■ កម្ពុជាស្វាគមន៍គោលដៅចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានយ៉ាងតិច ៧០% នៃប្រជាជនពិភពលោក <ទំព័រ៖២

■ «យើងជាព្រះសហគមន៍ធ្វើដំណើរជាមួយគ្នា» ជាប្រធានបទនៃសន្និបាតត្រីស្តបរិស័ទកាតូលិក ២០២១-២០២៣ <ទំព័រ៖១៨

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ the messenger

ខែ កញ្ញា | ឆ្នាំ ២០២១ | លេខទី ១៤៣

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

September, 2021 | #143

## យើងចូលរួមញែក វេចខ្ចប់ ទុកដាក់ និងបញ្ចេញសំរាមឱ្យបានត្រឹមត្រូវតាមពេលវេលាកំណត់




ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ តទៅ រាជធានីភ្នំពេញនឹងធ្វើការកំណែទម្រង់នៃការគ្រប់គ្រងសំរាម និងសំណល់រឹង ដោយតម្រូវឱ្យប្រជាពលរដ្ឋទាំងអស់ត្រូវធ្វើការញែក វេចខ្ចប់ ទុកដាក់ និងបញ្ចេញសំរាម សំណល់រឹងឱ្យបានត្រឹមត្រូវការកាលកំណត់ទៅតាមពេលវេលាឱ្យបានត្រឹមត្រូវ បើអ្នកណាមិនអនុវត្តតាមនឹងប្រឈមការដាក់ពិន័យផងដែរ។

**ត្រូវអនុវត្តនូវការគ្រប់គ្រងសំរាមសំណល់រឹង ដោយធ្វើការបែងចែក វេចខ្ចប់ និងការបញ្ចេញមកក្រៅ ចាប់ពីខែវិច្ឆិកានេះតទៅ**




# ខែកញ្ញាជាខែត្រូវទូលអង្វរព្រះជាម្ចាស់សម្រាប់ ឲ្យមនុស្សលោកយកចិត្តទុកដាក់ជាមួយបរិស្ថាន

បងប្អូនជាទីរាប់អាន! យើងម្នាក់ៗបានដឹងនិងឮគ្រប់គ្នាមកហើយថា ភពផែនដីជាផ្ទះរួមរបស់យើង បរិកាស ខ្យល់ ធនធានធម្មជាតិជាសម្បត្តិរួមសម្រាប់មនុស្សជាតិប្រើប្រាស់។ តាមជំនឿកាតូលិក អ្វីៗទាំងអស់នោះ ព្រះជាម្ចាស់បង្កើតឡើងសម្រាប់មនុស្ស ដើម្បីប្រើប្រាស់ មើលថែ និងរក្សា។

តាំងពីដើមរៀងមក មនុស្សបានប្រើប្រាស់ខុសទំនង នាំឱ្យមនុស្សទទួលបានទណ្ឌកម្មពីទង្វើរបស់ខ្លួន។

ក្នុងពេលបច្ចុប្បន្ននេះ បច្ចេកវិទ្យារីកចម្រើនឧហ្សាហកម្មល្ងូតលាស់ មនុស្សបានប្រមូលគ្រប់ធនធានធម្មជាតិដែលមានក្នុងដី លើគោក ក្នុងទឹក និងបានបង្កផលអាក្រក់ជាច្រើនផងដែរទៅក្នុងបរិយាកាស នាំឱ្យប្រែប្រួលយ៉ាងខ្លាំង ចំពោះអាកាសធាតុ ក្ដៅខ្លាំង ត្រជាក់ខ្លាំង រាំងស្ងួត ភ្លៀងខ្លាំងបង្កជំនន់ ...។ល។ ផលអវិជ្ជមានទាំងឡាយនេះ នាំឱ្យមនុស្សត្រូវការពិចារណា និងរកមធ្យោបាយគ្រប់គ្រងនិងថែរក្សាឱ្យបានល្អឡើងវិញ ។





ព្រះសហគមន៍កាតូលិក មានសម្ដេចប៉ាប ជាអ្នកណែនាំបានអំពាវនាវ និងជំរុញឱ្យគ្រីស្តបរិស័ទទាំងអស់យកចិត្តទុកដាក់ ចំពោះស្នាព្រះហស្តរបស់ព្រះជាម្ចាស់នៅលើផែនដីនេះ ដោយត្រូវរួមគ្នាអធិដ្ឋានពិសេស ដើម្បីរំឭកដល់អស់អ្នកទាំងឡាយណាដែលបានប្រើប្រាស់ជ្រុលហួសហេតុ បង្កជាមហន្តរាយរបស់ភពផែនដី។

តើអ្វីខ្លះដែលយើងទាំងអស់គ្នាអាចរួមគ្នាការពារភពផែនដីបាន?

សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូបានរំឭកថា «សូមឱ្យយើងម្នាក់ៗពិចារណា ឡើងវិញពីរបៀបរស់នៅរបស់ខ្លួន ទាំងការហូបចុក ការធ្វើដំណើរ ឬក៏របៀបដែលយើងប្រើប្រាស់ទឹក ភ្លើងអគ្គិសនី ប្លាស្ទិកជាពិសេសសម្ភារផ្សេងៗទៀតដែលបានបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថានរបស់យើង»។

ក្នុងពិភពលោកយើង មានសេចក្ដីប្រកាសអាសន្នជាច្រើនដើម្បីឱ្យពលរដ្ឋទាំងអស់យកចិត្តទុកដាក់ ត្រូវតែផ្លាស់ប្ដូរទម្លាប់រស់នៅក្នុងពេលបច្ចុប្បន្ននេះ។

តាមរបាយការណ៍របស់អង្គការសហប្រជាជាតិដែលបានចេញផ្សាយកាលពីខែមិថុនា កន្លងទៅបានប្រមាណថា ភពផែនដីកំពុងឈានដល់ចំណុចមួយដែលមិនអាចត្រឡប់ក្រោយបាននោះឡើយ ហើយប្រឈមនឹងការគំរាមកំហែងកើនបីដង គឺបាត់បង់ជីវចម្រុះ ការបំពុល អាកាសធាតុ និងបរិស្ថាន។

បងប្អូនជាទីស្រឡាញ់! បងប្អូនអាចសង្កេតឃើញការប្រែប្រួលទាំងអស់នេះដោយខ្លួនផ្ទាល់បាន តើប៉ុន្មានដងក្នុងប្រទេសកម្ពុជាដែលបានប្រកាសថាទទួលឥទ្ធិពលព្យុះ រាំងស្ងួត ភ្លៀងខ្លាំង ទឹកជំនន់។ល។

យើងទាំងអស់គ្នា ម្នាក់ៗកំពុងតែចង់បានរបស់ធម្មជាតិ ខ្យល់ធម្មជាតិ ទេសភាពធម្មជាតិស្អាត។ សូមចូលរួមទាំងអស់គ្នា ថែរក្សា និងការពារបរិស្ថានរបស់យើង។ សូមចូលរួម ប្រើប្រាស់ទឹកដោយសន្សំសំចៃ ក្រដាស ភ្លើងអគ្គិសនី កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក ឱ្យបានកាន់តែច្រើនឡើង។ ទុកដាក់សំរាមក្នុងផ្ទះរបស់ខ្លួនឱ្យមានរបៀបរៀបរយដូចជា សំណល់រឹង កាកសំណល់ផ្ទះបាយ គ្រឿងអេឡិចត្រូនិចជាដើម។ ប្រើឡើងវិញនូវរបស់របរដែលបងប្អូនអាចប្រើឡើងវិញបាន។

អាចបង្កើតសួនបន្លែតូចមួយក្នុងផ្ទះ ដើម្បីបង្កើតបរិយាកាសនិងជួយកាត់បន្ថយការកើនឡើងកំដៅផែនដីផងដែរ។

សូមប្ដូរទម្លាប់ដោយចាប់ផ្ដើមពីយើងម្នាក់ៗ បរិស្ថានជាជីវិតរបស់យើងទាំងអស់គ្នា! ភពផែនដីជា ផ្ទះរួមរបស់យើង! «ចូរនិយាយថាខ្ញុំធ្វើបាន!»៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្ដីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# កម្ពុជាស្វាគមន៍គោលដៅចាក់វ៉ាក់កូវីដ-១៩ ឱ្យបានយ៉ាងតិច ៧០% នៃប្រជាជនពិភពលោក

*អត្ថបទ៖ អមរិទ្ធ ដានុត*

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងក្នុងកិច្ចប្រជុំកំពូលសកលស្តីពីជំងឺកូវីដ-១៩ «ការបញ្ចប់ការរាតត្បាត និង ការកសាងឡើងវិញឱ្យកាន់តែប្រសើរ» នាថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២១ ដោយបានសូមស្វាគមន៍នូវការកំណត់គោលដៅចាក់វ៉ាក់សាំងជាពិសេសការចាក់វ៉ាក់សាំងឱ្យបានយ៉ាងតិច ៧០% នៃប្រជាជនពិភពលោក។

សម្តេចតេជោ ហ៊ុន សែន បានលើកឡើងថា ការឆ្លងរាលដាលជាសកលនៃជំងឺកូវីដ-១៩ គឺជាវិបត្តិរួម។ ហេតុនេះ កម្ពុជាយល់ស្របនឹងទស្សនៈថា «មិនមានប្រទេសណាអាចបញ្ឈប់វិបត្តិនេះតែម្នាក់ឯងបាននោះទេ។ យើងត្រូវធ្វើការរួមគ្នា, គាំទ្រគ្នា ទៅវិញទៅមក, ហើយត្រូវចងចាំថា មិនមាននណារម្នាក់អាចមានសុវត្ថិភាពនោះទេ ដរាបណាទាំងអស់គ្នា មិនទាន់មានសុវត្ថិភាព»។

សម្តេចបានមានប្រសាសន៍ថា ៖ «ដោយសារវ៉ាក់សាំងជាទំនិញដ៏សំខាន់ក្នុងការជួយសង្គ្រោះជីវិតមនុស្ស, កម្ពុជាសូមស្វាគមន៍នូវការកំណត់គោលដៅចាក់វ៉ាក់សាំង ជាពិសេសការចាក់វ៉ាក់សាំងឱ្យបានយ៉ាងតិច ៧០% នៃប្រជាជនពិភពលោក។ ដើម្បីសម្រេចគោលដៅនេះ, កម្ពុជា សូមអំពាវនាវឱ្យមានការកំណត់ វ៉ាក់សាំងកូវីដ-១៩ ទាំងអស់ ដែលត្រូវបានទទួលស្គាល់ដោយអង្គការសុខភាពពិភពលោក (WHO) ជាទំនិញយុទ្ធសាស្ត្រគន្លឹះសកល ដោយគ្មានការរើសអើងទៅលើប្រភេទ និង ប្រភពនៃវ៉ាក់សាំងឡើយ»។

សម្តេចក៏បានអំពាវនាវឱ្យកំណត់វ៉ាក់សាំងកូវីដ១៩ ជាទំនិញសាធារណៈដែលមានថ្លៃសមរម្យ និង អនុញ្ញាតឱ្យគ្រប់ប្រទេសទាំងអស់ អាចមានលទ្ធភាព ទទួលបាន និង ប្រើប្រាស់បានតាមតម្រូវការ ហើយលើសពីនេះទៀត បើកចំហការផលិតវ៉ាក់សាំងកូវីដ១៩ យ៉ាងទូលាយទៅតាមតំបន់ និងប្រទេសនានា ដែលមានលទ្ធភាព តាមរយៈការផ្តល់ហិរញ្ញប្បទាន និង ការលើកទឹកចិត្ត ដល់ការវិនិយោគលើការផលិតវ៉ាក់សាំង។

ជាការពិត, ស្ថានភាពនៃជំងឺកូវីដ-១៩ ឈានមកដល់ត្រីមាសទី ៣ នៃឆ្នាំ ២០២១ នេះ នៅបន្តប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ ដោយសារហានិភ័យពីរលកនៃការបំប្លែងខ្លួនថ្មីៗរបស់វីរុសកូរ៉ូណា ដែលមានសភាពកាន់តែកាចសាហាវ និងបន្តរំខានដល់សកម្មភាពសង្គម-សេដ្ឋកិច្ចទូទៅ ។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានលើកឡើងថា ៖ «កម្ពុជាយល់ថា ប្រទេសទាំងអស់ត្រូវប្រឹងប្រែង និង រួមសាមគ្គីគ្នាជាធ្លុងមួយ ដើម្បីសម្រេចគោលដៅដ៏ចម្បងនេះ ដោយមិនប្រកាន់ពូជសាសន៍, និន្នាការនយោបាយ និង ចៀសវាងឱ្យបាននូវ ការយកការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ធ្វើជារបៀបវារៈនយោបាយ ឬបម្រើរបៀបវារៈនយោបាយរបស់ខ្លួន»។



ទន្ទឹមនេះ, កម្ពុជា ក៏អំពាវនាវដល់រដ្ឋាភិបាលទាំងអស់ សូមកុំប្រមូលទិញវ៉ាក់សាំងទុកសម្រាប់តែប្រទេសរបស់ខ្លួន ឬ រក្សាវ៉ាក់សាំងដែលខ្លួនផលិតបាន ទុកសម្រាប់ប្រើប្រាស់តែក្នុងប្រទេសផ្ទាល់ខ្លួន។

នៅក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកការចាក់វ៉ាក់សាំងជា វិធានការយុទ្ធសាស្ត្រគន្លឹះ គួបផ្សំជាមួយនឹងវិធានការ ៣ ទៀត រួមមាន ៖ (១).ការខិតខំទប់ស្កាត់ និង រុករកការឆ្លងឱ្យបានទាន់ពេល, (២).ការពង្រឹងសមត្ថភាពព្យាបាល និង ការប្រើប្រាស់ថ្នាំព្យាបាល ប្រកបដោយស័ក្តិសិទ្ធភាព, និង (៣).ការអនុវត្តដោយហ្មត់ចត់នូវវិធានការផ្នែករដ្ឋបាល, សុខាភិបាល និង ច្បាប់ ក៏ដូចជាការទាក់ទាញការចូលរួមយ៉ាងសកម្មពីសំណាក់សាធារណជនគ្រប់មជ្ឈដ្ឋាន និងគ្រប់រូប។

សម្រាប់ទិសដៅទៅមុខ, កម្ពុជានឹងបន្តអនុវត្តវិធានការបង្ការ, ព្យាបាល និងចាក់វ៉ាក់សាំង ក៏ដូចជា រៀបចំក្របខណ្ឌវាយតម្លៃហានិភ័យគ្រប់ជ្រុងជ្រោយ ដើម្បីបើកដំណើរការនូវសកម្មភាពសង្គម-សេដ្ឋកិច្ច ពេញលេញឡើងវិញជាជំហាៗ ក្នុងស្មារតីប្រយ័ត្នប្រយែងខ្ពស់។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា៖ «រាជរដ្ឋាភិបាលនឹងប្រឹងប្រែងជំរុញការវិនិយោគលើវិស័យសង្គមកិច្ច ពិសេសគឺការពង្រឹងប្រព័ន្ធគាំពារសង្គម និង ប្រព័ន្ធសុខាភិបាល ដើម្បីត្រៀមលក្ខណៈសម្បត្តិឆ្លើយតបឱ្យបានទាន់ពេល និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ ទៅនឹងជំងឺរាត

# រាជរដ្ឋាភិបាលឱ្យធ្វើការទប់ស្កាត់ការវាយកម្ទេច និងបំផ្លិចបំផ្លាញសំណង់អគារបេតិកភណ្ឌ

*អត្ថបទ៖ អមរិទ្ធ ដានុត*

រាជរដ្ឋាភិបាលកម្ពុជា បានចេញសារាចរស្តីពីការទប់ស្កាត់ការវាយកម្ទេចនិងបំផ្លិចបំផ្លាញសំណង់អគារបេតិកភណ្ឌ ក្រោយពេលរាជរដ្ឋាភិបាលបានពិនិត្យឃើញថា សព្វថ្ងៃដោយសារទំនើបកម្មបណ្តាលឱ្យមានការបាត់បង់ការវាយ បំផ្លិចបំផ្លាញ ការធ្វើឱ្យខូចខាតតាមគ្រប់រូបភាពជាបន្តបន្ទាប់ចំពោះសំណង់អគារបេតិកភណ្ឌដែលស្ថិតនៅក្នុងតំបន់ បេតិកភណ្ឌទីក្រុង តាមបណ្តារាជធានី ខេត្ត។

សារាចរដែលចុះហត្ថលេខាដោយសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន នាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ បានលើកឡើងថា សំណង់អគារបេតិកភណ្ឌដែលជាសម្បត្តិបេតិកភណ្ឌជាតិដ៏មានតម្លៃ មានការប្រឈមនឹងហានិភ័យ និងស្ថិតក្រោមការគំរាមកំហែងខ្ពស់ដោយការអភិវឌ្ឍដែលទាមទារឱ្យមានការថ្លឹងថ្លែងរវាងការអភិរក្ស និងការអភិវឌ្ឍ គឺត្រូវតែមានតុល្យភាព។

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការណែនាំឱ្យមានការចូលរួមការងារអភិរក្សតំបន់បេតិកភណ្ឌទីក្រុង ដែលមានសំណង់អគារសាសនាផ្សេងៗ សំណង់ សាធារណៈ សំណង់ឯកជន ភូមិដ្ឋាន និងផ្ទះបុរាណ ស្របតាមច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម កាលថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ។

សម្តេចហ៊ុន សែន បានលើកឡើងថា ៖ «ហាមឃាត់ចំពោះការកែប្រែការប្តូររូបរាងខាងក្រៅ ឬធ្វើឱ្យខូចខាតសោភ័ណភាពចំពោះសំណង់នៃតំបន់បេតិកភណ្ឌទីក្រុង និងទប់ស្កាត់ការវាយកម្ទេចនិងបំផ្លិចបំផ្លាញសំណង់វប្បធម៌ ប្រវត្តិសាស្ត្រ សំណង់បុរាណ និងសំណង់អគារបេតិកភណ្ឌ ដើម្បីការពារឱ្យបានគង់វង្ស»។



សម្តេចនាយករដ្ឋមន្ត្រីបានណែនាំឱ្យមានការបញ្ឈប់ជាបន្ទាន់ចំពោះការបំផ្លាញអគារបេតិកភណ្ឌក្នុងតំបន់ការពារនិងក្រៅតំបន់ការពារ ដោយផ្តោតលើយុទ្ធសាស្ត្រគោលនយោបាយ និងផែនទីចង្អុលបង្ហាញ ដើម្បីជំរុញការអភិរក្សនិងការអភិវឌ្ឍទីក្រុងបេតិកភណ្ឌប្រកបដោយនិរន្តរភាព។

សម្តេចបន្តថា សំណង់អគារបេតិកភណ្ឌដែលនឹងត្រូវធ្វើការជួសជុលកែប្រែរូបរាង ឬវាយកម្ទេចចោល ត្រូវស្នើសុំការពិនិត្យ និងសម្រេចពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងអាជ្ញាធរពាក់ព័ន្ធជាមុនសិន៕

## លោក ទៀ បាញ់ ណែនាំពីការប្រមូលពន្ធ និងប្តូរចង្កូតពីស្តាំមកឆ្វេងលើយានជំនិះគ្រប់ប្រភេទដែលបំពាក់ស្លាកលេខខ.មយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

*អត្ថបទ៖ អមរិទ្ធ ដានុត*

រដ្ឋមន្ត្រីក្រសួងការពារជាតិ លោក ទៀ បាញ់ បានចេញសារាចរណែនាំមួយ ស្តីពីការអនុវត្តវិធានការប្រមូលពន្ធ និងប្តូរចង្កូតពីស្តាំមកឆ្វេងលើយានជំនិះគ្រប់ប្រភេទដែលកំពុងប្រើប្រាស់ស្លាកលេខកងយោធពលខេមរភូមិន្ទ(ខម)។

យោងតាមសារាចរណែនាំដែលចុះហត្ថលេខាដោយលោក ទៀ បាញ់ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១នេះ បានឱ្យដឹងថា ក្រសួងការពារជាតិដាក់ចេញនូវសារាចរណែនាំដោយឱ្យបណ្តាស្ថាប័នកងឯកភាពទូទាំងកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តឱ្យបានល្អប្រសើរ និងម៉ឺងម៉ាត់ចំពោះវិធានការរាជរដ្ឋាភិបាលស្តីអំពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ២០២១ ជាលើកចុងក្រោយ ចំពោះយានយន្តឯកជនដែលជ្រកក្រោម ស្លាកលេខ កងយោធពលខេមរភូមិន្ទ (ខ.ម) ដើម្បីឱ្យម្ចាស់ចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធ និងអាករនាំចូលស្របច្បាប់ និងបទប្បញ្ញត្តិស្តីពីគយ ។

លោក ទៀ បាញ់ បានបញ្ជាក់ក្នុងសេចក្តីណែនាំនេះថា ៖ «អនុវត្តការប្តូរចង្កូតពីស្តាំមកឆ្វេងឱ្យបានទាន់ពេលវេលាកំណត់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២»។

លោករដ្ឋមន្ត្រីបានបន្ថែមថា ការចុះបញ្ជីអនុញ្ញាតឱ្យប្រើប្រាស់ស្លាកលេខ ខ.ម អាចដំណើរការបានចំពោះយានយន្តដែលរដ្ឋបំពាក់, យានយន្តដែលទទួលបានពីបណ្តាប្រទេសផ្តល់ជំនួយ, យានយ ន្តជាអំណោយពីសប្បុរសជន ដែលបានបំពេញកាតព្វកិច្ចពន្ធរួចរាល់, យានយន្តកម្មសិទ្ធរបស់រដ្ឋដែលអស់ប្រសិទ្ធភាពប្រើប្រាស់ ហើយត្រូវកែថ្ងៃរៀបតម្លើងសារជាថ្មី, យានយន្តដែលទទួលបានពីការសម្រេចរបស់តុលាការ,យានយន្តដែលនាយទាហានប្រើប្រាស់ធនធានផ្ទាល់ខ្លួនទិញដាក់បញ្ចូលប្រើប្រាស់ ក្នុងក្របខណ្ឌរដ្ឋដោយបានបំពេញកាតព្វកន្ធរួចរាល់។

ចំពោះយានយន្តឯកជនពាក់ស្លាកលេខ ខ.ម ហើយបានទៅបំពេញកាតព្វកិច្ចពន្ធតាមសេចក្តីជូនដំណឹងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងការពារជាតិ នឹងរក្សាទុកឱ្យប្រើប្រាស់ជាធម្មតា។

លោក ទៀ បាញ់ បានបន្ថែមថា ក្នុងករណីយានយន្តឯកជនពាក់ស្លាកលេខ ខ.ម ហើយមិនបានទៅបំពេញកាតព្វកិច្ចពន្ធតាមសេចក្តីជូនដំណឹងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងការពារជាតិនឹងធ្វើការនិរាករណ៍ស្លាកលេខ ដែលបានបំពាក់កន្លងមកដោយស្វ័យប្រវត្តិ។

លោកបញ្ជាក់ទៀតថាអគ្គនាយកដ្ឋានយោធសេវាសហការជាមួយស្ថាប័នកងយោធពលខេមរភូមិន្ទ រៀបចំឯកសារ និងកម្មវិធីធ្វើការចុះផ្សព្វផ្សាយ អប់រំណែនាំ ឱ្យស៊ីជម្រៅដល់បណ្តាអង្គភាពទូទាំងកងយោធពលខេមរភូមិន្ទ៕

# USAID ផ្តល់ហិរញ្ញប្បទានថ្មី ចំនួន៥លានដុល្លារស្តារស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*អត្ថបទ៖ ផល សុផានិត*

ទីភ្នាក់ងារជំនួយអាមេរិក (USAID) ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១បាន ប្រកាសអំពីហិរញ្ញប្បទានបន្ថែមក្នុងទំហំទឹកប្រាក់ ៥ លានដុល្លារសហរដ្ឋអាមេរិក ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមរយៈគម្រោងដែលមានឈ្មោះថា «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ដែលនឹងត្រូវគ្រប់គ្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។

ហិរញ្ញប្បទានបន្ថែមនេះ នឹងធ្វើឲ្យសកម្មភាពប្រតិបត្តិការមានតម្លៃសរុបចំនួន ៦,៥ លានដុល្លារសហរដ្ឋអាមេរិក។

ឯកអគ្គរដ្ឋទូតអាមេរិក លោក W. Patrick Murphy បានថ្លែងថា យើងមានមោទនភាព ក្នុងការគាំទ្រដល់គម្រោងនេះ។ រដ្ឋាភិបាលសហរដ្ឋអាមេរិក មានសេចក្តីប្តេជ្ញាយូរអង្វែងក្នុងការលើកកម្ពស់សន្តិភាពនិងការផ្សះផ្សាជាតិ តាមរយៈការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

លោកថា គម្រោងនេះនឹងផ្តល់ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនូវការប្រើប្រាស់សេវាថែទាំសុខភាព និងចងក្រងនូវស្ថានភាពសុខភាព និង ក្តីព្រួយបារម្ភ ស្ថានភាពសង្គមសេដ្ឋកិច្ច និងបទពិសោធន៍ពេលឆ្លងកាត់ របបខ្មែរក្រហម។

លោកឯកអគ្គរដ្ឋទូតបន្ថែមថា ៖ «ការងារថ្មីមួយនេះនឹងធ្វើការសិក្សាស្រាវជ្រាវផ្ទាល់អំពីស្ថានភាពសុខុមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបន្ទាប់មក ធ្វើការប្រែក្លាយលទ្ធផលរកឃើញឲ្យ ទៅជាយុទ្ធនាការបង្កើនការយល់ដឹងរបស់សាធារណៈ»។



គម្រោងនេះនឹងធ្វើប្រតិបត្តិការនានាដើម្បីធ្វើឲ្យប្រសើរឡើងនូវសុខភាព សុខុមាលភាពនិងភាពសុខស្រួល របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទូទាំងប្រទេស។

លោក ឆាំង យុ នាយកប្រតិបត្តិមជ្ឈមណ្ឌលឯកសារកម្ពុជាបានលើកឡើងថា សោកនាដកម្មនិងភាពអយុត្តិធម៌ ដែលប្រជាជនកម្ពុជាទទួលរងនៅក្នុងរបបខ្មែរក្រហម មានទំហំមហាសាលដែលគ្មានអ្វីអាចជំនួសឬប៉ះប៉ូវជូនអ្នកទាំងអស់បានទេ។

លោកថា ទោះបីជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងមួយនេះ គឺជាជំហានឆ្ពោះទៅសម្រេចបានការថែទាំនិងគាំពារដល់អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ហិរញ្ញប្បទានពិសេស នេះរួមបញ្ចូលនូវអ្នកស្ម័គ្រចិត្តប្រកបដោយភាពមោះមុតចំនួន ៥០០ នាក់ ដែលបំពេញការងារនៅទូទាំងប្រទេស ក្នុងការជួយនាំអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិឋានរបស់ខ្លួនទៅមន្ទីរសុខភាពក្នុងសហគមន៍។

លោក ឆាំង យុ បានមានប្រសាសន៍ថា ៖ «តាមរយៈការងារស្ម័គ្រចិត្តនេះ យុវជន-យុវនារីទទួលបានឱកាសបង្ហាញចេញនូវភាពជាអ្នកដឹកនាំ រួមជាមួយនឹងការបំពេញការងារដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីគាំពារដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក៏ដូចជាចំពោះប្រជាជាតិកម្ពុជា»។

លោកបានបន្ថែមថា ទន្ទឹមនឹងនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបានឱកាសចែករំលែករឿងរ៉ាវឆ្លងកាត់ផ្ទាល់ខ្លួននៅក្នុងអំឡុងរបបខ្មែរក្រហម ទៅកាន់ក្មេងជំនាន់ក្រោយ ដើម្បីធានាថាយើងនៅតែចងចាំ ពេលវេលាដ៏លំបាកយ៉ាងខ្លាំងមួយនោះ។ ជារួម គម្រោងនេះនឹងរំលេចនូវចរិក មនុស្សធម៌ និងពង្រឹងបន្ថែមនូវស្មារតី មិនងាយទ្រុឌទ្រោមរបស់ប្រជាជនកម្ពុជា។

លោកនាយកប្រតិបត្តិមជ្ឈមណ្ឌលឯកសារកម្ពុជា បានបញ្ជាក់ឧទាហរណ៍ខ្លះៗនៃផែនការសកម្មភាពថ្មីទាំងនេះ រួមមាន ការបង្កើតជាអាហារូបករណ៍ក្នុងចំនួនកំណត់សម្រាប់សិស្សសិក្សាផ្នែកវេជ្ជសាស្ត្រ សុខភាពផ្លូវចិត្ត សុខភាពសាធារណៈ និងសុខភាពបឋម។ សកម្មភាពខាងលើថែមទាំងផ្តើមផងដែរនូវសកម្មភាពស្ម័គ្រចិត្តប្រតិបត្តិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលគាំពារដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

សូមបញ្ជាក់ថា USAID ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅទូទាំង ២៥ រាជធានី-ខេត្ត បានធ្វើការជាមួយដៃគូកម្ពុជានិងអន្តរជាតិ ដើម្បីអនុវត្តកម្មវិធីនានា ជាប្រយោជន៍សម្រាប់ប្រជាជនកម្ពុជាទាំងអស់។ ដោយការងារផ្តោតលើការពង្រឹងអភិបាលកិច្ចប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស, ការធ្វើឲ្យប្រសើរឡើងនូវសុខភាពនិងអាហារូបត្ថម្ភ, ការទ្រទ្រង់ដល់ការអប់រំនិងការលូតលាស់របស់កុមារ, ការបង្កើនទិន្នផលកសិកម្មនិងសុវត្ថិភាពចំណីអាហារ, ការអភិរក្សព្រៃឈើនិងតំបន់រងទឹកភ្លៀង រួមជាមួយនឹងការជួយដល់កសិករនិងប្រជាជនក្នុងតំបន់ឲ្យអាចសម្របខ្លួននិងកាត់បន្ថយគ្រោះថ្នាក់ធម្មជាតិ៕

# ជប៉ុននិងយូនីសេហ្វផ្តល់បរិក្ខារគ្រប់គ្រងប្រព័ន្ធត្រជាក់សម្រាប់វ៉ាក់សាំងកូវីដ-១៩



*អត្ថបទ៖ អមរិន្ទ ដានុត*

បរិក្ខារចាំបាច់សំខាន់ៗ សម្រាប់ពង្រឹងការគ្រប់គ្រងប្រព័ន្ធត្រជាក់ ដែលប្រើប្រាស់សម្រាប់វ៉ាក់សាំងកូវីដ-១៩ត្រូវបានប្រគល់ជូនក្រសួងសុខាភិបាលកម្ពុជានាថ្ងៃចន្ទម្សិលមិញនេះ ដែលគាំទ្រដោយប្រទេសជប៉ុន និងយូនីសេហ្វ។

យោងតាមសេចក្តីប្រកាសព័ត៌មានស្ថានទូតជប៉ុនប្រចាំកម្ពុជានិងអង្គការយូនីសេហ្វ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ បានឱ្យដឹងថា បរិក្ខារដែលក្រសួងទទួលបានរួមមាន ទូរក្លាស្សេវ៉ាក់សាំងចំនួន ២១ គ្រឿង, ម៉ា ស៊ីនកំណត់កម្លាំងវ៉ុលអគ្គិសនី ២១គ្រឿង និងឧបករណ៍សម្គាល់ទូក្លាស្សេសម្រាប់ពិនិត្យតាមដានសីតុណ្ហភាព ចំនួន២៧១ គ្រឿង ដែលបានទទួលថវិកាគាំទ្រពីរដ្ឋាភិបាលជប៉ុន និងការគាំទ្រផ្នែកលទ្ធ កម្មពីយូនីសេហ្វ។

សេចក្តីប្រកាសដដែលនេះបានលើកឡើងថា ៖ «វត្តមាននៃបរិក្ខារប្រព័ន្ធត្រជាក់ដែលដំណើរការល្អនៅទូទាំងប្រទេសកម្ពុជា នឹងធានាឲ្យមានការរក្សាទុកវ៉ាក់សាំងកូវីដ-១៩បានល្អ និងធ្វើឲ្យការផ្តល់វ៉ាក់សាំងនិងថ្នាំបង្ការជាប្រចាំ នៅក្នុងប្រទេសនេះមានដំណើរការកាន់តែប្រសើរនៅក្នុងរយៈពេលវែង»។

គិតមកដល់បច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់វ៉ាក់សាំងជូនពលរដ្ឋអាយុចាប់ពី ១២ ឆ្នាំឡើងទៅប្រមាណ ១១.៥លាននាក់ ស្មើនឹងប្រហែល ៩៥%នៃក្រុមប្រជាជនគោលដៅ។ លទ្ធផលនេះធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលបានចាក់វ៉ាក់សាំងជូន ពលរដ្ឋច្រើនជាងគេនៅក្នុងតំបន់អាស៊ាន និងនៅក្នុងសកលលោក ដែលនេះជាសមិទ្ធផលមួយដ៏ អស្ចារ្យ។

ការផ្តល់ជំនួយទាន់ពេលវេលាជាបរិក្ខារប្រព័ន្ធត្រជាក់បន្ថែមពីរាជរដ្ឋាភិបាលជប៉ុន គឺជួយពន្លឿនកិច្ចខិតខំប្រឹងប្រែងនេះបន្ថែមទៀត ព្រោះថាបរិក្ខារទាំងនេះនឹងធានាថាការចែកចាយវ៉ាក់សាំងកូវីដ-១៩ នាពេលបច្ចុប្បន្ននេះ នឹងមិនទទួលសម្ពាធខ្លាំងពេកលើសមត្ថភាពបច្ចុប្បន្ន និងមិន បង្កការរំខានដល់សេវាផ្តល់ថ្នាំបង្ការជាប្រចាំ ជាពិសេសការផ្តល់ថ្នាំបង្ការដល់កុមារឡើយ។ នេះបើតាមសេចក្តីប្រកាសព័ត៌មាននេះ។

ប្រភពដដែលបានបន្តថា ការគាំទ្រនេះ គឺជាផ្នែកមួយនៃជំនួយឆ្លើយតបចំពោះស្ថានភាពបន្ទាន់ពីរដ្ឋាភិបាលជប៉ុនដែលមានទឹកប្រាក់សរុបចំនួន ៣៦.៩ លានដុល្លារ ដល់ការិយាល័យយូនីសេហ្វប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក សម្រាប់គាំទ្រដល់ប្រទេសចំនួន១២ ក្នុងការបង្កើនសមត្ថភាពនៃប្រព័ន្ធត្រជាក់របស់ខ្លួន។ ថវិកាចំនួន ៩០៧,៥៨៨ដុល្លារ ត្រូវបានវិភាជន៍សម្រាប់ប្រទេសកម្ពុជា។

ជាមួយគ្នានេះដែរ ប្រទេសជប៉ុនក៏បានសន្យាផ្តល់ថវិកាចំនួន ១ពាន់លានដុល្លារ ដល់កម្មវិធីកូវ៉ាក់សកល លោកដែលជាយន្តការអន្តរជាតិដឹកនាំដោយសម្ព័ន្ធសកលសម្រាប់វ៉ាក់សាំង និងថ្នាំបង្ការ (GAVI) សម្ព័ន្ធនវានុវត្តន៍ដើម្បីត្រៀមទប់ទល់នឹងការរាតត្បាតនៃជំងឺ (CEPI) អង្គការសុខភាពពិភពលោក និងយូនីសេហ្វផងដែរ ដើម្បីធានានិងពន្លឿនការទទួលបានវ៉ាក់សាំងប្រកបដោយសមធម៌ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។

កាលពីពេលថ្មីៗនេះ ប្រទេសជប៉ុនបានផ្តល់ជាជំនួយវ៉ាក់សាំង ស្ត្រាហ្សេនីកា ចំនួន១លានដូសដែលផលិតនៅជប៉ុន ផ្តល់ជូនប្រទេសកម្ពុជា។

លោក មិកាមិ ម៉ាសាហ៊ីរ៉ូ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖«ដើម្បីឲ្យវ៉ាក់សាំងមានប្រសិទ្ធភាព គេត្រូវរក្សាទុកវានៅសីតុណ្ហភាពសមស្រប ដែលនេះគឺជាមុខងាររបស់ឧបករណ៍ទាំងនេះអាចធ្វើបាន។ យើងមានទំនុកចិត្តយ៉ាងមុតមាំថា ការរួមចំណែករបស់យើងនឹងផ្តល់នូវកម្លាំងវិជ្ជមាន ដើម្បីជួយពន្លឿនវឌ្ឍនភាពគួរឲ្យកត់សម្គាល់ឆ្ពោះទៅរកការស្តារឡើងវិញ ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេច បានកន្លងមក»។

លោកបានបន្តថា ៖ «មិត្តភាពរបស់យើងជាមួយនឹងពលរដ្ឋកម្ពុជា គឺជាមិត្តភាពដ៏សែនជ្រាលជ្រៅ ហើយយើងសង្ឃឹមថា ការគាំទ្រនេះនឹងជួយឲ្យមិត្តភាពរបស់យើងឈានទៅមុខមួយជំហានទៀត»។

ចំណែកលោកស្រី ហ្វ័ហ្គហ្វយូហ្សិច នាយិកាយូនីសេហ្វប្រចាំកម្ពុជា បានលើកឡើងដែរថា ពលរដ្ឋជប៉ុនគឺជាមិត្តដ៏អស្ចារ្យរបស់ពលរដ្ឋកម្ពុជានៅក្នុងអំឡុងពេលនៃវិបត្តិនេះ ហើយនេះគឺជា ការគាំទ្រដ៏សំខាន់ និងចាំបាច់មួយទៀតដែលពលរដ្ឋជប៉ុនបានផ្តល់ដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងដ៏គួរឲ្យស្ញប់ស្ញែង ក្នុងការឆ្លើយតបចំពោះការរាតត្បាតជាសកលនេះ៕

# ឥណទានសម្បទាន និងហិរញ្ញប្បទានឥតសំណង របស់ជប៉ុន ៧២លានដុល្លារ ត្រូវបានចុះហត្ថលេខា

*អត្ថបទ៖ អមរិទ្ធ ដានុត*

លិខិតប្តូរសារ និងឯកសារពាក់ព័ន្ធ ស្តីពីការផ្តល់ឥណទានសម្បទាន និងហិរញ្ញប្បទានឥតសំណងរបស់ជប៉ុន ក្នុងទំហំទឹកប្រាក់សរុបប្រមាណ៧២ លានដុល្លារអាមេរិក ដើម្បីរួមចំណែកដល់ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម នៃប្រទេសកម្ពុជា សម្រាប់អនុវត្តគម្រោងចំនួន៦ ក្នុងនោះមានឥណទានសម្បទាន១គម្រោង និងហិរញ្ញប្បទានឥតសំណង៥គម្រោង ត្រូវបានធ្វើឡើងនាព្រឹកថ្ងៃទី១១ខែតុលាឆ្នាំ២០២១នេះ។

លិខិតប្តូរសារ និងឯកសារពាក់ព័ន្ធ ត្រូវបានចុះហត្ថលេខាដោយលោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងលោកមិកាមិ ម៉ាសាហ៊ីរ៉ូ (MIKAMI Masahiro) ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា។

គម្រោងរួមមាន គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតខេត្តសៀមរាប (ដំណាក់កាលទី២) ដែលមានទឹកប្រាក់ប្រមាណ ៥៨,២១ លានដុល្លារ អាមេរិក។

សម្រាប់ហិរញ្ញប្បទានឥតសំណង មានគម្រោងគាំទ្រដំណើរការកសាងផែនការបោសសម្អាតមីន និងត្រួតពិនិត្យគុណភាព លើផ្ទៃដីបោសសម្អាត ដែលមានទឹកប្រាក់ប្រមាណ ១,៨ លានដុល្លារអាមេរិក,គម្រោងសម្ភារៈបច្ចេកទេស សម្រាប់មន្ទីរពិសោធន៍ជាតិសំណង់ ដែលមានទឹកប្រាក់ប្រមាណ ២,២៧ លានដុល្លារអាមេរិក, សម្ភារៈបច្ចេកទេសសម្រាប់ស្ថានីយវាស់វែងអចិន្ត្រៃយ៍ និងមជ្ឈម ណ្ឌលទិ ន្នន័យ ដែលមានទឹកប្រាក់ប្រមាណ ២,២៧ លានដុល្លារអាមេរិក។

គម្រោ ងបំពាក់ឧបករណ៍សម្ភារៈ និងបរិក្ខារបច្ចេកទេសសម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានទឹកប្រាក់ប្រមាណ ៣,៦៣ លានដុល្លារអាមេរិក និងគម្រោងបំពាក់សម្ភារៈបរិក្ខារ និងគ្រឿងម៉ាស៊ីនក្នុងវិស័យឧស្សាហកម្មគ្រឿងយន្ត អេឡិចត្រូនិច និងមេកានិក នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានទឹកប្រាក់ប្រមាណ ៤,៥៤ លានដុល្លារអាមេរិក។

ថ្លែងនៅក្នុងឱកាសនោះ លោក ប្រាក់ សុខុន បានលើកឡើងថា ពិធីចុះហត្ថលេខានៅក្នុងថ្ងៃនេះ គឺជាសក្ខីភាពនៃការបន្តជួយគាំទ្ររបស់ជប៉ុនដល់កម្ពុជា បើទោះបីជាមានការរីករាលដាលនៃជំងឺកូវីដ-១៩ ក្តី ហើយដែលជាការជួយគាំទ្រយ៉ាងរឹងមាំដល់ការអភិវឌ្ឍនៅកម្ពុជា។

លោកបានបញ្ជាក់បន្ថែមថា៖ «ប្រទេសជប៉ុនបាននិងកំពុងជួយគាំទ្រដល់កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ តាមរយៈការផ្តល់ឥណទានសម្បទាន ហិរញ្ញប្បទានឥតសំណង និងវ៉ាក់សាំង ហើយដែលជំនួយសប្បុរសធម៌ទាំងនេះ ឆ្លុះបញ្ចាំងនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធរវាងប្រទេសកម្ពុជា និងជប៉ុនព្រមទាំងបានរួមចំណែកដល់យុទ្ធនាការចាក់វ៉ាក់សាំងនៅទូទាំងប្រទេសរបស់កម្ពុជា»។

លោករដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា ជំនួយរបស់ជប៉ុនបាននិងកំពុងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសង្គម និងធនធានមនុស្ស នៅកម្ពុជា ហើយជំនួសមុខឱ្យរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ឯកឧត្តម បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនជប៉ុន ដែលតែងតែបន្តជួយដល់កម្ពុជា។

ជាងនេះទៅទៀត លោក ប្រាក់ សុខុន ក៏បានបញ្ជាក់បន្ថែមថា ប្រទេសជប៉ុន គឺជាស្ថាបត្យករដ៏សកម្មនៅក្នុងដំណើរការស្វែងរកសន្តិភាព នៅក្នុងប្រទេសកម្ពុជា ហើយនិងបានរួមចំណែកយ៉ាងសំខាន់បំផុតដល់ដំណើរការកសាងប្រទេសកម្ពុជាឡើងវិញក្រោយសង្គ្រាមហែកហួរប្រទេស និងការបំផ្លិចបំផ្លាញអស់ជាច្រើនទសវត្សរ៍៕

# អង្គការសង្គមស៊ីវិលជិត៣០ ស្នើឱ្យរដ្ឋាភិបាលកម្ពុជា បញ្ឈប់ការបំភិតបំភ័យលើអ្នកវិភាគបញ្ហាសង្គម

*អត្ថបទ៖ អមរិទ្ធ ដានុត*

អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ សហជីព និងសហគមន៍ជិត៣០ស្ថាប័ន បានអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា បញ្ឈប់ការបំភិតបំភ័យលើអ្នកវិភាគបញ្ហាសង្គមនៅកម្ពុជា និងសំឡេងរិះគន់ផ្សេងទៀតដោយគ្រាន់អ្នកទាំងនោះបញ្ចេញទស្សនៈ ខណៈមន្ត្រីរាជរដ្ឋាភិបាលបានលើកឡើងវិញថា ការវិភាគមួយចំនួននៅកម្ពុជា ដែលជាក្រុមបញ្ចោរនិងលើកជើងថាជាអ្នកវិភាគឯករាជ្យនោះ គឺមិនមែនជាការវិភាគតាមបែបវិជ្ជាជីវៈនិងមានលក្ខណៈវិទ្យាសាស្ត្រនោះទេ

យោងតាមសេចក្តីថ្លែងការណ៍រួមមួយអំពី «ការគំរាមកំហែងទៅលើអ្នកវិភាគគឺជាការគំរាមកំហែងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា» កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ សហជីព និងសហគមន៍ចំនួន២៩ស្ថាប័ន បានលើកឡើងថា ការគំរាមកំហែងលើអ្នកវិភាគបញ្ហាសង្គម និងនយោបាយ ដោយគ្រាន់តែអ្នកទាំងនោះប្រើប្រាស់សេរីភាព ខាងការបញ្ចេញមតិស្របច្បាប់ មិនគួរត្រូវបានធ្វើឡើងតាំងពីដំបូងមកម្ល៉េះ។

សេចក្តីថ្លែងការណ៍រួមនេះបានបញ្ជាក់ថា៖«ការគំរាមកំហែងបែបនេះបង្កជាគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សេរីភាពខាងការបញ្ចេញមតិ ដែលត្រូវបានការពារដោយច្បាប់ជាតិនិងច្បាប់អន្តរជាតិ។ សេរីភាពខាងការបញ្ចេញមតិគឺជាសេរីភាពមូលដ្ឋានរបស់ពលរដ្ឋគ្រប់រូប ដោយមិនគួរត្រូវបានការពារ និងគោរព តែនៅពេលដែលប្រើប្រាស់ដើម្បីសរសើររាជរដ្ឋាភិបាលនោះទេ ត្រូវតែត្រូវបានអាជ្ញាធរគោរព និងការពារគ្រប់ការបញ្ចេញមតិ ទាំងអស់»។

គួរបញ្ជាក់ថា នៅក្នុងសុន្ទរកថាដែលបានធ្វើឡើងកាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ សម្តេចនាយករដ្ឋមន្ត្រី បានព្រមានអ្នកវិភាគបញ្ហាសង្គមនៅកម្ពុជា ចំពោះការអត្ថាធិប្បាយទៅលើគោលនយោបាយការបរទេសកម្ពុជា។ ជាក់ស្តែង ឈ្មោះរបស់លោកបណ្ឌិត មាស នី ជាអ្នកវិភាគមួយរូបដែលបានធ្វើអត្ថាធិប្បាយរិះគន់អំពីគោលនយោបាយ ការបរទេសរបស់កម្ពុជាជាមួយប្រទេសចិន ត្រូវបានលើកឡើង ហើយលោករងការព្រមានថា កុំព្រហើនពេក។

សម្តេចនាយករដ្ឋមន្ត្រីក៏បានលើកឡើងផងដែរ អំពីការចេញដីកាចាប់ខ្លួនអ្នកវិភាគមួយរូបផ្សេងទៀតដែលបានបង្ហោះ លក្ខខណ្ឌប្រាំមួយចំណុចអំពីការបង្កើតរដ្ឋាភិបាលបង្រួបបង្រួមជាតិ នៅលើបណ្តាញសង្គមហ្វេសប៊ុករបស់ខ្លួន។ ក្រោយមក អ្នកវិភាគរូបនោះត្រូវបានបញ្ជាក់ថាជាលោកបណ្ឌិត សេង សារី ហើយលោករងការព្រមានថា ប្រសិនបើ ការបង្ហោះនោះមិនត្រូវបានដកចេញពីហ្វេសប៊ុកទេ នោះសកម្មភាពខាងលើរបស់លោកនឹងត្រូវបានគេចាត់ទុកថាជាបទល្មើសជាក់ស្តែង ហើយអាចនឹងត្រូវចាប់ខ្លួនពេលណាក៏បាន។

នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ សម្តេចនាយករដ្ឋមន្ត្រីក៏បានបង្ហោះសារនៅលើទំព័រហ្វេសប៊ុករបស់ខ្លួនដោយបញ្ជាក់ថា ការបកស្រាយរបស់លោក បណ្ឌិត សេង សារី មានលក្ខណៈសមហេតុសមផល និងអាចទទួលយកបាន ព្រមទាំងអំពាវនាវឱ្យតុលាការ ពិចារណាបញ្ចប់នីតិវិធីច្បាប់ទៅលើលោកបណ្ឌិត សេង សារី ផងដែរ។

អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ សហជីព និងសហគមន៍ទាំងនេះបានលើកឡើងទៀតថា អ្នកវិភាគបញ្ហាសង្គមនិងនយោបាយគួរតែអាចអនុវត្តការងាររបស់ខ្លួនដោយស្របច្បាប់ និងផ្សព្វផ្សាយនូវអ្វីដែលពួកគេរកឃើញដោយគ្មានការគំរាមកំហែង ឬការព្រមានណាមួយ ទោះបីជាទស្សនៈទាំងនោះមិនពេញ ចិត្តចំពោះរដ្ឋាភិបាលក៏ដោយ។

សេចក្តីថ្លែងការណ៍រួមបានថ្លែងថា ៖ «យើងខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមមេត្តាបញ្ឈប់ការបំភិតបំភ័យ និងដាក់ទោសដល់អ្នកដែលបានបញ្ចេញមតិបែបតន់ ឬមតិផ្ទុយ ហើយសូម មេត្តាបង្ហាញពីភាពបើកឆន្ទៈទូលាយក្នុងការស្តាប់ ហើយគោរពសិទ្ធសេរីភាពខាងការបញ្ចេញមតិរបស់ពលរដ្ឋខ្មែរគ្រប់រូប ជាពិសេសទោះបីជាទស្សនៈទាំងនោះមិនស្របតាមគំនិតរបស់ អាជ្ញាធរដ្ឋក៏ដោយ»។

អង្គការសង្គមស៊ីវិលទាំងនេះរួមមាន ក្រុមការងារដើម្បីដោះស្រាយទំនាស់, អង្គការអភិវឌ្ឍន៍សំលេងសហគមន៍, សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ, សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា,អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា, សមាគមការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) រួមនឹងស្ថាប័នជាច្រើនទៀត។

ទាក់ទងនឹងការលើកឡើងរបស់ក្រុមអង្គការសហគមន៍ទាំងនេះ លោក ជិន ម៉ាលីន រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាអនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១នេះ បានធ្វើការឆ្លើយតបដោយលើកយកនូវចំណុចសំខាន់មួយចំនួនមកបញ្ជាក់។

លោកបានលើកឡើងថា ការវិភាគដែលចាត់ទុកថាជាសិទ្ធិសេរីភាពនៃការសម្តែងមតិនិងទស្សនៈហើយដែលការពារដោយច្បាប់នោះ គឺជាការវិភាគតាមបែបវិជ្ជាជីវៈ បានន័យថាជាការវិភាគតាមបែបវិទ្យាសាស្ត្រ មានមូលដ្ឋាននិងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវច្បាស់លាស់ ដោយផ្អែកលើទិដ្ឋភាពទ្រឹស្តី គោលការណ៍ទូទៅ កិច្ចសម្ភាសន៍ និងការអនុវត្តជាក់ស្តែងជាដើម។

លោកជិន ម៉ាលីន បានបញ្ជាក់ថា ៖ «ការវិភាគមួយចំនួននៅកម្ពុជា ដែលក្រុមរបស់គេបញ្ចោរនិងលើកជើងថាជាអ្នកវិភាគឯករាជ្យនោះ ដោយសារតែបានរិះគន់រដ្ឋាភិបាល គឺមិនមែនជាការវិភាគតាមបែបវិជ្ជាជីវៈនិងមានលក្ខណៈវិទ្យាសាស្ត្រនោះទេ តែជាការវិភាគតាមអារម្មណ៍ ដែលរួមមានការស្រឡាញ់ ការស្អប់ និងគុំនុំគុំគួន រួមជាមួយនិងនិន្នាការនយោបាយផងដែរ ជាដើម»។

អ្នកនាំពាក្យរូបនេះបានបន្ថែមថា កុំធ្វើជាអ្នកវិភាគជោរតាមអ្នកសម្ភាសន៍និងវិទ្យុបរទេសមួយចំនួនដែលមាននិន្នាការនយោបាយប្រឆាំងនឹងរដ្ឋាភិបាលនិងផលប្រយោជន៍ជាតិ ព្រោះថាអ្វីដែលគេចង់បានគឺទស្សនៈរបស់អ្នកវិភាគដែលត្រូវនឹងគោលដៅរបស់គេ ដើម្បីយកទៅអត្ថាធិប្បាយបកស្រាយ ញ្ញេញបញ្ចូលបន្ថែម និងផ្សព្វផ្សាយដើម្បីធ្វើការវាយប្រហារ បន្ទុះបង្អាប់ និងរិះគន់រដ្ឋាភិបាលឱ្យខូចឈ្មោះតែប៉ុណ្ណោះ។

លោកថា៖«ការវិភាគដោយមិនផ្អែកលើវិជ្ជាជីវៈ និងមូលដ្ឋាននៃការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ នឹងអាចប្រឈមនឹងការទទួលខុសត្រូវតាមផ្លូវច្បាប់ ប្រសិនបើការវិភាគនោះប៉ះពាល់និងរំលោភបំពានលើសិទ្ធិសេរីភាពនិងសេចក្តីថ្លៃថ្នូរអ្នកដ៏ទៃ និងបង្កចលាចលប៉ះពាល់ដល់សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ហើយការអនុវត្តច្បាប់លើអំពើល្មើសនេះ មិនមែនជាការគំរាមកំហែងដល់អ្នកវិភាគឡើយ ហើយការវិភាគដែលបំពានច្បាប់ទាំងនេះក៏មិនមែនជាការអនុវត្តសិទ្ធិសេរីភាពនៃការសម្តែងមតិនិងទស្សនៈតាមផ្លូវច្បាប់នៅក្នុងសង្គមប្រជាធិបតេយ្យនោះដែរ»៕

# ទិវាអូហ្សូនពិភពលោកឆ្នាំនេះ ធ្វើឡើងក្រោមប្រធានបទ «ពិធីសារម៉ុងរ៉េអាល់បានជួយ ថែរក្សាយើង ម្ហូបអាហារ និងវ៉ាក់សាំងរបស់យើងឱ្យត្រជាក់»

*អត្ថបទ៖ អមរិទ្ធិ ដានុត*

ទិវាអូហ្សូនពិភពលោកខួបលើកទី៣៦ នៃអនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីកិច្ចការពារស្រទាប់អូហ្សូនឆ្នាំ១៩៨៥ និងខួបលើកទី៣៤ នៃពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូនឆ្នាំ១៩៨៧ ត្រូវបានពិភពលោកប្រារព្ធឡើងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១នេះ។

ទិវាអូហ្សូនពិភពលោក ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៩៥ មក ដើម្បីរំលឹកដល់ថ្ងៃបង្កើតពិធីសារម៉ុងរ៉េអាល់ ក៏ដូចជាអបអរសាទរដល់សមិទ្ធផលនិងវឌ្ឍនភាពជាច្រើនដែលគ្រប់គ្នាបានរួមគ្នាសម្រេចបាន សំដៅឆ្ពោះទៅការពារឱ្យបាននូវស្រទាប់អូហ្សូន។

លោក សាយ សំអាល់ បានលើកឡើងថា ៖ «ខ្ញុំសូមចូលរួម អបអរសាទរយ៉ាងកក់ក្តៅជាមួយបណ្តារដ្ឋាភិបាល និងប្រជាជននៃប្រទេសចំនួន ១៩៨ នៅលើសកលលោក ដែលកំពុងរួមគ្នាប្រារព្ធទិវាអូហ្សូនពិភពលោកឆ្នាំនេះ ក្រោមប្រធានបទ ពិធីសារម៉ុងរ៉េអាល់បានជួយ ថែរក្សាយើង ម្ហូបអាហារ និងវ៉ាក់សាំងរបស់យើងឱ្យត្រជាក់» (Montreal Protocol-Keeping us, our food and vaccines cool)»។




លោកបានបន្ថែមថា ការលើកយកប្រធានបទនេះ គឺដើម្បីបំផុសស្មារតីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានឱ្យយល់ដឹងកាន់តែច្បាស់អំពី សារៈសំខាន់នៃស្រទាប់អូហ្សូនសម្រាប់ជីវិតលើភពផែនដីយើងនេះ និងបន្តចូលរួមឱ្យកាន់តែខ្លាំងក្លា បន្ថែមទៀត សំដៅថែរក្សាការពារស្រទាប់អូហ្សូន និងកាត់បន្ថយការកើនកម្តៅភពផែនដី។

ជាការពិតណាស់ តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ប្រជាជាតិជាច្រើននៅលើពិភពលោករហូតមកដល់ពេលនេះ បានលុបបំបាត់ស្ទើរទាំងស្រុងនូវសារធាតុបំផ្លាញស្រទាប់អូហ្សូនហើយ សង្ឃឹមថា ស្រទាប់អូហ្សូននឹងអាចរួមភ្ជិតមកវិញនៅក្នុងទសវត្សរ៍ឆ្នាំ២០៥០ខាងមុខ។

លោក សាយ សំអាល់ថា ៖ «សារធាតុបំផ្លាញ ស្រទាប់អូហ្សូន ក៏ជាសារធាតុដែលមានសក្តានុពលធ្វើឱ្យកើនកម្តៅខ្ពស់ផងដែរ ដូច្នេះ កិច្ចខិតខំប្រឹងប្រែង របស់មនុស្សជាតិក្នុងការអនុវត្តពិធីសារម៉ុងរ៉េអាល់ ពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយ ការកើនកម្តៅភពផែនដី។ ជាក់ស្តែង ក្នុងចន្លោះឆ្នាំ១៩៩០ ដល់ឆ្នាំ២០១០ ពិភពលោកបានរួមគ្នាកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិកទៅក្នុងបរិយាកាសប្រមាណ១៣៥ ពាន់លានតោន»។

ក្នុងនាមជារដ្ឋភាគីកម្ពុជាបានបញ្ឈប់ការប្រើប្រាស់សារធាតុ ក្លរ៉ូភ្លុយអរ៉ូកាបូន (CFC) ទាំងស្រុងក្នុងឆ្នាំ២០១០ ហើយក៏កំពុងបន្តអនុវត្តផែនការគ្រប់គ្រងសារធាតុហាយដ្រូក្លរ៉ូភ្លុយអរ៉ូកាបូន (HCFC) ស្របតាមកាតព្វកិច្ចដែលមានចែងក្នុងពិធីសារម៉ុងរ៉េអាល់។

សារលិខិតដដែលនេះបានលើកឡើងដែរថា ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាក៏កំពុងត្រៀមរៀបចំផែនការគ្រប់គ្រងសារធាតុហាយដ្រូភ្លុយអរ៉ូកាបូន (HFCs) ក្នុងការអនុវត្តវិសោធនកម្ម ទីក្រុងគីហ្គាលីនៃពិធីសារម៉ុងរ៉េអាល់ ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ក្នុងក្តីសង្ឃឹមថា ការកើនកម្តៅភពផែនដីអាចត្រូវបានកាត់បន្ថយរហូតដល់ ០,៥°C នៅចុងសតវត្សរ៍នេះ តាមរយៈការត្រួតពិនិត្យ និងកាត់បន្ថយការប្រើប្រាស់សារធាតុ HFCs នេះ។

> «សារធាតុបំផ្លាញ ស្រទាប់អូហ្សូន ក៏ជាសារធាតុដែលមានសក្តានុពលធ្វើឱ្យកើនកម្តៅខ្ពស់ផងដែរ ដូច្នេះកិច្ចខិតខំប្រឹងប្រែង របស់មនុស្សជាតិក្នុងការអនុវត្តពិធីសារម៉ុងរ៉េអាល់ ពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយ ការកើនកម្តៅភពផែនដី។»

លោក សាយ សំអាល់បានបញ្ជាក់ថា ៖ «កម្ពុជាប្តេជ្ញាបន្តចូលរួមជាមួយសហគមន៍អន្តរជាតិ ក្នុងការអនុវត្តឱ្យបានជោគជ័យនូវរាល់កាតព្វកិច្ចរបស់ខ្លួន សំដៅជានា ឱ្យបាននូវប្រសិទ្ធភាពនៃការកាត់បន្ថយ និងការលុបបំបាត់ការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុដែលមានសក្តានុពលធ្វើឱ្យកើនកម្តៅខ្ពស់»។

លោកថា កម្ពុជាបាននិងកំពុងអនុវត្តផែនការគ្រប់គ្រង សារធាតុហាយដ្រូក្លរ៉ូភ្លុយអរ៉ូកាបូន (HCFC Phase-out Management Plan) ក្នុងនោះដំណោះស្រាយប្រសិទ្ធភាពថាមពលក្នុងការប្រើប្រាស់ឧបករណ៍ត្រជាក់ដែលមានសក្តានុពលកម្តៅសកលទាប ឬសូន្យត្រូវបានគេរំពឹងថានឹងផ្តល់នូវអត្ថប្រយោជន៍ដល់សេដ្ឋកិច្ច ព្រមទាំងសុខភាពមនុស្ស និងសន្តិសុខថាមពលផងដែរ។



# កំណត់ត្រារូបភាពដំបូងបង្អស់នៃការរស់រានបន្តពូជរបស់សត្វ ក្រពើភ្នំ និងហ្វូងកូនទើបញ្ញាស់ ត្រូវបានបង្ហាញជាផ្លូវការ

*អត្ថបទ៖ ផល សុផានិត*

ស្ថិតនៅក្រោមលក្ខខណ្ឌ អាកាសធាតុដ៏លំបាក និងមានការអត់ធ្មត់ខ្ពស់ ការរកឃើញថ្មីត្រូវបានធ្វើឡើងនៅកន្លែងមួយដែលមានលាមក និងស្នាមជើងក្រពើភ្នំ ត្រូវបានប្រមូលនៅរដូវប្រាំងឆ្នាំនេះ។ កូនសត្វល្មូនបច្ចុប្បន្ននេះនៅតែមានសុវត្ថិភាព នៅក្នុងជម្រកសត្វព្រៃ របស់ពួកគេក្រោមការការពារយ៉ាងម៉ឺងម៉ាត់ពីសំណាក់អនុរក្សនៃដែនជម្រកសត្វព្រៃស្រែពក ខេត្តមណ្ឌលគិរី។

ក្នុងរដូវបង្កាត់ពូជនេះ ក្រុមស្រាវជ្រាវបានធ្វើការត្រួតពិនិត្យជាប្រចាំ ហើយសម្រាប់ដំណើរពិសេសនេះក្រុមអ្នកវិទ្យាសាស្ត្រ បានចំណាយពេល ៤ យប់ ដើម្បីតាមដានទីតាំងជម្រកសត្វក្រពើ ចាប់ពីម៉ោង ៧ យប់រហូតដល់ពាក់កណ្តាលអធ្រាត្រម៉ោងប្រហែល ២ រំលងអធ្រាត្រដើម្បីសង្កេតមើលសត្វនេះ។

លោក ប៊ុន សុធា ជាសមាជិកក្រុមស្រាវជ្រាវម្នាក់ បានបង្ហាញទឹកមុខញញឹម នៅលើមុខរបស់គាត់ បានថ្លែងថា ៖ «ពេលនោះពេលវេលាដ៏គួរឱ្យរំភើប បានកើតឡើងនៅពេលដែលក្រុមរបស់យើងមួយក្រុមបានប្រទះឃើញពន្លឺចែងចាំងនៃកូនក្រពើ» ។

របកគំហើញនេះបង្កើតបានជាភស្តុតាងរូបថតដំបូង នៃចំនួនសត្វក្រពើភ្នំ បន្ទាប់ពីការខិតខំស្រាវជ្រាវអស់រយៈពេលជាងមួយទសវត្សរ៍ នៅក្នុងដែនជម្រកសត្វព្រៃស្រែពក ដែលជាតំបន់អភិរក្សស្ថិតនៅក្នុងតំបន់ទេសភាពវាលទំនាបខាងកើតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និងការគាំទ្ររបស់អង្គការមូលនិធិសកលសម្រាប់ធនធានធម្មជាតិ (WWF)។

កិច្ចសហប្រតិបត្តិការអភិរក្សរវាង ក្រសួងបរិស្ថាន អង្គការ WWF ដៃគូអង្គការក្រៅរដ្ឋាភិបាលជាពិសេសសមាជិកទាំងអស់ របស់ក្រសួងនិងក្រុមការងារស្រាវជ្រាវ របស់អង្គការ WWF ដែលកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេត្រូវបានបញ្ចប់ជាមួយ នឹងការបញ្ជាក់ជាផ្លូវការលើកដំបូងនេះ។

លោក សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានមានប្រសាសន៍ថា ការរកឃើញនេះបង្ហាញពីសារៈសំខាន់នៃតំបន់វាលខ្សាច់ស្រែពក ដែលជាចំណុចក្តៅសកល និងមានសក្តានុពលខ្ពស់ក្នុងការបញ្ច្រាសការបាត់បង់ជីវចម្រុះ និងសម្រាប់ការស្តារឡើងវិញនូវ សត្វព្រៃសំខាន់ៗទូទាំងពិភពលោក។

លោក សាយ សំអាល់ បន្តថា ៖« ដំណឹងដ៏គួរឱ្យរំភើបនេះក៏បង្ហាញពីសារៈសំខាន់ នៃព្រះរាជាណាចក្រកម្ពុជាចំពោះការអភិរក្សសត្វក្រពើ ដ៏កម្រនិងប្រភេទសត្វសំខាន់ៗដទៃទៀត។ ប្រទេសកម្ពុជាគឺជាប្រទេសដែលមានធនធានធម្មជាតិ តែមួយគត់ដែលតំណាង ឱ្យប្រភពពិតនៃមោទនភាពជាតិ សម្រាប់ប្រជាជនកម្ពុជាទាំងអស់។ សូមអរគុណចំពោះសន្តិភាពពេញលេញនៅក្នុងប្រទេសកម្ពុជាយើង រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍មកពីគ្រប់វិស័យ ចូលរួមដំណោះស្រាយដែលអាចធ្វើទៅបានក្នុងការគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិ ដោយសង្ឃឹមថា នឹងស្តារជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី របស់ប្រទេសឱ្យមានសក្តានុពលឡើងវិញ»។

លោកស្រី Milou Groenenberg ប្រធានផ្នែកស្រាវជ្រាវ និងឃ្លាំមើលជីវៈចម្រុះ របស់អង្គការ WWF ការអភិវឌ្ឍន៍ នេះត្រូវបានចាត់ទុកថា ជារបកគំហើញនៃការសិក្សាអំពី ប្រភេទសត្វនៅស្រែពក ដោយសារ របាយការណ៍ចាស់ នៃការបង្កាត់ពូជ មានរបាយការណ៍កាលពីច្រើនឆ្នាំមុនដែលមិនបានបញ្ជាក់ ហើយមិនធ្លាប់មានពីមុនជាភស្តុតាងរូបថតនៃការភ្ញាស់កូនក្រពើភ្នំ ។

> **ការការពារជម្រកចំណីអាហារ និងទឹកដែលផ្តល់ដោយធម្មជាតិ អំណោយផល ដល់ក្រពើភ្នំនិង ប្រភេទសត្វដទៃទៀតដែលដើរ នៅតំបន់វាលរហោស្ថាន**

លោកស្រី Milou Groenenberg បានមានប្រសាសន៍ថា ៖« កាលពីមុនយើងមិនច្បាស់ទេថា តើក្រពើភ្នំដែលមានទីលំនៅនៅទីនោះ មានគូបង្កាត់ពូជ ឬក៏មិនមានសំបុកណាមួយ ហើយមិនបានដឹងថាបានញាស់ដោយជោគជ័យឬអត់?»

លោកស្រី Milou Groenenberg បានបន្ថែមថា ៖« ការរកឃើញនៅតំបន់ស្រែពក ពិតជាបង្កើនក្តីសង្ឃឹមសម្រាប់ការអភិរក្សក្រពើភ្នំ និងការរស់រានមានជីវិតនៅក្នុងព្រៃ ហើយជាការរកឃើញដ៏សំខាន់សម្រាប់ប្រភេទសត្វនៅកម្ពុជា និងនៅទូទាំងពិភពលោក» ។

ក្រពើភ្នំទឹកសាប ធ្លាប់មានវត្តមាន ពាសពេញអាស៊ីអាគ្នេយ៍ ប៉ុន្តែបានបាត់ពីខ្លួន នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ។ ប្រទេសកម្ពុជាគឺជាទីជម្រករបស់សត្វក្រពើភ្នំ ដោយមានការប៉ាន់ប្រមាណថាមានសត្វក្រពើភ្នំ ពី ២០០-៤០០ ក្បាលដែលនៅសល់នៅក្នុងព្រៃ។ ការគំរាមកំហែងសំខាន់ៗដែលក្រពើភ្នំ ប្រឈមមុខគឺការបាត់បង់ទីជម្រក និងការរិចរិលការបរបាញ់ ដោយការជួញដូរសត្វព្រៃខុសច្បាប់ និងពីមុនដើម្បីផ្គត់ផ្គង់កសិដ្ឋានចិញ្ចឹមក្រពើភ្នំ ការបង្កាត់ពូជជាមួយប្រភេទសត្វក្រពើដទៃទៀត ទំនប់វារីអគ្គីសនី និងនេសាទខុសច្បាប់ដែលបំផ្លាញ។

ការរស់រានមានជីវិត និងការការពារកូនក្រពើវ័យក្មេង និងជម្ររបស់ពួកគេត្រូវបានធានាដោយការខិតខំប្រឹងប្រែងអនុវត្តច្បាប់យ៉ាងតឹងរ៉ឹង នៅក្នុងទេសភាពក៏ដូចជាការចូលរួមរបស់សហគមន៍ និងការគាំទ្រការចិញ្ចឹមជីវិតនៅក្នុងភូមិជុំវិញដែលបានធ្វើឡើង ជាផ្នែកមួយនៃភាពជាដៃគូយុទ្ធសាស្ត្រនិងរយៈពេលវែង រវាងក្រសួងបរិស្ថាននិងអង្គការ WWF។

លោកសេង ទៀក នាយកប្រចាំប្រទេសអង្គការ WWF បានបន្ថែមថា ៖«ខ្ញុំសូមអបអរសាទរចំពោះការស្រាវជ្រាវ និងអនុរក្សអនុវត្តច្បាប់នៅលើដីចំពោះការរកឃើញដ៏អស្ចារ្យនេះ លទ្ធផលនេះនឹងមិនអាចទៅរួចទេ បើគ្មានការប្តេជ្ញាចិត្តដ៏មោះមុតនិងឥតឈប់ឈររបស់ពួកគាត់។ កិច្ចខិតខំប្រឹងប្រែងអភិរក្សត្រូវតែ ពង្រឹងដោយត្រូវការដំណោះស្រាយសមស្រប និងប្រកបដោយភាពច្នៃប្រឌិត ចំពោះការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការការពារសត្វព្រៃព្រមទាំងអំពាវនាវឱ្យមានវិធីល្អប្រសើរជាងមុន ក្នុងការគ្រប់គ្រងការប្រើប្រាស់និងការចែករំលែកធនធានធម្មជាតិ»។

លោកបានបន្ថែមថា៖ «របកគំហើញនេះបង្ហាញថាការស្តារឡើងវិញ នូវទេសភាពវាលទំនាបខាងកើតគឺអាចធ្វើទៅបាននៅពេល ដែលយើងធ្វើការរួមគ្នា ដើម្បីអនុញ្ញាតឱ្យមានលក្ខខណ្ឌចាំបាច់ទាំងអស់។ ការការពារជម្រកចំណីអាហារ និងទឹកដែលផ្តល់ដោយធម្មជាតិអំណោយផលដល់ក្រពើភ្នំនិងប្រភេទសត្វដទៃទៀតដែលដើរនៅតំបន់វាលរហោស្ថាន» ។

ក្រសួងបរិស្ថាននិងអង្គការ WWF នឹងបន្តតាមដានចំនួនសត្វក្រពើភ្នំស្រែពក និងការពារជម្រកសត្វពីការរំលោភបំពាន និងសកម្មភាពខុសច្បាប់តាមរយៈ ការល្បាតតាមទូក និងថ្មើរជើងជាប្រចាំទាំង ក្នុងនិងក្រៅតំបន់ការពារ។









# កុមារកម្ពុជាប្រឈមនឹងវិបត្តិរបបអាហារមិនគ្រប់គ្រាន់

*អត្ថបទ៖ ផល សុផានិត*



កុមារកម្ពុជាដែលមានអាយុក្រោម ២ ឆ្នាំមិនទទួលបានអាហារ ឬសារជាតុចិញ្ចឹមដែលពួកគេត្រូវការដើម្បីលូតលាស់ដែលនាំអោយប៉ះពាល់ដល់ការអភិវឌ្ឍ។ នេះបើតាមរបាយការណ៍ថ្មីមួយរបស់អង្គការ UNICEF នៅថ្ងៃទី ២២ ខែកញ្ញានេះ។

«Fed to Fail? វិបត្តិនៃរបបអាហាររបស់កុមារនៅវ័យដំបូងនៃការលូតលាស់» ដែលត្រូវបានចេញផ្សាយមុនកិច្ចប្រជុំកំពូលប្រព័ន្ធស្បៀងអាហាររបស់អង្គការសហប្រជាជាតិនៅសប្តាហ៍នេះ ដោយបានព្រមានថា ការកើនឡើងនៃភាពក្រីក្រ វិសមភាព ជម្លោះ គ្រោះមហន្តរាយធាតុអាកាសធាតុ និងភាពអាសន្ននៃសុខភាពដូចជាជំងឺរាតត្បាតកូវីដ-១៩ រួមចំណែកដល់វិបត្តិអាហារូបត្ថម្ភដែលកំពុងបន្តមាន។

នៅប្រទេសកម្ពុជា កុមារម្នាក់ក្នុងចំណោមបីនាក់មានជំងឺក្រិន ហើយម្នាក់ក្នុងចំណោម ១០ នាក់មានសភាពស្គមស្គាំង ខណៈដែលរបាយការណ៍បានកត់សម្គាល់ថា នៅទូទាំងពិភពលោកមានតែកុមារម្នាក់ក្នុងចំណោមបីនាក់ប៉ុណ្ណោះ ដែលត្រូវបានផ្តល់របបអាហារចម្រុះគ្រប់គ្រាន់ដើម្បីលូតលាស់បានល្អនៅពេលផ្លាស់ប្តូរទទួលទានរបបអាហាររឹង។

លោក Foroogh Foyouzat តំណាងអង្គការ UNICEF ប្រចាំនៅកម្ពុជាបាននិយាយថា ៖« ក្នុងនាមជាភ្នាក់ងាររបស់អង្គការសហប្រជាជាតិធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា យើងសូមកោតសរសើរការពង្រីកកម្មវិធីផ្ទេរសាច់ប្រាក់ ដើម្បីកាត់បន្ថយការលំបាកជាពិសេសសម្រាប់អាហារូបត្ថម្ភមាតានិងទារក»។

របាយការណ៍នេះបានរកឃើញថា ៤០% នៃកុមារកម្ពុជាពី ៦ ខែដល់ ២៣ ខែទទួលបានចំនួនក្រុមអាហារអប្បបរមា ប៉ុន្តែជិតពីរភាគបីនៃកុមារទាំងនោះគឺមកពីក្រុមផ្សេងទៀត ។

លោក Foyouzat បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយថា ៖« ឥឡូវនេះយើងត្រូវវិនិយោគលើការគាំទ្រយូរអង្វែងសម្រាប់រយៈពេលមួយពាន់ថ្ងៃដំបូងនៃជីវិតរបស់កុមារ»។

កង្វះអាហារូបត្ថម្ភក្នុងរយៈពេលពីរឆ្នាំដំបូងនៃជីវិត អាចប៉ះពាល់ដល់រាងកាយនិងខួរក្បាលដែលកំពុងលូតលាស់យ៉ាងឆាប់រហ័សរបស់កុមារ «ការវិនិយោគបែបនេះក៏រួមចំណែកដល់ការទទួលបានការអប់រំ និងផលិតភាពរបស់កុមារម្នាក់ៗ ពេញមួយជីវិតរបស់ពួកគេ។ ការកើនឡើងនូវថវិកាជាតិជាតម្រូវការសម្រាប់ការបង្កើនកម្មវិធីអាហារូបត្ថម្ភ» ។

> យើងដឹងរឿងនេះអស់ជាច្រើនឆ្នាំមកហើយ នៅតែមានការរីកចម្រើនតិចតួចលើការផ្តល់អាហារដែលមានជីវជាតិនិងសុវត្ថិភាពត្រឹមត្រូវសម្រាប់កុមារ។ ជាការពិត វិបត្តិជំងឺកូវីដ-១៩ កំពុងបន្តធ្វើអោយស្ថានការណ៍កាន់តែអាក្រក់ទៅ





អង្គការUNICEFបាននិយាយថា របបអាហារក្នុងចំណោមកុមារនៅលើពិភពលោកបានបង្ហាញសញ្ញាតិចតួចនៃការប្រសើរឡើងក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះជាមួយកុមារអាយុក្រោម ២ ឆ្នាំដែលងាយរងគ្រោះបំផុតចំពោះកង្វះអាហារូបត្ថម្ភគ្រប់ទម្រង់ ដូចជាក្រិន ស្គមស្គាំង និងកង្វះសារជាតុចិញ្ចឹមដែលជាលទ្ធផលនៃរបបអាហារមិនល្អ។

របាយការណ៍បាននិយាយផងដែរថា ចំណេះដឹងទាបនៃអាហាររូបត្ថម្ភ និងទីផ្សារទឹកគោដែលមានតម្លៃខ្ពស់ រួមចំណែកដល់ភាពចម្រុះនៃរបបអាហារទាបសម្រាប់កុមារ និងការកាត់បន្ថយការបំបៅដោះកូន។ ការកាត់បន្ថយប្រាក់ឈ្នួលនាពេលថ្មីៗនេះចំពេលមានជំងឺរាតត្បាត បានធ្វើអោយបញ្ហាដែលមានស្រាប់ទាំងនេះកាន់តែមានសភាពធ្ងន់ធ្ងរ។

លោក Henrietta Fore នាយកប្រតិបត្តិអង្គការ UNICEF បាននិយាយថា ៖« នៅពេលដែលមានឧបសគ្គកាន់តែខ្ពស់ ការផ្តល់របបអាហារអោយកុមារតូចៗរាប់លាននាក់ត្រូវបរាជ័យ»។

លោក Henrietta Fore បន្តថា៖ «ការទទួលទានសារជាតុចិញ្ចឹមមិនគ្រប់គ្រាន់ក្នុងរយៈពេលពីរឆ្នាំ ដំបូងនៃជីវិតអាចធ្វើអោយប៉ះពាល់ដល់រាងកាយនិងខួរក្បាលដែលកំពុងលូតលាស់យ៉ាងឆាប់រហ័សរបស់កុមារដែលអាចជះឥទ្ធិពលដល់ការសិក្សា អនាគតការងារ និងអនាគតរបស់ពួកគេ»។

លោក Henrietta Fore គូសបញ្ជាក់ថា៖ «ខណៈពេលដែលយើងដឹងរឿងនេះអស់ជាច្រើនឆ្នាំមកហើយ នៅតែមានការរីកចម្រើនតិចតួចលើការផ្តល់អាហារដែលមានជីវជាតិនិងសុវត្ថិភាពត្រឹមត្រូវសម្រាប់កុមារ។ ជាការពិត វិបត្តិជំងឺកូវីដ-១៩ កំពុងបន្តធ្វើអោយស្ថានការណ៍កាន់តែអាក្រក់ទៅ»។

នៅក្នុងការវិភាគលើប្រទេសចំនួន ៩១ របាយការណ៍បានរកឃើញថាមានតែពាក់កណ្តាលនៃកុមារដែលមានអាយុពី ៦ ខែដល់ ២៣ ខែប៉ុណ្ណោះដែលត្រូវបានគេផ្តល់អាហារអប្បបរមាដែលត្រូវបានណែនាំជារៀងរាល់ថ្ងៃ ខណៈមានតែមួយភាគបីបានទទួលទានក្រុមអាហារអប្បបរមាដែលពួកគេត្រូវការដើម្បីលូតលាស់៕



# យុវជនអាស៊ានបញ្ចេញសំឡេងតែមួយអំពីលទ្ធិប្រជាធិបតេយ្យនៅក្នុងតំបន់

*អត្ថបទ៖ អរិយបុត្រ*

ស្របពេលដែលពិភពលោកនាំគ្នារំលឹកដល់ទិវាអន្តរជាតិនៃលទ្ធិប្រជាធិបតេយ្យ អង្គការវេទិកាយុវជនអាស៊ាន (AYF) ដែលជាក្រុមសង្គមស៊ីវិលយុវជនតំបន់មួយ បានចេញសេចក្ដីថ្លែងការណ៍រួមដែលតំណាងឲ្យយុវជននៅក្នុងតំបន់ ដោយរួមបញ្ចូលអនុសាសន៍យុវជនជុំវិញបញ្ហា ចំនួន ៧ សម្រាប់រដ្ឋាភិបាលអាស៊ាន មេដឹកនាំសង្គមស៊ីវិល និងយុវជនក្នុងតំបន់ដើម្បីធ្វើសកម្មភាព។

សេចក្ដីថ្លែងការណ៍នេះត្រូវបានបញ្ចេញក្នុងកិច្ចសន្ទនាជាសាធារណៈដែលត្រូវបានរៀបចំឡើងដោយ វេទិ កាយុវជនអាស៊ាន និងគាំទ្រដោយក្រុមប្រឹក្សាយុវជនអាមេរិក-អាស៊ាននិងអង្គការបណ្ដាញប្រជាធិបតេយ្យអាស៊ី ។

កិច្ចពិភាក្សាជាសាធារណៈនេះក៏មានការរៀបចំការពិភាក្សាពីសមាជិកនៃអង្គការនីមួយៗផងដែរ។

សេចក្ដីថ្លែងការណ៍បានគូសបញ្ជាក់ពីអនុសាសន៍ដែលជារឿយៗត្រូវបានគេមើលរំលងលើបញ្ហាសំខាន់ៗដូចជាសន្តិភាព, នយោបាយ, លទ្ធិប្រជាធិបតេយ្យ, សិទ្ធិនៅក្នុងការទទួលបានការងារសមរម្យ, ការអប់រំផ្លូវភេទនិងការទទួលបានសិទ្ធិលើផ្នែកសុខភាពបន្តពូជ, សេរីភាពក្នុងការបញ្ចេញមតិនិងសិទ្ធិទទួលបានព័ត៌មាន, សិទ្ធិជនចំណាកស្រុក, និងការទទួលបាននូវការពារគ្រាអាសន្នដែលកើតមានឡើងដោយសារតែបម្រែបម្រួលអាកាសធាតុ។

សេចក្ដីថ្លែងការទាំងនេះត្រូវបានធ្វើដោយមានការយល់ព្រមដោយទទួច ពីយុវជនចំនួន ៣០០ នាក់ដែលពួកគេបានចូលរួម ក្នុងអំឡុងពេលមហោស្រពយុវជនអាស៊ាន ( SEAYouth) ប្រចាំឆ្នាំលើកទី ២ របស់ វេទិកាយុវជនអាស៊ានដែលបានរៀបចំឡើងកាលពីពេលថ្មីៗកន្លងទៅដើម្បីរំលឹកដល់ទិវាយុវជនអន្តរជាតិនិងទិវាមនុស្សធម៌ពិភពលោក។

បន្ទាប់ពីការបញ្ចប់ការរៀបចំនៃមហោស្រពយុវជនអាស៊ាននេះរួចមក អនុសាសន៍ទាំងនេះត្រូវបានប្រចាប់បញ្ចូលទៅក្នុងសេចក្ដីថ្លែងការណ៍របស់ វេទិកាយុវជនអាស៊ាន ដោយមានជំនួយពីសមាជិកបួននាក់នៃក្រុមពង្រាងសម្រាប់កិច្ចការយុវជនមកពីបណ្ដាប្រទេសអាស៊ីអាគ្នេយ៍។

លោក ហ្វាទីម៉ា ហ្សារ៉ា ( Fatimah Zah-rah ) អ្នកសម្របសម្រួលប្រចាំតំបន់របស់វេទិកាយុវជនអាស៊ាន បាននិយាយថា៖ «យើងប្រមូលផ្ដុំខ្លួនយើងដើម្បីទាមទារលំហនិងការនិទានកថាដើម្បីសម្រេចក្ដីសុបិន្តរបស់យើង ដើម្បីឱ្យតំបន់នេះក្លាយជា មជ្ឈមណ្ឌលមនុស្សកាន់តែច្រើន និងជាកន្លែងរួមបញ្ចូលគ្នាសម្រាប់មនុស្សគ្រប់គ្នា»។

លោកបានថ្លែងថា សេចក្ដីថ្លែងការណ៍របស់យុវជនជានិមិត្តរូបនៃការព្រួយបារម្ភរួមនិងការតស៊ូមតិរបស់យើងដើម្បីចូលរួមជះឥទ្ធិពលដល់ដំណើរការបង្កើតគោលនយោបាយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

យុវជន ង្វៀន ឌីញឌឹក (Nguyen Dinh Duc) តំណាងយុវជនមកពីប្រទេសវៀតណាមដែលជាសមាជិកមួយរូបនៃក្រុមរៀបចំសេចក្ដីព្រាងសេចក្ដីថ្លែងការណ៍នេះបាននិយាយថា តាមរយៈសេចក្ដីព្រាងសេចក្ដីថ្លែងការណ៍ខ្ញុំបានសង្កេតឃើញថាយុវជនអាស៊ីអាគ្នេយ៍មានការយល់ដឹងអំពីគំនិតល្អ ៗ ទាក់ទងនឹងសិទ្ធិមនុស្សការអត់ឱននិងការរួមបញ្ចូលគ្នា។ យើងមិននិយាយភាសាដូចគ្នាទេប៉ុន្តែយើងចែករំលែកគំនិតនិងទស្សនៈដូចគ្នា ។

យុវជន ស្រ៊ូទី ឌូបេ (Shruti Dubey) សមាជិកក្រុមពង្រាងមកពីប្រទេសថៃបាននិយាយ ដំណើរ ការនៃការប្រមូលផ្ដុំនិងការចងក្រង នូវសំណូមពររបស់យុវជនមកពីសហគមន៍អាស៊ាននេះ គឺដើម្បីធ្វើឱ្យប្រសើរឡើង និងជាការធានានូវសិទ្ធិជាមូលដ្ឋានរបស់យើងចំពោះសេរីភាពការគោរពលទ្ធិប្រជាធិបតេយ្យនិងអ្វីៗជាច្រើនទៀត តែនេះមិនជាការបំផុសគំនិតសម្រាប់ខ្ញុំទេជាពិសេសដោយសារវាបង្ហាញពីក្ដីសង្ឃឹមនាពេលអនាគតរបស់យើង។

សមាជិកក្រុមរៀបចំសេចក្ដីព្រាងមួយរូបទៀត គឺ យុវជន រីឌូ មូឡាណា ឌៀហ្គានតារ៉ា ( Ridho Maulana Dirgantara) មកពីប្រទេសឥណ្ឌូនេស៊ីបានលើកឡើងថា «ខ្ញុំដឹងថានៅម្ខាងនៃយុវជនពិតជាខ្វល់ខ្វាយអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងតំបន់អាស៊ាន។ ពួកគេកំពុងព្យាយាមតាមវិធីសាស្ត្រផ្សេងៗដើម្បីដោះស្រាយនិងរួមចំណែកក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត។ ម្យ៉ាងវិញទៀតវាបង្ហាញយ៉ាងល្អិតល្អន់ថារដ្ឋាភិបាលអាស៊ានពិតជាមិនបានប្រើប្រាស់សក្ដានុពលឬសម្លេងរបស់យុវជនឡើយដូច្នេះសេចក្ដីថ្លែងការណ៍នេះគឺជាការរំលឹកសម្រាប់ពួកគេក្នុងការបង្កើនការចូលរួមរបស់យុវជនក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្តជាពិសេសយុវជននឹងក្លាយជាអ្នកបន្តវេន»។

លោក ខាន ខាន (Khant Khant) សមាជិកក្រុមរៀបចំសេចក្ដីព្រាងមកពីប្រទេសមីយ៉ាន់ម៉ាបាននិយាយថា៖ «យើងជំរុញឱ្យមេដឹកនាំអាស៊ានដាក់ទណ្ឌកម្ម ដើម្បីការពារការបាត់បង់ជីវិតជនស៊ីវិលបន្ថែមទៀតនិងអនុវត្តកម្មវិធីជំនួយមនុស្សធម៌ដល់អ្នកដែលត្រូវការឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ លើសពីនេះទៀតចំពោះមិត្តភក្តិអន្តរជាតិទាំងអស់យើងចង់ឱ្យអ្នកឈរដោយសាមគ្គីភាពជាមួយមិត្តភក្តិមកពីប្រទេសជាសមាជិកអាស៊ានមួយចំនួនដែលកំពុងតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យរបស់ពួកគេ។ សូមគាំទ្រពួកគេនិងសេចក្ដីប្រាថ្នារបស់ពួកគេចំពោះលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស» ។

លោកស្រី ខារ៉ែល ជៀអាន អេនតូនីញ៉ូ ហ្គាឡាង (Karel Jiaan Antonio Galang) អ្នកសម្របសម្រួលនៃអង្គការ បណ្ដាញប្រជាធិបតេយ្យអាស៊ីបាននិយាយថា «សិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យមានទំនាក់ទំនងគ្នា។ លទ្ធិប្រជាធិបតេយ្យនឹងការពារសិទ្ធិមនុស្សហើយសិទ្ធិមនុស្សគឺជាតម្រូវការមូលដ្ឋានសម្រាប់លទ្ធិប្រជាធិបតេយ្យ»។

យុវនារី គង់ វណ្ណារី មកពីក្រុមប្រឹក្សាយុវជនអាមេរិក-អាស៊ានបាននិយាយថា «តាមប្រវត្តិសាស្ត្រយុវជនដែលចូលរួមក្នុងសង្គមបានបង្ហាញថាជាកម្លាំងដ៏ខ្លាំងក្លាសម្រាប់ការផ្លាស់ប្ដូរ។ យើងបានឃើញចលនាយុវជនដឹកនាំដោយជោគជ័យទទួលបានការចាប់អារម្មណ៍ពីអន្តរជាតិនិងការប្រកួតប្រជែងដែលបង្កើតឡើងនៅក្នុងអង្គការនិងស្ថាប័នឯកជននិងមិនរកប្រាក់ចំណេញសាធារណៈ។ ការវែកញែកខាងសីលធម៌នៃការចូលរួមរបស់យុវជននិងការចូលរួមរបស់ពលរដ្ឋគឺជាការសង្កត់ធ្ងន់ដ៏មានតម្លៃពីព្រោះពួកគេអាចនាំឱ្យមានលទ្ធផលសង្គមវិជ្ជមានដែលមានអត្ថប្រយោជន៍រយៈពេលវែង»។

សេចក្ដីថ្លែងការណ៍រួមរបស់យុវជនត្រូវបានគាំទ្រដោយបុគ្គល ២០៨ នាក់និងអង្គការចំនួន ៣២ ។ ការចេញនូវឯកសារដ៏សំខាន់នេះតំណាងឱ្យនិមិត្តរូបនៃការប្រមូលផ្ដុំយុវជនក្នុងការធ្វើប្រជាធិបតេយ្យភាវូបនីយកម្មនៅអាស៊ីអាគ្នេយ៍ និងជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់យុវជនក្នុងការដណ្ដើមយកកន្លែងរបស់ពួកគេនៅក្នុងដំណើរការបង្កើតគោលនយោបាយដើម្បីធានាបាននូវការរួមបញ្ចូលដោយផ្ដោតលើប្រជាជនផ្ដោតលើយេនឌ័រនិង សហគមន៍នៅ អាស៊ីអាគ្នេយ៍៕

# ការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា នឹងសម្រាលបន្ទុកដល់អាជីវករ និងប្រជាជនដែលរងផលប៉ះពាល់ដោយជំងឺកូវីដ១៩

*អត្ថបទ៖ ផល សុផានិត*

មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានវាយតម្លៃពីសុទិដ្ឋិនិយមនៃការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា ដែលនឹងជួយសម្រាលបន្ទុកដល់អាជីវករ និងប្រជាជនដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ ។

ការលើកឡើងរបស់ IMF ធ្វើឡើងក្នុងឱកាសដែលលោក ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឱ្យ លោក Yasuhisa Ojima តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ ប្រចាំប្រទេសកម្ពុជា ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារនៅធនាគារជាតិនៃកម្ពុជានាពេលកន្លងមកនេះ។

ក្នុងនោះ IMF បានបង្ហាញលទ្ធផលនៃការវាយតម្លៃថា នឹងមានការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា និងបានវាយតម្លៃខ្ពស់ ចំពោះវិធានការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ១៩ និងចំពោះវិធានការរបស់ធនាគារជាតិនៃកម្ពុជា ដែលបានដាក់ចេញក្នុងការ រួមចំណែកដល់កំណើនសេដ្ឋកិច្ច និងសម្រាលបន្ទុកដល់អាជីវករ និងប្រជាជនក្រីក្រដែលទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ១៩ ។

ក្នុងនាមមូលនិធិរូបិយវត្ថុអន្តរជាតិ លោក Yasuhisa Ojima បានបង្ហាញពីការគាំទ្រចំពោះធនាគារជាតិនៃកម្ពុជា ដើម្បីសម្រេចបានសមិទ្ធផលថ្មីៗនានា របស់ធនាគារជាតិនៃកម្ពុជាបន្ថែមទៀត។

លោក ជា ចាន់តូ ទេសាភិបាលបានថ្លែងអំណរគុណ ដល់ក្រុមបេសកកម្មពិគ្រោះយោបល់មាត្រា IV និងបានថ្លែងអំណរគុណដល់ IMF ដែលបានផ្ដល់អនុសាសន៍សំខាន់ៗ ក្នុងការអនុវត្តវិធានការនានា ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងការឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩ ។

លោកបានវាយតម្លៃខ្ពស់ ចំពោះវត្តមានរបស់ការិយាល័យតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ ប្រចាំប្រទេសកម្ពុជា ដែលបានដើរតួនាទីសំខាន់ ក្នុងការសម្របសម្រួល ដល់ការផ្ដល់ជំនួយបច្ចេកទេស និងការពង្រឹងសមត្ថភាពដល់មន្ត្រីបុគ្គលិកជាដើម។

សូមជម្រាបថា IMF បានព្យាករណ៍សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ២០២១ថា នឹងមានកំណើនខ្ពស់ជាងមុន ក្នុងអត្រា២.២% គាំទ្រដោយនិន្នាការល្អ ជាងការរំពឹងទុក នៃវិស័យកម្មន្តសាល និងវិស័យកសិកម្ម ដែលជំរុញដោយភាពរឹងមាំ នៃតម្រូវការខាងក្រៅ ខណៈវិស័យសំណង់ វិស័យអចលនទ្រព្យ និងវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន រងផលប៉ះទង្គិចដោយសារ «ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ»។



ក្នុងឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករថានឹងបន្តងើបឡើងក្នុងរង្វង់ប្រមាណ៥% ដោយសារការរំពឹងទុក ការបន្តងើបឡើងនៃតម្រូវការសកល, ការបន្តសក្តានុពលកំណើន នៃវិស័យកាត់ដេរ និងវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងការកើនឡើងសន្សឹមៗ នៃវិស័យគាំទ្រផ្សេងទៀត ព្រមទាំងប្រសិទ្ធភាព នៃការដាក់ចេញវិធានការគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស «ផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩»៕

# អាមេរិកបើកការិយាល័យដំបូងរបស់ក្រសួងកសិកម្មនៅកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

សហរដ្ឋអាមេរិកបានបើកការិយាល័យរបស់ក្រសួងកសិកម្ម (USDA)ដំបូងរបស់ខ្លួន នៅកម្ពុជា នៅខែកញ្ញានេះ ដើម្បីទ្រទ្រង់ពាណិជ្ជកម្មទាក់ទងនឹងកសិកម្ម ដែលកំពុងមានកំណើន រវាងប្រទេសទាំងពីរ។ នេះបើយោងតាមសេចក្ដីប្រកាសព័ត៌មានរបស់ស្ថានទូតអាមេរិកប្រចាំកម្ពុជា។





សេចក្ដីប្រកាសបានលើកឡើងថា ថ្វីត្បិតតែការិយាល័យផ្នែកសេវាកម្មជាមួយបរទេសរបស់ក្រសួងកសិកម្មអាមេរិក (USDA) ស្ថិតនៅក្នុងស្ថានទូតអាមេរិកនៅភ្នំពេញមែន ប៉ុន្តែការងាររបស់គេមាននៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីទ្រទ្រង់កិច្ចសហការ និងពាណិជ្ជកម្មទ្វេភាគីផ្នែកកសិកម្ម សម្រាប់ជាផលប្រយោជន៍នៃប្រទេសទាំងពីរ។

លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា W. Patrick Murphy បានឱ្យដឹងថា នៅប្រទេសកម្ពុជា គេចូលចិត្តផលិតផល និងបច្ចេកវិទ្យាកសិកម្មរបស់អាមេរិក ហើយការិយាល័យថ្មីរបស់ USDAនេះ នឹងជំរុញកិច្ចការនេះដើម្បីឲ្យអតិថិជន និងផលិតករកម្ពុជាទទួលបានផលិតផល និងបច្ចេកវិទ្យាទាំងនោះឲ្យបានកាន់តែច្រើន»។






លោកបានមានប្រសាសន៍ថា ៖ «វាជាដំណឹងល្អសម្រាប់ប្រទេសទាំងពីរ ហើយវាក៏បានឆ្លុះបញ្ចាំងឲ្យឃើញអំពីការប្ដេជ្ញាចិត្តយូរអង្វែងរបស់យើង ក្នុងការធ្វើឲ្យប្រជាជនកម្ពុជាទទួលបានទំនិញ និងសេវាប្រកបដោយគុណភាព ពីសហរដ្ឋអាមេរិក»។

ទីផ្សារប្រទេសកម្ពុជាកំពុងមានកំណើន សម្រាប់ទំនិញកសិកម្មនាំចេញរបស់សហរដ្ឋអាមេរិក ដោយក្នុងឆ្នាំ ២០២០ គេលក់បានក្នុងតម្លៃ ៧២,៧ លានដុល្លារ គឺកើន ៤៧៤% នៅក្នុងរយៈពេល ១០ ឆ្នាំមកនេះ។

ការិយាល័យផ្នែកសេវាកម្មជាមួយបរទេសរបស់ USDA ក៏នឹងជួយផងដែរដល់កសិករ និងសិស្សសាលានៅកម្ពុជា ក្នុងទំហំទឹកប្រាក់រាប់សិបលានដុល្លារ តាមរយៈកម្មវិធីជំនួយអភិវឌ្ឍន៍ជាបន្តរបស់ USDA ដូចជាកម្មវិធី McGovern-Dole International Food for Education ដែលផ្ដល់អាហារសម្រាប់កូនសិស្សនៅសាលាបឋមសិក្សា និងកម្មវិធី Food for Progress ដែលលើកកម្ពស់ផលិតភាពកសិកម្មផងដែរ។

ការិយាល័យផ្នែកសេវាកម្មជាមួយបរទេសរបស់ក្រសួងកសិកម្មសហរដ្ឋអាមេរិក (USDA) បានតែងតាំង កញ្ញា ហួយ សុខគា អ្នកឯកទេសខាងកិច្ចការកសិកម្ម ធ្វើជាជាតំណាង។ កន្លងមក សុខគា គឺជាអ្នកឯកទេសពាណិជ្ជកម្មរបស់ស្ថានទូតអាមេរិក នៅភ្នំពេញ ដោយនាងបានជួយក្រុមហ៊ុនអាមេរិកនានា ឲ្យចូលមកបណ្ដាក់ទុនក្នុងទីផ្សារនៃប្រទេសកម្ពុជាផងដែរ៕

# កម្ពុជាទាក់ទាញគម្រោងវិនិយោគ មានតម្លៃ ៣,៣ ពាន់លានដុល្លារ នៅក្នុងរយៈពេល៩ ខែ



*អត្ថបទ៖ អរិយបុត្រ*

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអះអាងថា រយៈពេល ៩ ខែ ដើមឆ្នាំ ២០២១ នេះ កម្ពុជាបានទាក់ទាញគម្រោងវិនិយោគដែលមានតម្លៃប្រមាណជា ៣,៣ ពាន់លានដុល្លារ។ នៅក្នុងរយៈពេលនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានអនុម័តយល់ព្រមលើគម្រោងវិនិយោគសរុបចំនួន ១៣៤ ដែលមានទុនវិនិយោគសរុបចំនួន ៣,៣ ពាន់លានដុល្លារអាមេរិក។

ចំនួនគម្រោងវិនិយោគនៅក្នុងអំឡុងពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២១ នេះ ត្រូវបានគេដឹងថា បានធ្លាក់ចុះ ២៤ ភាគរយបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនហើយទឹកប្រាក់នៃការវិនិយោគសរុបវិញគឺបានធ្លាក់ចុះ ៤៨ ភាគរយ ។

ប្រភពដដែលបានបន្តថា គម្រោងវិនិយោគដែលបានអនុម័តបានបង្កើតការងារនៅក្នុងចំនួន ៨៥.៥៧២ ដោយភាគច្រើន គឺនៅលើគម្រោងរោងចក្រឧស្សាហកម្មកាត់ដេរ ថាមពល រោងចក្រគីមី រោងចក្រលោហៈធាតុ ហើយក៏មានគម្រោងកសិកម្ម ខ្លះផងដែរ ។

ប្រភពដដែលបានបន្តថា ក្នុងចំណោមគម្រោងវិនិយោគទាំងអស់ មានគម្រោងចំនួន ១០១ ដែលមានទឹកប្រាក់ចំនួន ១,៤ ពាន់លានដុល្លារត្រូវបានអ្នកវិនិយោគទុនមកបណ្ដាក់ទុន នៅខាងក្រៅតំបន់សេដ្ឋកិច្ចពិសេស ដោយឡែក សម្រាប់គម្រោងដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសគឺមាន ៣៣ គម្រោងដែលមានទំហំវិនិយោគសរុប ១,៩ ពាន់លានដុល្លារអាមេរិក។

កាលពីឆ្នាំមុន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តគម្រោងវិនិយោគចំនួន ២៣៨ ដែលមានទុនវិនិយោគចំនួន ៨,២ ពាន់លានដុល្លារអាមេរិក។

នៅក្នុងអំឡុងពេលនេះ កម្ពុជាកំពុងតែស្ថិតនៅក្នុងតំណាក់កាលនៃការរីករាលដាលនៃមេរោគកូវីដ ១៩ ដូចនេះអ្នកវិភាគមួយចំនួនបានអះអាងថា នេះគឺជាទិដ្ឋភាពដ៏វិជ្ជមានមួយ ដែលកម្ពុជានៅតែបន្តអាចទាក់ទាញវិនិយោគទុនពីក្រៅប្រទេសបានសម្រាប់ជាជំនួយប៉ះប៉ូវខ្លះ ទៅលើវិស័យសេវាកម្ម និងទេសចរណ៍ដែលកំពុងតែប្រឈមមុខនឹងវិបត្តិដ៏ធ្ងន់ធ្ងរ ខណៈដែលវិស័យនេះ គឺជាប្រភពចំណូលនិងទ្រទ្រង់ជីវភាពពលរដ្ឋប្រមាណជា ២ លាននាក់។

ធនាគារពិភពលោក ថ្មីៗនេះបានអះអាងថា ការនាំចេញរបស់កម្ពុជា ជាពិសេសគឺផលិតផលវាយនភ័ណ្ឌនិងកាត់ដេរ ព្រមទាំងសំភារៈ សម្រាប់ធ្វើដំណើរ គឺមានស្ថានភាពវិជ្ជមាន ដោយទំហំនៃការនាំចេញផលិតផលពីវិស័យនេះ គឺពង្រីកដល់ទៅ ១៧ ភាគរយ នៅក្នុងអំឡុងរយៈពេល ៧ ខែចុងក្រោយ រីឯទំហំនៃការនាំចេញពីវិស័យនេះវិញ គឺមានទំហំប្រមាណជា ៦៣,១ ភាគរយ នៃការនាំចេញ សរុបរបស់កម្ពុជាឡើងវិញ៕

# រដ្ឋមន្ត្រី៖ «ទីផ្សារកសិកម្មកម្ពុជាមាននៅរហូតដល់ទៅ៩០ប្រទេស»

*អត្ថបទ៖ អរិយបុត្រ*







លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងថា ផលិតផលកសិកម្មកម្ពុជានៅក្នុងរយៈពេល ៩ខែ ដើមឆ្នាំ ២០២១ នេះ បាននាំចេញទៅដល់៩០ ប្រទេសនៅលើពិភពលោក ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ បរិមាណនាំចេញធំបំផុត គឺមានតែប្រទេសជិតខាងតែប៉ុណ្ណោះ។

លោកបានអះអាងថា យោងតាមប្រព័ន្ធទិន្នន័យត្រីះភូតគាមអនាម័យជាតិ អគ្គនាយកដ្ឋានកសិកម្ម នៃកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឲ្យដឹងថា ពីខែមករា ដល់ខែកញ្ញា ឆ្នាំ ២០២១ កម្ពុជាបាននាំចេញនៅក្នុងបរិមាណសរុបរហូតដល់ទៅ ៥,៩៣ លានតោន ដែលក្នុងនោះ ការនាំចេញទៅកាន់ ប្រទេសវៀតណាម មានចំនួន ៦៤,១១%, ប្រទេសថៃ មានចំនួន ២១,៤៩% ប្រទេសចិន មានចំនួន ៩,៦៩%, ហើយទៅកាន់គោលដៅប្រទេសចំនួន ៨៧ ផ្សេងទៀតមានចំនួន ៤,៧១% តែប៉ុណ្ណោះ ។

បរិមាណនៃការនាំចេញផលិតផលកសិកម្មកម្ពុជា គឺភាគច្រើនអង្ករ បន្ទាប់មក ចេក ស្វាយ ម្រេច ពោត សណ្តែក ដំឡូងមី ម្ទេស និងថ្នាំជក់ ជាដើម។

យោងតាមរបាយការណ៍បានឲ្យដឹងថា ការនាំចេញកសិផលសរុបក្នុងរយៈពេល៩ខែឆ្នាំ២០២១ មានកំណើនចំនួន ៨៨,៤៨% ក្នុងនោះកសិផលក្រៅពីអង្ករមានការកើនឡើងចំនួន ១០៧,៦៩% រីឯការនាំចេញអង្ករមានការថយចុះចំនួន ១៥,៩៧% ដោយសារកម្ពុជាជួបបញ្ហាប្រឈមនឹងកង្វះប្រភេទទូរកុងតេន័រដែលមានទំហំ២០ហ្វិតសម្រាប់ផ្ទុកអង្ករ និងតម្លៃដឹកជញ្ជូនកើនឡើង។ ដោយឡែក ការប៉ាន់ស្មានតម្លៃនៃការនាំចេញក្នុងរយៈពេល៩ខែឆ្នាំ២០២១ មានទំហំប្រមាណជា ៣.៤៨៩.៧៧៦.៩៩៩ ដុល្លារអាមេរិក ដែលក្នុងនោះ ការនាំចេញអង្ករមានចំនួន ៣៤៩,៩១លានដុល្លារអាមេរិក, ការនាំចេញស្រូវមានចំនួន ៤២៨,៩៥ លាន ដុល្លារអាមេរិក ហើយការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួនជា ២.៧១០ លាន ដុល្លារអាមេរិក។

ប្រភពដដែលបានឲ្យដឹងថា បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន២២ប្រទេស មានបរិមាណសរុបចំនួន ១០៤.២២២តោន ថយចុះចំនួន ៥៧.៣៩២ តោន ស្មើនឹង ៣៥,៥១% ទិសដៅប្រទេសចិន មានបរិមាណសរុបចំនួន ២០៣.២៧៩ តោន កើនឡើងចំនួន ៣១.៣៨៣ តោន ស្មើនឹង ១៨,២៦% ទិសដៅអាស៊ានចំនួន ៧ប្រទេស មានបរិមាណសរុបចំនួន ៤១.៤៧៦ តោនថយចុះចំនួន ២៥.៩៥៧ តោន ស្មើនឹង ៣៨,៤៩% និងទិសដៅដទៃទៀតចំនួន២៣ប្រទេស មានបរិមាណសរុប ៦១.៧២១ តោន ថយចុះចំនួន ២៦.១១១តោន ស្មើនឹង ២៩,៧៣% ។

ក្រុមហ៊ុនដែលបាននាំចេញអង្ករមានចំនួន ៥៩ ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ២៩៩.៥៣៣ តោន ពោលគឺ៧២,៩៤% និងក្រុមហ៊ុន៤៩ដទៃទៀតបាននាំចេញត្រឹមតែ ១១១.១៦៥ តោន ស្មើនឹង២៧,០៦%។

របាយការណ៍នេះបានបន្តថា ការនាំចេញស្រូវមានចំនួន ២.៥២៣.២៦៣ តោន ក្នុងរយៈពេល៩ខែឆ្នាំ២០២១ ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១.៦២៧.៧៤០ តោន) ដែលមានការកើនឡើងចំនួន ៨១,២៣% បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២០ ដែលមានចំនួន ១ ៣៩២.៣០៦ តោន។

ក្នុងរយៈពេល៩ខែ ឆ្នាំ២០២១ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ មានចំនួន ៣.៨៩៤.៤៨៥ តោន កើនឡើងចំនួន ៤៦,៤៧% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ ដែលមានចំនួន ២.៦៥៨.៩១៦ តោន ដែលក្នុងនោះរួមមាន ដំឡូងមីស្រស់ ចំណិតដំឡូងមី ម្សៅដំឡូងមី កាលសំណល់ដំឡូងមី មានបរិមាណសរុបរហូតដល់ទៅ ១,៩១ លានតោន ទៅកាន់ប្រទេស៧ ប្រទេស, គ្រាប់ស្វាយចន្ទីចំនួន ៨៩២.៥៣៥ តោន កើនឡើងចំនួន ៣៣៧,០៧%) ទៅកាន់ជាង ១០ ប្រទេស , គ្រាប់ពោតមានចំនួន ១៥៤.៤៥៩ ថយចុះចំនួន ២០,៣៦% ទៅកាន់ ៥ ប្រទេស គ្រាប់សណ្តែក ៥៣.២៩០ តោន ទៅកាន់ប្រទេសចំនួន ៣ , ផ្លែចេកស្រស់មានចំនួន ៣៤៣.៨១២ តោន កើនឡើងចំនួន ៤៦,២០% នាំចេញទៅប្រទេសចំនួន ៤ , ផ្លែក្រូចថ្លុងមានចំនួន ៣៤.៩១៨,៤៤ តោន កើនឡើងចំនួន ១៣០,៤៨% នាំចេញទៅ២ប្រទេស, ផ្លែស្វាយស្រស់មានចំនួន ១៧២.៨៤៦ តោន កើនឡើងចំនួន ១៧៤,៧១%) នាំចេញទៅប្រទេស ៧ ប្រទេស នៅមានដំណាក់ស្វាយ ទឹកស៊ីរ៉ូស្វាយ ដូងប្រេង ថែមទៀត ។

នៅក្នុងរយៈពេលនេះ កម្ពុជានាំចេញម្រេចចំនួន ២៧.៣១៦ តោន កើនឡើងចំនួន ៥៦២,៧១% ដោយ នាំចេញទៅប្រទេសជាង ២០ ប្រទេស នៅមានម្ទេសស្រស់ ម្ទេសក្រៀម បន្លែ កៅស៊ូ ឈើកែច្នៃ និងសត្វរស់៕

# ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ

# ត្រូវអនុវត្តនូវការគ្រប់គ្រងសំរាមសំណល់រឹង

## ដោយធ្វើការបែងចែក វេចខ្ចប់ និងការបញ្ចេញមកក្រៅ ចាប់ពីខែវិច្ឆិកានេះតទៅ

**ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០២១ តទៅ រាជធានីភ្នំពេញ នឹងធ្វើការកំណែទម្រង់នៃការគ្រប់គ្រងសំរាម និងសំណល់រឹង ដោយតម្រូវឱ្យប្រជាពលរដ្ឋទាំងអស់ត្រូវធ្វើការញែក វេចខ្ចប់ ទុកដាក់ និងបញ្ចេញសំរាមសំណល់រឹងឱ្យបានត្រឹមត្រូវការកាលកំណត់ទៅតាមពេលវេលាឱ្យបានត្រឹមត្រូវ បើអ្នកណាមិនអនុវត្តតាមនឹងប្រឈមការដាក់ពិន័យផងដែរ។**






*អត្ថបទ៖ អមរិន្ទ ដានុត*

រដ្ឋបាលរាជធានីភ្នំពេញបានឱ្យដឹងថា ការធ្វើការកំណែទម្រង់នៃការគ្រប់គ្រងសំរាម និងសំណល់រឹងចាប់ពីដើមខ្សែរហូតដល់ចុងខ្សែ ទទួលបានលទ្ធផលគួរជាទីមោទនៈ ដែលក្នុងនោះ ការដេញថ្លៃជ្រើសរើសក្រុមហ៊ុនថ្មី ដើម្បីផ្ដល់សេវាសំអាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ ក៏បានធ្វើរួចរាល់ផងដែរ។

មានក្រុមហ៊ុនចំនួន០៣ ត្រូវបានជ្រើសរើស ហើយបានចាប់ផ្ដើមប្រតិបត្តិការការងាររបស់ខ្លួនកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ចាប់តាំងពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១មក។ ក្រុមហ៊ុនទាំង០៣នោះរួមមាន ក្រុមហ៊ុន 800 Super/Global Action for Environment Awareness Public Limited បានផ្ដល់សេវាក្នុងតំបន់ទី១ ដែលមានចំនួន០៥ខណ្ឌ៖ ខណ្ឌទួលគោក ខណ្ឌសែនសុខ ខណ្ឌឫស្សីកែវ ខណ្ឌជ្រោយចង្វារ និងខណ្ឌព្រែកព្នៅ។

សម្រាប់ ក្រុមហ៊ុន Mizuda Group Co., Ltd បានផ្ដល់សេវាក្នុង តំបន់ទី២ ដែលមាន០៥ខណ្ឌ រួមាន ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌដង្កោ ខណ្ឌកំបូល និងខណ្ឌពោធិ៍សែនជ័យ។ ចំណែកក្រុមហ៊ុន CINTRI (Cambodia) /Everbright (China) បានផ្ដល់សេវា ក្នុងតំបន់ទី៣ ដែលមាន០៤ខណ្ឌ គឺ ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ។

ដើម្បីឱ្យការអនុវត្តប្រព័ន្ធថ្មីនៃការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ រដ្ឋបាលរាជធានីភ្នំពេញ បានធ្វើការណែនាំអំពីការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹង ដោយត្រូវសំរាម និងសំណល់រឹង មុននឹងបញ្ចេញ ត្រូវសម្រិតទឹកចេញដាក់ចូលទៅក្នុងប្រព័ន្ធលូឱ្យបានត្រឹមត្រូវ។

### ការញែកសំរាម សំណល់រឹង

សំរាម សំណល់រឹង ត្រូវបានបែងចែកជាពីរប្រភេទ គឺសំរាមសើម និងសំរាមស្ងួត។ សំរាមសើម មានដូចជា សំណល់ម្ហូបអាហារ សំណល់សរីរាង្គ ផ្លែឈើ ផ្កា ចំណែកសំរាមស្ងួត មានក្រដាស ក្រដាសកាតុង ឡាំង គ្រឿងប្លាស្ទីក ហ្វូម ជ័រ ដែក កំប៉ុង ដប...ជាដើម។

ក្នុងការបែងចែកសំរាម សំណល់រឹងនេះ រដ្ឋបាលរាជធានីភ្នំពេញ បានតម្រូវឱ្យប្រជាពលរដ្ឋទាំងអស់ត្រូវញែកសំរាម សំណល់រឹងទាំង០២ប្រភេទ ដាក់នៅក្នុងថង់ដាច់ដោយឡែកពីគ្នា ដែលសំរាមសើម ត្រូវដាក់នៅក្នុងថង់ពណ៌ខ្មៅ និងសំរាមស្ងួត ត្រូវដាក់ក្នុងថង់ពណ៌ស។

លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ បានធ្វើការបញ្ជាក់ឱ្យដឹងថា ៖ «ក្រុមហ៊ុនដឹកសំរាមនឹងធ្វើការប្រមូល និងដឹកជញ្ជូនតែសំរាមសំណល់រឹង ដែលបានដាក់ក្នុងថង់ដែលបានកំណត់ទាំង០២ប្រភេទនេះតែប៉ុណ្ណោះ ទៅតាមកម្មវិធីដាច់ដោយឡែកពីគ្នា»។

លោកថា ការដាក់សំរាម សំណល់រឹង ក្នុងថង់ពណ៌ផ្សេងក្រៅពីពណ៌ខ្មៅ និងពណ៌ស ក្រុមហ៊ុននឹងមិនប្រមូលឡើយ។ បងប្អូនប្រជាពលរដ្ឋអាចរកទិញថង់ទាំង០២ពណ៌ខាងលើនេះ នៅតាមបណ្ដាទីផ្សារនានា។

### ហាមវេចខ្ចប់សំណល់ដែលបង្កគ្រោះថ្នាក់

ទាក់ទងនឹងសំណល់គ្រោះថ្នាក់ ដូចជា អំពែងកញ្ចក់ និងសំណល់មុតស្រួចនានា ត្រូវបានហាមដាក់លាយឡំជាមួយនឹងសំរាមសើម និងសំរាមស្ងួត ប៉ុន្តែត្រូវទុកដាក់សំណល់ដែលបង្កគ្រោះថ្នាក់ទាំងនេះចូលក្នុងធុងសំរាម ឬប្រអប់ដោយឡែកឱ្យបានត្រឹមត្រូវ ក្រុមហ៊ុនប្រមូលសំរាមនឹងប្រមូលនៅរៀងរាល់ថ្ងៃអាទិត្យ។ ក្នុងករណីទុកដាក់ខុសពីការណែនាំនេះ ក្រុមការងារនឹងធ្វើការផាកពិន័យ ហើយធ្វើកំណត់ហេតុអំពីកំហុសឆ្គងលើកទី។ បើនៅតែទុកដាក់ខុសទៀត នឹងទទួលការផាកពិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន ព្រមទាំងប្ដឹងទៅតុលាការតាមកំហុសជាក់ស្ដែង។

ជាងនេះទៅទៀត ថង់សំរាម សំណល់រឹងត្រូវចងមាត់ឱ្យបានជិតត្រឹមត្រូវ និងមិនត្រូវហែកឡើយ។

សម្រាប់ផ្សារទំនើប ផ្សាររដ្ឋ ផ្សារឯកជន អគារពាណិជ្ជកម្ម សណ្ឋាគារ ផ្ទះសំណាក់ អាគារស្នាក់នៅ ភោជនីយដ្ឋាន កន្លែងកំសាន្ត សាលារៀន មន្ទីរពេទ្យ លំនៅដ្ឋានក្នុង បុរី សហគ្រាស រោងចក្រ សិប្បកម្ម អគារក្រសួងស្ថាប័នរដ្ឋ ត្រូវមានកាតព្វកិច្ចដាក់ធុងសំរាមដោយខ្លួនឯងជាចាំបាច់។

ជាមួយគ្នានេះដែរ រដ្ឋបាលរាជធានីភ្នំពេញក៏បានបញ្ជាក់ពីក្រុមលើកទឹកចិត្ត ដែលមានដូចជា វត្តអារាម ព្រះវិហារ អាជីវកម្មលក់ដូរចល័ត ផ្ទះស្នាក់នៅទូទៅ និងផ្សារក្រមួន...

តម្រូវឱ្យមានធុងសំរាមខ្លួនឯង និងអាចមានធុងសំរាមដែលផ្ដល់ឱ្យដោយប្រតិបត្តិករថ្មី ដែលអាចត្រូវបានរៀបចំដាក់ពង្រាយជាពិសេសនៅតាមតំបន់ផ្ទះល្វែងខ្ពស់។







### ការបញ្ចេញសំរាម សំណល់រឹង

ការបញ្ចេញសំរាម សំណល់រឹងសើម ក្នុងខណ្ឌកណ្ដាលនៃរាជធានីដែលមានខណ្ឌចំនួន០៥ រួមមាន៖ ខណ្ឌដូនពេញ ខណ្ឌចំការមន ខណ្ឌ៧មករា ខណ្ឌទួលគោក និងខណ្ឌបឹងកេងកង ក្រុមហ៊ុននឹងប្រមូល និងដឹកជញ្ជូនរៀងរាល់ថ្ងៃ នៅពេលយប់ចាប់ពីម៉ោង ៩ ដល់ម៉ោង ៥ ទៀបភ្លឺ។ ដូច្នេះ ម៉ោងបញ្ចេញសំរាមមានម៉ោង គឺ៦-៩យប់។ បញ្ចេញសំរាមខុសពីម៉ោងនេះ នឹងទទួលការផាកពិន័យ។

សម្រាប់ ខណ្ឌជាយរាជធានី ដែលមានចំនួន០៩ រួមមាន៖ ខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វារ ខណ្ឌដង្កោ ខណ្ឌព្រែកព្នៅ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌកំបូល ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ ក្រុមហ៊ុននឹងប្រមូលនិងដឹកជញ្ជូន តាមផ្លូវជាតិ ត្រូវប្រមូល និងដឹកជញ្ជូនរៀងរាល់ថ្ងៃ នៅពេលយប់ វេលាម៉ោង ៩យប់ ដូច្នេះ ការបញ្ចេញសំរាមត្រូវចាប់ផ្ដើមចន្លោះពីម៉ោង៦យប់ រហូតដល់ម៉ោង ៩យប់។ រីឯផ្លូវធំត្រូវប្រមូល និងដឹកជញ្ជូនរៀងរាល់ថ្ងៃ (ពេលថ្ងៃ វេលាម៉ោង ៨ព្រឹក ឬពេលយប់ វេលាម៉ោង ។ និងផ្លូវរណប ត្រូវប្រមូល និងដឹកជញ្ជូនរៀងរាល់ ១២ថ្ងៃ/១ម្ដង (ពេលថ្ងៃ វេលាម៉ោង ៨ព្រឹក ឬពេលយប់ វេលាម៉ោង ៩ ។

សម្រាប់សំរាម សំណល់រឹងស្ងួត ក្រុមហ៊ុននឹងប្រមូល និងដឹកជញ្ជូន ២ដង/១សប្ដាហ៍ គឺនៅរៀងរាល់ថ្ងៃចន្ទ និងថ្ងៃសុក្រ។

> ក្រុមហ៊ុនដឹកសំរាមនឹងធ្វើការប្រមូល និងដឹកជញ្ជូនតែសំរាមសំណល់រឹង ដែលបានដាក់ក្នុងថង់ដែលបានកំណត់ទាំង០២ប្រភេទនេះតែប៉ុណ្ណោះ ទៅតាមកម្មវិធីដាច់ដោយឡែកពីគ្នា

ក្នុងករណីខកខានមិនបានបញ្ចេញសំរាមសំណល់រឹងតាមម៉ោងពេលកំណត់ (ពេលថ្ងៃត្រឹមម៉ោង ៨ព្រឹកនិងពេលយប់ ត្រឹមម៉ោង ៩យប់) ត្រូវរង់ចាំបញ្ចេញនៅវេនក្រោយ ហើយមិនត្រូវយកសំរាមនេះមកទុក គ្មានសណ្ដាប់ធ្នាប់ឡើយ។

ចំពោះសំណល់ដើមឈើ និងមែកឈើ សំណង់ អាចម៍ដី កំទេចថ្ម ខ្សាច់...សំណល់ជាគ្រឿងសង្ហារឹម គ្រឿងអេឡិចត្រូនិក គ្រឿងអគ្គិសនីសំបកកង់ និងវត្ថុកែច្នៃឡើងវិញបាន ត្រូវទុកដាក់ដោយឡែកឱ្យបានត្រឹមត្រូវ រួចធ្វើការទំនាក់ទំនងមករដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ។




អ្នកនាំពាក្យក្រសួងបរិស្ថាន លោក នេត្រ ភត្រា បានគាំទ្រចំពោះវិធានការនៃការគ្រប់គ្រងសំរាមសំណល់រឹងរបស់សាលារាជធានីភ្នំពេញនេះ ដោយលោកបានថ្លែងថា ការកែទម្រង់របស់រាជរដ្ឋាភិបាលលើការគ្រប់គ្រងសំណល់សំរាម តាមរយៈការដាក់ចុះនូវគោលនយោបាយគ្រប់គ្រងសំណល់រឹងសំរាមតាមទីប្រជុំជន និងការតម្រង់ទិសឱ្យមានការគ្រប់គ្រងដោយក្រុមហ៊ុនច្រើន និងការចូលរួមពីសាធារជនក្នុងការគ្រប់គ្រងសំរាមនេះ។

យោងតាមរបាយការណ៍របស់ក្រសួងបរិស្ថាន បានឱ្យដឹងថា សម្រាប់ប្រទេសកម្ពុជា មួយថ្ងៃសំរាមដែលបង្កើតឡើងមានប្រមាណជាជាង១ម៉ឺនតោន ដែលក្នុងនោះរាជធានីភ្នំពេញមានចន្លោះពី២៧០០ទៅ៣០០០តោនក្នុងមួយថ្ងៃ។ ចំណែក១ឆ្នាំ កម្ពុជាបង្កើតសំរាមបានប្រមាណជាង៤លានតោន។

ប្រភពដដែលបានបន្តថា នៅក្នុងសំណល់ ១០០% គឺ៦៨%ជាសំណល់សរីរាង្គ ២០%ជាសំណល់ប្លាស្ទិក ហើយប្រមាណជា១០% សំណល់រឹងជាសំណល់គ្រោះថ្នាក់៕






# ក្រោយបញ្ចប់ការសិក្សាយុវជនម្នាក់ចាប់ផ្តើមកែច្នៃផលិតផលពីផ្លែឈើក្នុងស្រុក

*អត្ថបទ៖ ផល សុផានិត*

យុវជនមួយរូប បានបញ្ចប់ការសិក្សាអនុបណ្ឌិតផ្នែកវិស្វកម្ម ឧស្សាហកម្ម នៅប្រទេសថៃ បានបង្កើតសហគ្រាសខ្លួនឯង ដើម្បីកែច្នៃកសិផលក្នុងស្រុក ក្នុងគោលបំណងឱ្យប្រជាពលរដ្ឋខ្មែរ ស្គាល់ផលិតផលជាតិ និងនាំចេញទៅក្រៅប្រទេស ជាជាងការនាំចេញផលិតផលស្រស់ទៅកាន់ក្រៅប្រទេស។

ដោយមានការជួយជ្រោមជ្រែងពីអង្គការខេមបូឌា ហាវេសធូ(Cambodia Harvest II) លើផ្នែកទីផ្សារ និងទំនាក់ទំនងដៃគូក្នុងការនាំចេញ ព្រមទាំងដៃគូក្នុងស្រុកនៅតាមម៉ាត(Mart) មួយចំនួន សហគ្រាស ណាវីតា កំពុងពង្រីកកិច្ចសហប្រតិបត្តិការជាមួយម៉ាតផ្សេងៗទៀត និង ឈានទៅទីផ្សារទំនើបធំៗក្នុងស្រុកនាចុងឆ្នាំនេះ។

លោក អ៊ុយ ឆេងហេង មានវ័យ២៨ឆ្នាំ ជាស្ថាបនិកសហគ្រាសណាវីតា បានបញ្ចប់ការសិក្សាអនុបណ្ឌិតផ្នែកវិស្វកម្ម ឧស្សាហកម្ម នៅសាកលវិទ្យាល័យ ម៉ាហីដុល(Mahidol) នៃប្រទេសថៃ បានសម្រេចបង្កើតការកែច្នៃច្រើន នូវកសិផលក្នុងស្រុកដូចជា ផ្លែមៀន តាងែន ស្រកានាគ ស្វាយ ម្នាស់ និងផ្លែឈើហូបផ្លែជាច្រើនមុខទៀតឱ្យចេញជាផលិតផលស្តង់ដារ។

លោក អ៊ុយ ឆេងហេង ជាកូនកសិករនៅខេត្តបាត់ដំបងស្រាប់ បានលើកឡើងពីកម្លាំងចិត្តដែលជម្រុញឱ្យរូបលោកបង្កើតសហគ្រាសណវីតា ដើម្បីកែច្នៃផ្លែឈើដូច្នេះថា ទី១ គឺការជម្រុញរបស់ក្រុមគ្រួសារ ទី២ គឺកើតចេញពីក្តីស្រលាញ់លើជំនាញគីមីចំណីអាហារ ទី៣គឺដើម្បីជំនះការម៉ាក់ងាយពីអ្នកជុំវិញទៅលើសមត្ថភាពរបស់លោក ទី៤ គឺលោកមានគោលបំណងជួយលើកស្ទួយវិស័យកសិកម្មក៏ដូចជាលើកស្ទួយផលិតផលជាតិ និងជាចំណែកតូចមួយក្នុងការទប់ស្កាត់ការធ្វើការចំណាកស្រុករបស់ប្រជាជននៅខេត្តបាត់ដំបង។

ស្ថាបនិកវ័យក្មេងរូបនេះ បាននិយាយថា ត្បិតតែសហគ្រាសនេះទើបតែចាប់ផ្តើមរីកធំធាត់មែនពិត តែក៏បានជួយផ្តល់ការងារមួយចំនួនដល់ប្រជាជនក្នុងតំបន់ ប្រមាណជាជិត៣០នាក់ ហើយថ្ងៃអនាគតនឹងពង្រីកឱកាសការងារបន្ថែមទៀតដល់ប្រជាពលរដ្ឋក្នុងស្រុកឱ្យមានការងារសមរម្យ។

សហគ្រាសណាវីតា បង្កើតឡើងក្នុងឆ្នាំ២០១៥ ជាសហគ្រាសធនតូចនិងមធ្យមពាក់កណ្តាលស្វ័យប្រវត្តិស្ថិតនៅក្នុងភូមិសាសាបាលាត់ សង្កាត់អូម៉ាល់ ក្រុង ខេត្តបាត់ដំបង។

លោកបានឲ្យដឹងទៀតថា ក្នុងពេលបច្ចុប្បន្នលោកកំពុងពិចារណាលើផលិតផលគម្រូដែលបានផ្ញើទៅ ដូចជាបារាំង អង់គ្លេស អ៊ីតាលី អេស្ពាញ អាឡឺម៉ង់ ខណៈអូស្ត្រាលីកំពុងដាក់លក់ផលិតផលណាវីតាជាបណ្តើរៗក្នុងកម្រិតសាកល្បង និងមានដៃគូសហការកំពុងសហការនាំចេញទៅជប៉ុន កូរ៉េខាងត្បូង និងត្រៀមតាំងបង្ហាញផលិតផលនៅប្រទេសសិង្ហបុរីនាខែក្រោយនេះផងដែរ។








ទោះជាយ៉ាងនេះក្តី លោកឆេងហេង បាននិយាយពីបញ្ហាកង្វះខាតដើមទុន បញ្ហាទីផ្សារតែម្តង និងការប្រកួតប្រជែងតម្លៃ។ លោកបានឲ្យដឹងថា ភាគច្រើនអតិថិជនមិនទាន់ស្គាល់ផលិតផលរបស់លោក ម្យ៉ាងវិញទៀត សំបកវេចខ្ចប់ត្រូវបានបញ្ជាទិញពីប្រទេសជិតខាងក្នុងតម្លៃថ្លៃ ពិបាកក្នុងការប្រកួតប្រជែងជាមួយផលិតផលនាំចូល។

ថ្ងៃមុខលោកមានគោលដៅថានឹងកែច្នៃបន្លែផ្លែឈើគ្រប់ប្រភេទឲ្យមានគ្រប់ទម្រង់ដូចជា ម្សៅ ទឹកភេសជ្ជៈ ផ្លែឈើសម្ងួតផ្សេងៗទៀត ដែលមានដាំដុះក្នុងប្រទេសកម្ពុជា ក្រៅពីផលិតដែលបានដាក់លក់ក្នុងពេលសព្វថ្ងៃនេះ ដូចជាស្វាយ ប៉េងប៉ោះ ម្នាស់ ស្រកានាគ ផ្លែមៀនប៉ៃលិនឬតាងែន ល្ហុងជាដើម៕

# «យុទ្ធនាការទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថសង្គម ស្តីពីការកាត់បន្ថយតម្រូវការប្រើប្រាស់គ្រឿងសង្ហារិមធ្វើពីឈើប្រណិត» ត្រូវបានសម្ពោធជាផ្លូវការ





*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងបរិស្ថាននិងទីភ្នាក់ងារជំនួយអាមេរិក USAID បានប្រកាសជាផ្លូវការរួមគ្នានូវ «យុទ្ធនាការទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថសង្គម ស្តីពីការកាត់បន្ថយតម្រូវការប្រើប្រាស់គ្រឿងសង្ហារិមធ្វើពីឈើប្រណិត» នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១នេះ ដែលជាយុទ្ធនាការមួយក្នុងចំណោមយុទ្ធនាការសំខាន់ៗចំនួន៣ ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ទីភ្នាក់ងារជំនួយអាមេរិកUSAID បានលើកឡើងថា យុទ្ធនាការទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថសង្គមរបស់យុវជនគាំទ្របរិស្ថានថ្មីមួយ ដែលឧបត្ថម្ភដោយទីភ្នាក់ងារជំនួយអាមេរិកUSAID ក្នុងការកាត់បន្ថយតម្រូវការប្រើប្រាស់គ្រឿងសង្ហារឹមធ្វើពីឈើប្រណិត ត្រូវបានប្រកាសជាផ្លូវការហើយ។

ការប្រកាសនេះ ធ្វើឡើងរវាងលោក រីឆាត ឈិន ប្រធាន ការិយាល័យកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព នៃទីភ្នាក់ងារជំនួយអាមេរិក USAID និងលោកស្រី មាស ច័ន្ទធីតា អគ្គនាយិការងអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន។

សេចក្តីប្រកាសនេះបានបញ្ជាក់ថា យុទ្ធនាការនេះ គឺជាយុទ្ធនាការមួយក្នុងចំណោមយុទ្ធនាការចំនួនបី ដែលផ្តល់ខ្លឹមសារ និងសារគន្លឹះ តាមរយៈប្រព័ន្ធ ពហុផ្សព្វផ្សាយ ដើម្បីគាំទ្រយុវជន ដែលជា «ជើងឯកបៃតង» ក្នុងការធ្វើជាគម្រូ ផ្លាស់ប្តូរឥរិយាបថ និងការអនុវត្តឱ្យបានជោគជ័យជុំវិញកិច្ចការពារធនធានធម្មជាតិរបស់កម្ពុជា។

លោក រីឆាត ឈិន បានឱ្យដឹងថា តម្រូវការឈើប្រណិត មានការកើនឡើងគួរឱ្យកត់សម្គាល់ទាំងទីផ្សារក្នុងស្រុក និងអន្តរជាតិ ដែលរួមចំណែកដល់ការកាប់បំផ្លាញព្រៃឈើ និងការបាត់បង់ប្រភេទដើមឈើមានតម្លៃ ដូចជាឈើគ្រញូង ធ្នុង នៅក្នុងព្រៃត្រូពិចរបស់កម្ពុជា។

លោកបានថ្លែងថា៖«យើងសង្ឃឹមថា យុទ្ធនាការនេះនឹងផ្តល់ព័ត៌មាន មានប្រយោជន៍ និងផ្តល់ជម្រើសដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសយុវជនធ្វើការពិចារណា ដើម្បីពួកគេ អាចចូលរួមការពារបរិស្ថានរបស់ពួកគេឱ្យកាន់តែប្រសើរឡើង»។

លោក រីឆាត ឈិន បានបន្ថែមថា ការធ្វើសកម្មភាពត្រឹមត្រូវនៅថ្ងៃនេះ អាចនាំឱ្យមានផលវិជ្ជមាន នាពេលអនាគត ដល់ព្រៃឈើ និងសត្វព្រៃនៅកម្ពុជានាពេលអនាគត។ សូមរក្សាដើមឈើឱ្យនៅកន្លែងដែលពួកវាកំពុងស្ថិតនៅ។

ជាមួយគ្នានេះដែរ លោកស្រី មាស ច័ន្ទធីតា ក៏បានថ្លែងឡើងផងដែរថា ប្រជាជនកម្ពុជាទាំងចាស់ ទាំងក្មេង មានកាតព្វកិច្ចចូលរួមក្នុងការអភិរក្ស និងការពារធនធានធម្មជាតិដ៏មានតម្លៃរបស់ខ្លួន។ លោកស្រីបានមានប្រសាសន៍ថា ៖ «គោលបំណងនៃយុទ្ធនាការនេះ គឺគាំទ្រដល់យុទ្ធសាស្ត្រគាំពារបរិស្ថានជាតិ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគោលដៅពង្រឹងប្រសិទ្ធភាពគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព»។

ពិធីសម្ពោធយុទ្ធនាការនេះ បានបង្ហាញពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ក្នុងការលើកកម្ពស់កិច្ចគាំពារបរិស្ថាន ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តភាព និងសកម្មភាពជាវិជ្ជមានពីសាធារណជន ក្នុងការអភិរក្សកេរ្តិ៍ដំណែលធម្មជាតិ ដ៏សម្បូរបែបរបស់កម្ពុជាដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋគ្រប់រូប ក៏ដូចជាអ្នកជំនាន់ក្រោយៗទៀត៕

គួរបញ្ជាក់ផងដែរថា ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៦១ ដោយលោកប្រធានាធិបតី John F. Kennedy និងដើរតួនាទីជាទីភ្នាក់ងារនាំមុខរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ក្នុងការផ្តល់ជំនួយបរទេស។ ចាប់តាំង ពីឆ្នាំ ១៩៩២ មក ទីភ្នាក់ងារនេះ បានផ្តល់ជំនួយប្រមាណជាង ១ ពាន់លានដុល្លារអាមេរិកសម្រាប់ការអភិវឌ្ឍ ដល់ប្រទេសកម្ពុជាផងដែរ៕

# នាយឧត្តមសេនីយ៍ វង្ស ពិសេន ទទួលជួបជាមួយអនុព័ន្ធយោធាថ្មីសហរដ្ឋអាមេរិក ប្រចាំកម្ពុជា



*អត្ថបទ៖ ផល សុផានិត*

នាយឧត្តមសេនីយ៍ វង្ស ពិសេន អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ បានទួលជួបជាមួយលោកវរសេនីយ៍ឯក Thang Jacky Ly អនុព័ន្ធយោធាថ្មីរបស់សហរដ្ឋអាមេរិក ប្រចាំកម្ពុជា នៅអគ្គបញ្ជាការដ្ឋាន នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១។

ក្នុងឱកាសនោះ លោកវរសេនីយ៍ឯក Thang Jacky Ly បានជម្រាបជូននាយឧត្តមសេនីយ៍អគ្គមេបញ្ជាការ ពីគោលបំណងនៃការមកបំពេញបេសកកម្មការទូតនៅកម្ពុជា ដោយទី១ ធ្វើការសិក្សាស្វែងយល់ពីវប្បធម៌ និងទំនៀមទម្លាប់របស់ប្រទេសកម្ពុជា។ ទី២ ធ្វើការយ៉ាងជិតស្និតជាមួយថ្នាក់ដឹកនាំនៃកងយោធពលខេមរភូមិន្ទ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការរវាងកងទ័ពប្រទេសទាំងពីរ។

ជាការឆ្លើយតប នាយឧត្តមសេនីយ៍ វង្ស ពិសេន បានលើកឡើងពីទំនាក់ទំនងការទូតរវាងកម្ពុជា និងសហរដ្ឋអាមេរិក ដែលមានតាំងពីឆ្នាំ១៩៥០ ហើយមកដល់បច្ចុប្បន្ននេះ កម្ពុជានៅតែមានជំហររក្សាកិច្ចសហប្រតិបត្តិការល្អជាមួយសហរដ្ឋអាមេរិក។

នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការ បានថ្លែងអំណរគុណដល់សហរដ្ឋអាមេរិក ដែលថ្មីៗនេះបានជួយដល់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ តាមរយៈការផ្តល់វ៉ាក់សាំងចំនួន ១លាន ៦សែនដូស រួមទាំងសម្ភារៈបរិក្ខាពេទ្យមួយចំនួនទៀត។ ក្រៅពីនោះ សហរដ្ឋអាមេរិកនៅបានផ្តល់ជំនួយមនុស្សធម៌ដល់កម្ពុជា ដូចជាការជួយសង្គ្រោះគ្រោះមហន្តរាយផ្សេងៗ ការជួយកសាងហេដ្ឋារចនាសម្ព័ន្ធ និងការបណ្តុះបណ្តាលធនធានមនុស្សជាដើម។

នាយឧត្តមសេនីយ៍ វង្ស ពិសេន ក៏បានលើកឡើងពីកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងសហរដ្ឋអាមេរិក នាពេលកន្លងមក ក្នុងការស្រាវជ្រាវរុករកអដ្ឋិធាតុកងទ័ពអាមេរិកដែលបាត់ខ្លួនក្នុងសង្គ្រាមនៅកម្ពុជា និងកិច្ចសហប្រតិបត្តិការបង្ក្រាបអំពើភេរវកម្ម ការជួញដូរមនុស្ស ក៏ដូចជាការហ្វឹកហ្វឺនឆ្មាំអង្គរ និងការកសាងកម្លាំងរបស់កងយោធពលខេមរភូមិន្ទ ដែលត្រូវទៅបំពេញបេសកកម្មនៅអង្គការសហប្រជាជាតិ និងលំហរសមុទ្រផងដែរ។

នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការ មានជំនឿថា ទៅថ្ងៃអនាគត សហរដ្ឋអាមេរិកនៅតែបន្តទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អជាមួយកម្ពុជា ដោយឈរលើគោលការណ៍គោរពអធិបតេយ្យភាព ការគោរពគ្នា និងការជឿទុកចិត្តគ្នាទៅវិញទៅមក ហើយកម្ពុជានៅតែចាត់ទុកសហរដ្ឋអាមេរិកជាមិត្តល្អរបស់កម្ពុជា៕

# កម្មវិធីលើទូរសព្ទដៃ (App) របស់វិទ្យុវើរីតាសអាស៊ី ត្រូវបានសម្ពោធដាក់ដំណើរការជាផ្លូវការហើយ!

*អត្ថបទ៖ ព្រះសហគមន៍កាតូលិក*




លោកកាឌីណាល់ ឆាល មួង បូ ដែលជាប្រធានសម្ព័ន្ធសភាលោកអភិបាលកាតូលិកទ្វីបអាស៊ី (FABC) បានសម្ពោធដាក់ឱ្យប្រើប្រាស់កម្មវិធីថ្មី លើទូរសព្ទដៃរបស់វិទ្យុវើរីតាសអាស៊ី នៅវិសាលវិហារ សន្តីម៉ារី ក្នុងទីក្រុងយ៉ាំងហ្គូន ប្រទេសភូមា នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃរំឭកដល់សម្តេចប៉ាប យ៉ូហាន ទី២៣ ដែលជាអ្នកផ្តើមគំនិតឱ្យស្ថាបនាវិទ្យុវើរីតាសអាស៊ី។

វិទ្យុវើរីតាសអាស៊ី (radio veritas asia - RVA) គឺជាប្រព័ន្ធផ្សព្វផ្សាយរបស់ព្រះសហគមន៍កាតូលិក ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៦៩ ដោយសម្ព័ន្ធសភាលោកអភិបាលកាតូលិកទ្វីបអាស៊ី FABC។ RVA បានផ្សព្វផ្សាយអំពីបេសកកម្មរបស់ FABC ក្នុងការប្រកាសដំណឹងល្អ ទៅកាន់មនុស្សទាំងអស់នៅទ្វីបអាស៊ី និងនៅទ្វីបផ្សេងទៀត ដោយណែនាំឱ្យមនុស្សមានទំនាក់ទំនងគ្នាតាមរយៈកិច្ចសន្ទនាសាសនា វប្បធម៌ និងសកម្មភាពបម្រើ បងប្អូនក្រីក្រ។

លោកកាឌីណាល់ បូជាអគ្គអភិបាល ព្រះសហគមន៍កាតូលិកភូមិភាគ យ៉ាំងហ្គោន នឹងប្រកាសដាក់ឲ្យដំណើរការ កម្មវិធីថ្មីលើទូរសព្ទនេះនៅក្នុងពិធីបុណ្យអភិបូជាផ្សាយផ្ទាល់ពិសេសនាពេលនោះ។ លោកកាឌីណាល់នឹងថ្លែងសារពិសេស ទៅកាន់បងប្អូនទាំងអស់បន្ទាប់ពីពិធីបុណ្យអភិបូជា។

ជាមួយគ្នានេះ លោកអភិបាលទទួលបន្ទុកផ្នែកប្រព័ន្ធផ្សព្វផ្សាយ នៃ Office of Social Communication (OSC) នឹងថ្លែងសារនៅក្នុងកម្មវិធីដ៏មហាឱឡារិកនេះ មានលោកអភិបាល រ៉ូប៊ីត ម៉ាឡារី ជាប្រធាន FABC-OSC។

លោកអភិបាលមាន រ៉េមុន វីកក្រាម៉ាស៊ីង (Raymond Wickramasinghe) និងលោកអភិបាល យ៉ូសែប លេឆៃ ថាត់វីស៊ី (Joseph Luechai Thatwisi) សមាជិកនៃ FABC-OSC លោកបូជាចារ្យ ចច ផ្លាតូតាម (George Plathottam SDB) អគ្គលេខាធិការ នៃ FABC-OSC លោកអភិបាល ម៉ាហ្សេលីណូ ម៉ារាលីដ (Marcelino Maralit) និងលោកអភិបាល ម៉ាក្សវែល ស៊ីលវ៉ា (Maxwell Silva) ដែលជាអភិបាលទទួលបន្ទុលប្រព័ន្ធផ្សព្វផ្សាយ នៃសភាលោកអភិបាលភីលីពីន និងស្រីលង្កា។ លោក មីកាអែល អ៊ុងឡាំង (Michael Unland) ជានាយកប្រតិបត្តិ CAMECO ។

ជាកិច្ចចាប់ផ្តើមដោយព្រឹត្តិការណ៍អនឡាញ ហើយអ្នកចូលរួមនឹងសម្គាល់ព្រឹត្តិការណ៍នេះដោយថតរូប តាមរយៈទូរសព្ទរបស់ពួកគេជាមួយកម្មវិធីទូរសព្ទ RVA APP នៅលើអេក្រង់។

នៅក្នុងពិធីនេះ លោក ស៊ីប៊ូ ដេវាសៃ (Shibu Devasia) ជាប្រធានក្រុមការងារបង្កើតកម្មវិធី RVA APP បង្ហាញពីទិដ្ឋភាពទូទៅ អំពីដំណើរការ របស់ RVA APP។

អ្នកចូលរួមទាំងអស់ អាចនឹងទស្សនាវីដេអូផ្សព្វផ្សាយដែលបង្ហាញពីកម្មវិធីទូសព្ទនៅក្នុងពិធី ។ ការផ្សព្វផ្សាយជាវីដេអូមានរួចហើយនៅលើគេហទំព័រ rvasia.org។

ចំណុចសំខាន់ដែលជាលក្ខណៈពិសេសនៃកម្មវិធីទូរសព្ទ គឺជាសារបំផុសគំនិត ពាក្យលើកទឹកចិត្ត ការរិះគិតស៊ីជម្រៅ អំពីព្រះគម្ពីរ អំពីសក្ខីភាពរបស់មហាជន អភិបូជាប្រចាំថ្ងៃ ពាក្យការអធិដ្ឋាន និងការអធិដ្ឋានស្ញឹងស្ញាធ។ កម្មវិធីទូរសព្ទ RVA នឹងផ្តល់ព័ត៌មាន អំពីព្រះសហគមន៍ កាតូលិក តាមរយៈព័ត៌មាន បទយកការណ៍ និងការអត្ថាធិប្បាយផ្សេង។

លោកឪពុក ចច បានមានប្រសាសន៍ថា វិទ្យុវើរីតាសអាស៊ី RVA ប្តេជ្ញាថា នឹងបង្ហាញវត្តមានឌីជីថលនៃព្រះសហគមន៍កាតូលិកនៅអាស៊ី ដើម្បីសម្រេចបាននូវបេសកកម្មរបស់ខ្លួនដោយធ្វើជា «សំឡេងគ្រីស្តសាសនានៅទ្វីបអាស៊ី»។ លោកបានរំឭកអំពីបន្ទូលរបស់សម្តេចប៉ាប សន្ត យ៉ូហានប៉ូលទី ២ ក្នុងដំណើរទស្សនកិច្ចនៅទីក្រុងម៉ានីលក្នុងឆ្នាំ ១៩៩៥ ដើម្បីរំឭកខួប២៥ឆ្នាំរបស់ RVA អំពីបេសកកម្មវិទ្យុសហគមន៍នៅទ្វីបអាស៊ីដោយមានបន្ទូលថា៖ «សេចក្តីពិតដែលជាដំណឹងល្អត្រូវបានឮនៅក្នុងភាសានានារបស់ទ្វីបនេះ ពិតជាធ្វើឱ្យវិទ្យុវើរីតាសអាស៊ីជាសំឡេងរបស់គ្រីស្តសាសនានៅអាស៊ី»។




អ្នកគ្រប់គ្រងទូទៅរបស់ RVA លោកឪពុក វិចទ័រ សាដាយ៉ា (Victor Sadaya) មានប្រសាសន៍ថា «បេសកកម្មរបស់ RVA គឺដើម្បីចែករំលែកព្រះគ្រីស្តជាមួយជនជាតិអាស៊ីទូទាំងពិភពលោក តាមរយៈភាសាទាំង២១ផ្សេងៗគ្នា»។

«កម្មវិធីថ្មីលើទូរសព្ទ អាចឱ្យលោកអ្នកជ្រើសរើសភាសាដែលខ្លួនពេញចិត្ត» នេះជាប្រសាសន៍របស់លោកបូជាចារ្យ ប៊ីណាត ដាស៊្សី តាំង (Bernard Dashi Tang) ដែលជាប្រធានកម្មវិធីការផ្សាយរបស់ RVA ។

លោកបូជាចារ្យ ប៊ីណាត មានប្រសាសន៍ទៀតថា «RVA ផ្សាយជាសេវាកម្មជាភាសាអង់គ្លេស និង ២១ភាសាទៀតក្នុងភូមិអាស៊ីមានដូចជា៖ ភាសាខ្មែរ ភាសាបង់ហ្គាលី ចិនហ្វាឡាម ចិនហាកា ចិនតឹឌីម ហិណ្ឌូ ភាសាមន ភាសាកាឈីនជិងផាវ ភាសាកាឈីនលីស៊ូ កាឈីនរ៉ាវ៉ាង ការ៉ែនស្កាវ ការ៉ែនផូ កាចូ ម៉ាដារីន ភូមា ស៊ីនហាឡា ទមិឡ តេលូហ្គូ អ៊ូឌូ វៀតណាម និងហ្មូង»។ លោកបញ្ជាក់ថា កម្មវិធីថ្មីលើទូរសព្ទនេះមាននៅលើ Google Playstore និង App Store ។

លោកស្រី អាលែន ដូណាប៊ឺ (Arlene A. Donarber) ជំនួយការប្រធានកម្មវិធីផ្សាយរបស់ RVA បានអញ្ជើញប្រជាជនអាស៊ីឱ្យ«ចូលរួមចំណែកជាមួយនៃវិទ្យុវើរីតាសអាស៊ី និងដើម្បីស្តាប់ដំណឹងល្អ»។ លោកស្រីអាលែន នឹងធ្វើបទបង្ហាញពិសេសលើកម្មវិធីថ្មីនេះផងដែរ។

លោកហ្វេរ៉ូស្ស ហ្វឺណាន់ដេស (Feroz Fernandes, sfx,) ប្រធានការិយ័យនិពន្ធរបស់វិទ្យុវើរីតាសអាស៊ី បានមានប្រសាសន៍ថា «កម្មវិធីនេះអាចផ្តល់ឱ្យយើង នូវការអប់រំ ព័ត៌មាន និងការប្រកាសជំនឿ»។

# គ្រូអប់រំជំនឿនៃព្រះសហគមន៍ចំនួន៣ ចូលរួមសិក្ខាសាលា

*អត្ថបទ៖ ឆាក លាំង*



កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១កន្លងទៅ ក្រុមគ្រូអប់រំជំនឿចំនួន១០នាក់ មកពីកន្លែង៣គឺព្រះសហគមន៍ក្រចេះ ខ្សឹម និងគុលលើ បានចូលរួមកម្មវិធីសិក្ខាសាលាមួយ នៅព្រះវិហារក្រចេះ ស្ថិតក្នុងភូមិ១ ឃុំរការកណ្តាល ស្រុកក្រចេះ ខេត្តក្រចេះ។

បងស្រីអាញ៉េស ស្រី សុជាតិ ជាអ្នករៀបចំ និងធ្វើបទបង្ហាក្នុងសិក្ខាសានេះ បានផ្តល់បទសម្ភាសន៍ជាមួយ វិទ្យុ វើរីតាស អាស៊ី តាមសារអេឡិចត្រូនិចថា កម្មវិធីសិក្ខាសាលាគ្រូអប់រំជំនឿនេះ មានរយៈពេលពេញមួយថ្ងៃ ក្រោមប្រធានបទ «លក្ខណៈ និងតួនាទីរបស់អ្នកអប់រំជំនឿ» ។

បងស្រី សុជាតិ បន្តថា ក្នុងប្រធានបទធំមួយនេះ យើងបានចែកចេញជា៣ផ្នែកតូចៗទៀត៖ ១.រិះគិតអំពីសារៈសំខាន់នៃការអប់រំជំនឿ ២.សារៈសំខាន់របស់អ្នកអប់រំជំនឿ និងទី៣. ដំណាក់កាលផ្សេងៗនៃការអប់រំជំនឿ។

ដូនជីខ្មែររូបនេះបានបន្ថែមថា គោលដៅដែលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមរៀបចំ ជាក្រុមតូចៗ សម្រាប់គ្រូអប់រំជំនឿតាមតំបន់ផ្សេងៗ ព្រោះតែមានការបារម្ភ ពីការរីករាលដាលនៃជំងឺឆ្លងកូវីដ១៩។

កម្មវិធីសិក្ខាសាលានេះគឺរំលឹកពីគរុកោសល្យ ដែលលោកគ្រូអ្នកគ្រូអប់រំជំនឿចាស់ៗបានទទួល និងពង្រឹងជំនឿបន្ថែមដល់គ្រូថ្មីៗ ឲ្យពួកគាត់ដឹងកាន់តែច្បាស់អំពីសារៈសំខាន់ និងតួនាទីរបស់ខ្លួនជាគ្រូអប់រំជំនឿ ឲ្យស្របទៅតាមគោលដៅ និងគម្រោងការដែលព្រះសហគមន៍បានណែនាំ។

បងប្រុស ប្រាក់ ប៊ុនហុង ជាសិក្ខាកាមម្នាក់ដែលបានចូលរួមក្នុងកម្មវិធីសិក្ខាសាលានេះ បានលើកឡើងថា «ខ្ញុំបានទទួលបទពិសោធថ្មីបន្ថែម ទាំងខាងជំនឿខ្លួន និងចំណេះដឹងថ្មីក្នុងការបន្តជំនឿទៅ បងប្អូនជំនាន់ក្រោយដែលចង់ដឹងពីព្រះយេស៊ូ»។

បងប្រុស ហុង បន្ថែមទៀតថា «កម្មវិធិសិក្ខាសាលានេះ បានជាជួយលើកទឹកចិត្តដល់គ្រូអប់រំជំនឿទាំងអស់ ដែលបានចំណាយពេលវេលាច្រើន ក្នុងប្រកាសដំណឹងល្អតាមរយៈការបង្រៀន ឲ្យបន្តយកចិត្តទុក និងពោរពេញដោយអំណរសប្បាយ ក្នុងបេសកកម្មដែលខ្លួនកំពង់តែបំពេញកន្លងមក»។

ព្រះសហគមន៍ភូមិភាគកំពង់ចាម បានរៀបចំកម្មវិធីនេះរៀងរាល់ ២ ឬ៣ខែម្តងជារៀងរាល់ឆ្នាំ តែដោយសាយវិបត្តិកូវីដ១៩ សកម្មភាពជាច្រើនរបស់ព្រះសហគមន៍ក៏ត្រូវបានផ្អាកមួយរយៈ។ ហើយកម្មសិក្ខាសាលាកាលពីថ្ងៃទី១៦កន្លងទៅ រៀបចំដោយគណៈកម្មាអប់រំជំនឿភូមិភាគកំពង់ចាម ដែលធ្វើជាលើកទី៣ ក្នុងឆ្នាំនេះ ក្រោមវត្តមាន បងស្រី អាញ៉េស ស្រី សុជាតិ ជាអ្នកពន្យល់ និងណែនាំ៕

# គ្រួសារស្រឡាញ់ឈើឆ្កាងព្រះយេស៊ូទទួលណូវីស៣រូប






*អត្ថបទ៖ ព្រះសហគមន៍កាតូលិក*

ក្រុមគ្រួសារដូនជី អ្នកស្រឡាញ់ឈើឆ្កាងព្រះយេស៊ូក្នុងភូមិភាគកំពង់ចាម បានរៀបចំកម្មវិធីទទួលណូវីសចំនួន៣រូប ដើម្បីអប់រំក្លាយជាដូនជីកាតូលិកនាពេលខាងមុខ នាថ្ងៃដែលព្រះសហគមន៍កាតូលិកសកលប្រារព្ធបុណ្យលើកតម្កើងឈើឆ្កាង ព្រះយេស៊ូ នៅថ្ងៃទី១៤ ខែកញ្ញាឆ្នាំ២០២១ នៅផ្ទះណូវីសក្នុងក្រុងកំពង់ចាម។

យុវនារីទាំងបីរូបនោះរួមមាន តេរេសាឃឹម សុខា ជាណូវីសឆ្នាំដំបូង និងពីររូបទៀត គឺក្លារ៉ាយាន កញ្ញា និងក្លារ៉ាដួត ស្រីឡៃ ជាណូវីសឆ្នាំបញ្ចប់។

កម្មវិធីនេះ រៀបចំឡើងក្រោមអធិបតីភាពរបស់លោកអភិបាលប្រ៊ុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។

អភិបាលប្រ៊ុយណូ មានប្រសាសន៍ថា លោកសូមអរគុណក្រុមបងស្រីនិងអស់អ្នកដែលបានគាំទ្រទាំងកំលាំងកាយនិងចិត្ត និងអរព្រះគុណព្រះជាម្ចាស់ដែលនាំឲ្យយុវនាទីបីនាក់ស្គាល់ផ្លូវមួយសម្រាប់ជីវិត។

លោកអភិបាលបន្ថែមថា «សូមបងស្រីបង្ហាញផ្លូវដល់យើង បន្តផ្តល់សក្ខីភាពអំពីគម្រោងការណ៍ដ៏ពិសេសរបស់ព្រះជាម្ចាស់តាមរយៈឈើឆ្កាងឲ្យយើងយល់កាន់តែច្បាស់គម្រោងការណ៍របស់ព្រះអង្គសម្រាប់យើងទាំងអស់គ្នា» ។

តេរេសា ឃឹម សុខា ជាបេក្ខនារី ណូវីសឆ្នាំទី១ បានឲ្យដឹងថា ឆន្ទៈរបស់គាត់គឺធ្វើជាដូនជីកាតូលិក ទោះបីជាក្រុមគ្រួសារអ្នកបួសរបស់គាត់ត្រូវបានរំសាយកាលពីឆ្នាំ២០១៧ គឺក្រោយ២ឆ្នាំ ដែលយុវនារីរូបនេះ បានថ្វាយពាក្យសច្ចាប្រណិធានលើកដំបូងរួច។

ក្នុងរយៈពេល៤ឆ្នាំមកនេះ សុខាបានទៅកន្លែងជាច្រើនរបស់ក្រុមគ្រួសារអ្នកបួស ដើម្បីស្វែងរកការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះគាត់។ ទោះបីវ័យ៣៧ឆ្នាំហើយក៏ដោយ ក៏នាងនៅតែមានចិត្តសង្ឃឹមជានិច្ច និងជឿជាក់លើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ក្នុងជីវិតជាអ្នកបួស។

តេរេសា ឃឹម សុខា បានឲ្យដឹងថា ក្រុមគ្រួសារថ្មីនេះមាន លក្ខណៈជាបងប្អូន ដោយបម្រើព្រះសហគមន៍ និងស្តាប់បង្គាប់លោកអភិបាល ដូចគ្នានឹងសច្ចាទាំងបី ដែលគាត់បានធ្វើជាមួយក្រុមគ្រួសារព្រះមាលា។ យុវនារីរូបនេះបញ្ជាក់ថា «អ្វីដែលនាងខ្ញុំទទួលគឺបងស្រីនៅទីនេះ ជាជនជាតិខ្មែរ។ ពេលបងស្រីថារីនណែនាំ គាត់ប្រើភាសាខ្មែរ គាត់បង្រៀន ហើយគាត់ធ្វើ អីចឹងខ្ញុំយល់ច្រើនជាងដែលខ្ញុំរស់នៅជាមួយបរទេស»។

សុខា បានរំលឹកអំពីទិសដៅរបស់គាត់យ៉ាងដូច្នេះថា «អ្វីដែលឲ្យខ្ញុំបន្តនិងមានក្តីសង្ឃឹមដល់សព្វថ្ងៃនេះ គឺខ្ញុំនឹកឃើញពាក្យសច្ចារបស់ខ្ញុំដែលបានសច្ចាលើកដំបូងជាមួយព្រះជាម្ចាស់នៅក្រុមគ្រួសារបងស្រីព្រះមាលា។ ដូច្នេះ ខ្ញុំចង់គោរពនិងចង់បម្រើព្រះអង្គ តាមអ្វីដែលនាងខ្ញុំ(ត្រូវ)លីឈើឆ្កាងបន្តទៀត»។

ក្លារ៉ា យាន កញ្ញា ជាណូវីសឆ្នាំទី២ ដែលជាឆ្នាំបញ្ចប់ការសិក្សា ត្រៀមខ្លួនដើម្បីថ្វាយពាក្យសច្ចាប្រណិធាន នាពេលខាងមុខនេះ បានឲ្យដឹងថា គាត់នឹងខិតខំប្រឹងប្រែងធ្វើយ៉ាងណារស់នៅស្របតាមការណែនាំរបស់ក្រុមគ្រួសារអ្នកបួស តាមព្រះបន្ទូលរបសព្រះជាម្ចាស់ «និងធ្វើឲ្យដំណើរជីវិតនៃការត្រាស់ហៅនេះ រស់រវើក និងបន្តដំណើរពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីក្លាយជាបងស្រីនាពេលអនាគត»។

ក្រុមដូនជីមានវត្តមានក្នុងប្រទេសកម្ពុជាជាលើកទី២ ក្នុងអំឡុងឆ្នាំ១៩៩០ ដោយមានដូនជីនកាតូលិកក្រុមគ្រួសារអ្នកស្រលាញ់ព្រះឈើឆ្កាងមកពីប្រទេសថៃ មកតាំងនៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម គឺលោកយាយ សាវីយេ និង លោកយាយប៉េឡាជី។ បច្ចុប្បន្នក្រុមគ្រួសារនេះ មានសមាជិកដូនជីបម្រើការងារនៅក្នុងភូមិភាគកំពង់ចាមចំនួន៦នាក់ និងមានណូវីសចំនួន៣នាក់។ ចំពោះដូនជីពីររូបដែលមកពីប្រទេសថៃនាទសវត្សទី៩០ លោកយាយ សាវីយេ និងលោកយាយប៉េឡាជី បានវិលត្រលប់ទៅប្រទេសថៃវិញ នៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៨ ៕

# អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ណែនាំយុវជនឱ្យរស់នៅក្នុងក្ដីសង្ឃឹម ជំនឿ និងមេត្តាករុណា

*អត្ថបទ៖ ដាលីស*

លោកអភិបាលអូលីវីយេ ជ្មីតហាស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានធ្វើការណែនាំទៅដល់យុវជន-យុវនារី តាមរយៈសន្និបាតយុវជនតាមប្រព័ន្ធអនឡាញមានរយៈពេល៣ថ្ងៃ ដែលបានរៀបចំឡើងក្រោមប្រធានបទ «យុវជនជាកម្លាំងព្រះសហគមន៍» ដើម្បីរិះគិតជាមួយគ្នាពីស្ថានភាពបច្ចុប្បន្ន។

កម្មវិធីនេះដឹកនាំដោយលោកអភិបាលអូលីវីយេ រួមជាមួយនឹងការិយាល័យយុវជនជំទង់ និងកុមារភូមិភាគភ្នំពេញ ដែលមានយុវជនភូមិភាគភ្នំពេញទាំង៩មណ្ឌលសកម្មភាពបានចូលរួម និងមានការចូលរួមជាមួយនឹងតំណាងយុវជនមកពីភូមិភាគបាត់ដំបង និងភូមិភាគកំពង់ចាម ដែលសរុបប្រមាណជាង ២០០នាក់កាលពីថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១កន្លងមកនេះ។








នៅក្នុងសន្និបាតនេះដែរ ដែលលោកអភិបាលបានណែនាំដល់យុវជនដោយលោកបានស្នើឱ្យយុវជនរិះគិតនូវចំណុចចំនួន៣សំខាន់គឺ សេចក្ដីសង្ឃឹម ជំនឿ និងមេត្តាករុណា។ លើសពីនេះទៅទៀតលោកអភិបាលអូលីវីយេ ក៏បានផ្ដល់នូវគំនិតដើម្បីរិះគិតនៅក្នុងស្ថានភាពបច្ចុប្បន្នតាមរយៈការគិតពីគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ពីដើមរៀងមក។







លោក អូលីវីយេ បានលើកយកអត្ថបទព្រះគម្ពីរមកពន្យល់អំពីស្ថានភាពរបស់មនុស្សថា ៖ «កាលសម័យដើមអាដាំនិងអេវ៉ាមានសេចក្ដីសុខ ប៉ុន្តែក្រោយមកមនុស្សចាប់ផ្ដើមប្រណែន បាត់បង់សេចក្ដីសុខ។ លោកអេសាយជាព្យាការី ដែលថ្លែងពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលចង់បង្កើតពិភពថ្មី ដែលមានយុត្តិធម៌ មនុស្សចេះស្រឡាញ់គ្នា សត្រូវអាចរស់នៅជាមួយគ្នាបាន ដែលពោរពេញដោយសុភមង្គល»។





លោកបានបន្តថា ជាព្រះជាម្ចាស់បានណែនាំឱ្យគ្រប់គ្នាមានសេចក្ដីសុខជាមួយឪពុកម្ដាយដែលនៅជាមួយអ្នក ដែលស្រឡាញ់អ្នក ហើយអ្នកមានថ្ងៃកំណើតមួយទៀត គឺថ្ងៃទទួលអគ្គសញ្ញាជ្រមុជទឹក គឺកើតសាជាថ្មី ដើម្បីចូលក្នុងគម្រោងការរបស់ព្រះជាម្ចាស់។

លោកបានបញ្ជាក់បន្ថែមថា៖«សេចក្ដីសង្ឃឹមរបស់យើង គឺណែនាំឱ្យយើងចូលនៅក្នុងគម្រោងការរបស់ ព្រះជាម្ចាស់ ដែលជាពិភពដែលព្រះជាម្ចាស់បង្កើតដោយនាំឱ្យចេះទទួលខុសត្រូវ, ចេះថែរក្សាគ្នាទៅវិញទៅមក, ជាពលរដ្ឋរស់នៅក្នុងសង្គមប្រកបដោយយុត្តិធម៌ ដោយដឹងថាមនុស្សទាំងអស់មានតម្លៃថ្លៃថ្នូរ នាំឱ្យមនុស្សទាំងអស់ចេះរស់នៅជាគ្រួសារតែមួយ ដោយចេះគោរពគ្នាទៅវិញទៅមក ចេះជួយគ្នាទៅវិញ ទៅ មក ដោយស្រឡាញ់មនុស្សទាំងអស់ ស្រឡាញ់ខ្មាំងសត្រូវ»។





លោកអភិបាលដដែលរូបនេះបានបន្ថែមទៀតថា ដើម្បីឱ្យសេចក្ដីស្រឡាញ់នេះលូតលាស់ លុះត្រាតែគ្រប់គ្នាចេះលើកលែងទោស។ ព្រះជាម្ចាស់ផ្ទាល់បានមកកើតជាមួយម ដើម្បីបង្រៀនឱ្យចេះស្រឡាញ់ និងលើកលែងទោស។

នៅក្នុងការអប់រំនេះ លោកអភិបាលអូលីវីយេ បានបញ្ជាក់ថា ៖ «ជីវិតរបស់យើងទៅមុខដោយមានជំនឿ និងសេចក្ដីសង្ឃឹម ហើយមេត្តាករុណាណែនាំឱ្យយើងមានភាពកែច្នៃប្រឌិតជានិច្ចដោយសន្តិភាព។ យើងអាចធ្វើបានលុះត្រាតែយើងអនុវត្តយ៉ាងសកម្មបំផុត»។

គួរបញ្ជាក់ផងដែរថា នេះជាលើកទីមួយហើយដែលព្រះសហគមន៍ភូមិភាគភ្នំពេញបានរៀបចំសន្និបាតយុវជនតាមប្រព័ន្ធអនឡាញ ដើម្បីសម្របខ្លួនជាមួយនឹងបរិបទសង្គមនាពេលបច្ចុប្បន្ននេះ៕

# សមាគមសប្បុរសធម៌សន្តវ៉ាំងសង់ដឺប៉ូលកម្ពុជាប្រារព្ធខួបលើកទី៣៦១ ជាមួយនឹងសម្មភាពជួយជនក្រីក្រដើម្បីរំឭកដល់សន្តវ៉ាំងសង់ដឺប៉ូល

*អត្ថបទ៖ ដាលីស*

យុវជននៃសមាគមសប្បុរសធម៌សន្តវ៉ាំងសង់ដឺប៉ូលកម្ពុជា បានប្រារព្ធខួបលើកទី៣៦១នៃមរណភាពសន្តវ៉ាំងសង់ដឺប៉ូល កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ ដោយត្រូវបានបែងចែកជា៣ក្រុមតាមភូមិភាគនីមួយៗ មាន រាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តកំពង់ចាម។




អ្នកសម្របសម្រួលថ្នាក់ជាតិនៃក្រុមសន្តវ៉ាំងសង់ដឺប៉ូលកម្ពុជា កញ្ញា ឃឹម សុខឃីម បានប្រាប់ឱ្យដឹងថា ការការប្រារព្ធខួបនេះ ជាការរំលឹកដល់សកម្មភាពមួយចំនួនដែលសន្តវ៉ាំងសង់ដឺប៉ូលបានធ្វើជាមួយអ្នកក្រីក្រ ការរំលឹកអំពីធម៌មេត្តាករុណា និងសេចក្តីស្រឡាញ់ដែលលោកជាគំរូដ៏ល្អ សម្រាប់យុវជន ហើយលោកក៏បានលើកទឹកចិត្តដល់យុវជន កុមារ ក្នុងការចែករំលែកនូវអំណោយទានរបស់ខ្លួនក្នុងការជួយអ្នកដទៃផងដែរ។

កញ្ញា សុឃីម បានបន្តថា ៖ «ខ្ញុំយល់ឃើញថា ទោះបីជាក្នុងស្ថានភាពនៃការរីករាលដាលវីរុសកូវីដ១៩ក្តី តែក្រុមសមាជិកវ៉ាំងសង់ដឺបូលនៅតែព្យាយាមបន្តសកម្មភាពសប្បុរសជាមួយនឹងបងប្អូនដែលខ្វះខាតដោយគោរពតាមសេចក្តីណែនាំរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់ការរាតត្បាតនៃវីរុសកូវីដ១៩»។

កញ្ញាបានអំពាវនាវដល់អ្នកចូលរួមបម្រើដល់អ្នកដែលខ្វះខាត និងត្រូវការជំនួយតាមរយៈការស្ម័គ្រចិត្តសហការ និងចំណាយពេលវេលាចែករំលែកជួយគ្នាទៅវិញទៅមក។

អ្នកសម្របសម្រួលរូបនេះបានលើកឡើងថា៖ «ខ្ញុំសូមថ្លែងអំណរគុណដល់លោកអភិបាលអូលីវីយ៉េ ដែលជាអភិបាលណែនាំជីវិតខាងផ្លូវវិញ្ញាណនៃក្រុមសន្តវ៉ាំងសង់ដឺបូល លោកអភិបាលទាំងអស់ លោកបូជា បងប្រុសបងស្រីដែលបានគាំទ្រ កម្មវិធីនៃក្រុមសន្តវ៉ាំងសង់ដឺប៉ូលកម្ពុជាឱ្យមានដំណើរការទៅមុខ»។

ការរំឭកខួបនេះត្រូវបានរៀបចំតាមរយៈសមក្មភាពមួយចំនួនដូចជា ថ្វាយអភិបូជាតាមក្រុមនីមួយ, ការទៅសួរសុខទុក្ខអ្នកជំងឺនិងចាស់ជរា, ផ្តល់ការឧត្ថម្ភដល់សិស្សក្រីក្រ, ជួសជុលសាលាបឋមសិក្សា និងមានការចែកគ្រឿងបរិភោគទៅដល់អ្នកដែលខ្វះខាត និងត្រូវការ មានអង្ករ ទឹកត្រីមី ពងទា ជាដើម។

ជាមួយគ្នានេះដែរ លោក ផាន ប៉ូរ៉ា សមាជិកក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃសមាគមសប្បុរសធម៌សន្តវ៉ាំងសង់ដឺប៉ូល បានរៀបរាប់ឱ្យដឹងផងដែរថា ក្រុមសន្តវ៉ាំងសង់ដឺប៉ូល បានចូលមកកម្ពុជានាឆ្នាំ២០០២ តាមរយៈក្រុមគ្រួសារបងស្រីបុត្រីមេត្តាករុណា និងបង្កើតសមាគមសប្បុរសធម៌សន្តវ៉ាំងសង់ដឺប៉ូលឆ្នាំ២០០៤ ។

លោកបានបន្តថា ដោយមានការគាំទ្រពីលោកអភិបាលអេមីលដេតុម្ប និងក្រោយមកត្រូវបានចុះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃនាឆ្នាំ២០១៩ ។

លោក ផាន ប៉ូរ៉ា បានបន្ថែមថា ក្រុមនេះមានសមាជិក ទាំងចាស់និងក្មេងជាង៤០០នាក់ ដែលជាអ្នកស្ម័គ្រចិត្ត និងមានសាសនាផ្សេងៗពីគ្នាចូលរួមសកម្មភាពជាមួយគ្នា។

លោកថា ៖ «ក្នុងរយៈពេលកន្លងមកនេះ ក្រុមយើងទទួលបាននូវសមិទ្ធិផលមួយចំនួនដូចជាផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ៤០០នាក់ ជួយធ្វើផ្ទះជនក្រីក្រចំនួនជាង៣០០ខ្នង ផ្តល់ម្ហូបអាហារប្រចាំខែដល់ចាស់ជរា និងអ្នកជំងឺជារៀងរាល់ខែ»។

លោក ផាន ប៉ូរ៉ា បានបញ្ជាក់ថា សមាគមសប្បុរសធម៌សន្តវ៉ាំងសង់ដឺប៉ូលកម្ពុជា មានប្រទេសអូស្ត្រាលីជាដៃគូ និងក្រុមប្រឹក្សាអន្តរជាតិនៃសមាគមសន្តវ៉ាំងសង់ដឺប៉ូលក្នុងការសម្របស្រួលលើផ្នែកហិរញ្ញវត្ថុ ដោយរួមជាមួយថវិការដែលក្រុមលោករកនៅក្នុងស្រុកតាមរយៈសកម្មភាពចិញ្ចឹមក្រពើ និងលក់សម្លៀកបំពាក់ក៏ដូចជាសកម្មភាពជិះកង់សប្បុរសធម៌ និងការដាក់ដង្វាយសម្ងាត់ដើម្បីជួយផងដែរ។

# ព្រះសហគមន៍កាតូលិកក្រុងកំពត ជួយពលរដ្ឋខ្វះខាតចំនួន៧៩គ្រួសារ ក្នុងខែកញ្ញា

*អត្ថបទ៖ ដាលីស*

សមាជិកគណៈកម្មការសង្គហនៃព្រះសហគមន៍កាតូលិកក្រុងកំពត បានប្រាប់ឱ្យដឹងថា ក្នុងមួយខែពេញនៃកញ្ញាឆ្នាំ ២០២១ នេះ ព្រះសហគមន៍កាតូលិកក្រុងកំពត ខេត្តកំពត បានជួយដល់គ្រួសារក្រីក្រ ចំនួន៧៥គ្រួសារ ក្នុង៤តំបន់ផ្សេងៗគ្នា។

កញ្ញា ញ៉ែម សុភាព សមាជិកនៃគណៈកម្មការសង្គហនេះបានប្រាប់ RVAKhmer ថា គ្រួសារទាំង៧៥ដែលទទួលបានជំនួយពីព្រះសហគមន៍កាតូលិកក្រុងកំពត មានគ្រួសារចំនួន ៣២គ្រួសារនៅសង្កាត់អូរតូច ចំនួន១៦គ្រួសារនៅសង្កាត់កំពង់កណ្តាល ចំនួន១៥គ្រួសារក្នុងសង្កាត់ត្រើយកោះ និង១២គ្រួសារផ្សេងទៀតនៅភូមិកំពង់ត្នោត។

ជាក់ស្តែង នៅព្រឹកថ្ងៃទី៣០ ខែកញ្ញានេះ ព្រះសហគមន៍កាតូលិកក្រុងកំពត បានធ្វើការចែកសម្ភារៈ និងគ្រឿងបរិភោគ ដល់ប្រជាពលរដ្ឋដែលមានការខ្វះខាតចំនួន ១៥គ្រួសារ នៅសង្កាត់ត្រើយកោះ ក្នុងក្រុងកំពត ដែលសកម្មភាពនេះដឹកនាំដោយលោកឪពុក អាឡិចសាន់ដ្រូ និងមានការចូលរួមពីសំណាក់យុវជនសប្បុរសធម៌សន្តវ៉ាំងសង់ដឺប៉ូល និងអាជ្ញាធរមូលដ្ឋានផងដែរ។

កញ្ញា ញ៉ែម សុភាព បានបញ្ជាក់ពីទឹកចិត្ត និងបទពិសោធន៍ជំនឿរបស់ខ្លួនក្នុងសកម្មភាពទាំងអស់នេះថា កញ្ញាមានអំណរសប្បាយនៅពេលបានរៀបចំសកម្មភាពជួយជនក្រីក្រខ្វះខាត ដែលជាឱកាសមួយសម្រាប់កញ្ញាក្នុងការបង្ហាញពីសក្ខីភាពនៃជំនឿរបស់ខ្លួនជាគ្រីស្តបរិស័ទកាតូលិក ដែលស្រឡាញ់មនុស្សឯទៀតៗដូចជាបងប្អូនបង្កើត។





កញ្ញាថា ៖ «ខ្ញុំមានអំណរសប្បាយនៅពេលបានរៀបចំសកម្មភាពជួយបងប្អូនក្រីក្រខ្វះខាតដែលជាឱកាសមួយជួយខ្ញុំឱ្យបង្ហាញពីសក្ខីភាពនៃជំនឿរបស់ខ្ញុំជាគ្រីស្តបរិស័ទមកពីព្រះសហគមន៍កាតូលិក ហើយពិតមែនយើងស្រឡាញ់បងបង្អូនឯទៀតៗដូចជាបងប្អូនរបស់យើង»។

សមាជិកគណៈកម្មការសង្គហនៃព្រះសហគមន៍កាតូលិកក្រុងកំពត បានបន្តទៀតថា ៖ «ការជួយបងប្អូនខ្វះខាតជាអ្វីដែលខ្ញុំខ្នះខ្នែងជាងការងារផ្សេងទៀត ហើយខ្ញុំចូលចិត្តនិងសប្បាយចិត្តព្រោះអត្ថន័យ នៅពេលបងប្អូនក្រីក្រញញឹមមិនមែនត្រឹមតែអំណោយតិចតួចតែប៉ុណ្ណឹងទេ ប៉ុន្តែសម្រាប់អ្នកក្រីក្រគឺជាអំណរសប្បាយដ៏ធំធេង»។

កញ្ញា ញ៉ែម សុភាពបានធ្វើការលើកឡើងថា កញ្ញាមានអំណរសប្បាយ គឺប្រៀបបានទៅនឹងការឃើញជួបព្រះយេស៊ូ ហើយគ្រួសារទាំងនេះតែងតែរំឭកជានិច្ចពីសកម្មភាពនានា ដែលព្រះសហគមន៍បានធ្វើចំពោះពួកគាត់។

កញ្ញាថា ៖ «នេះជាសញ្ញាមួយដែលបង្ហាញពីសេចក្តីស្រឡាញ់ពិតមែន»។

សម្ភារដែលគ្រួសារនីមួយៗទទួលបានមានអង្ករ២០គីឡូ ប្រេងឆា ទឹកស៊ីអ៊ីវ សាប៊ូ និងថវិកាមួយចំនួនផងដែរ។ សម្ភារទាំងនេះទទួលបានការឧត្ថម្ភក្រុម ATCS (A Call To Share) ពីប្រទេសសិង្ហបុរី ហើយក្រុមActs តែងជួយដល់អ្នកក្រីក្រជារៀងរាល់ឆ្នាំទាំងថវិកា និងធនធានមនុស្ស តាំងពីឆ្នាំ២០១៧មក៕

# លាង រស្មី៖ «សកម្មភាពរបស់គ្រីស្តបរិស័ទធ្វើឲ្យខ្ញុំមានជំនឿលើព្រះយេស៊ូគ្រីស្ត»

*អត្ថបទ៖ ឆាក លាំង*

កញ្ញា លាង រស្មី វ័យ៣២ឆ្នាំ ជាកូនសែស្រឡាយចិនរស់នៅរាជធានីភ្នំពេញ មានបងប្អូនស្រីចំនួនពីរនាក់។ ការរស់នៅក្នុងជំនឿខុសពីគ្រួសារ មានការលំបាកជាខ្លាំង។ សព្វថ្ងៃនេះ នាងមានជំនឿលើសាសនាគ្រីស្ត និកាយកាតូលិក ខុសពីក្រុមគ្រួសារដែលជឿលើពុទ្ធសាសនា។



កញ្ញា បានរៀបរាប់អំពីមូលហេតុនៃការផ្លាស់ប្តូរជំនឿថា៖ «ខ្ញុំបានស្គាល់ព្រះយេស៊ូតាមរយៈសកម្មភាពរបស់គ្រីស្តបរិស័ទមួយរូបក្នុងឆ្នាំ២០០៥។ គាត់ជាអ្នកជិតខាងល្អម្នាក់ ដែលតែងតែចាប់អារម្មណ៍អ្នកនៅជុំវិញ ជាពិសេសក្មេង។ ហើយសាវ័កព្រះយេស៊ូរូបនោះ បាននាំខ្ញុំមកព្រះវិហា និងរៀនអប់រំជំនឿជាមួយក្មេងដទៃទៀត»។

កញ្ញា លាង រស្មី បានប្រាប់ទៀតថា៖ «ដំបូងឡើយខ្ញុំគិតថា ចង់មានមិត្ត ចង់លេង និងបានរៀនតែប៉ុណ្ណោះ តែក្រោយទទួលការអប់រំ នាងខ្ញុំបានស្គាល់ព្រះយេស៊ូកាន់តែច្រើន។ ក្រោយការអប់រំ មួយរយៈព្រះវិញ្ញាណបានជំរុញឲ្យខ្ញុំស្រលាញ់ជីវិតជាគ្រីស្តបរិស័ទ និងស្រលាញ់ព្រះយេស៊ូក៏សម្រេចចិត្តទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឆ្នាំ២០១០ នៅព្រះសហគមន៍កាតូលិកផ្សារតូច»។

សព្វថ្ងៃនេះ រស្មីរស់នៅជាមួយឪពុកម្តាយនិងប្អូនស្រី។ នាងបានរំលឹកថា មុននឹងក្លាយជាគ្រីស្តបរិស័ទគាត់ជួបនិងការលំបាកជាខ្លាំង ព្រោះឪពុកម្តាយរបស់គាត់មិនព្រមឲ្យប្តូរជំនឿ។ ពួកគាត់តែងប្រើឲ្យធ្វើការងារផ្សេងៗ ដើម្បីហាមឃាត់មិនឲ្យទៅព្រះវិហារ ឬទៅអប់រំជំនឿជាដើម។ រស្មីបន្ថែមថា "ហើយពេលខ្លះខ្ញុំដូចជាមានតែម្នាក់ក្នុងគ្រួសារ ព្រោះតែមានជំនឿខុសពីគេ"។

កញ្ញា លាង រស្មី បានបន្ថែមថា «ពេលមានបង ឬប្អូនក្នុងគ្រួសារឈឺ ពួកគាត់ថា «មកពីខ្ញុំ! ខ្ញុំប្តូរសាសនា ទើបមានរឿងនេះកើតឡើង។ វាជាពេលវេលាលំបាកមួយ និងឈឺចាប់ណាស់ ព្រោះគ្រួសារអត់និយាយជាមួយ និងមិនសូវចាប់អារម្មណ៍លើខ្ញុំ»។

គ្រីស្តបរិស័ទរូបនេះបន្ថែមទៀតថា ពេលនោះកញ្ញាតែងអធិដ្ឋានសុំព្រះយេស៊ូជួយដោះស្រាយរឿងនេះ។ ក្រោយមកការទូលអង្វររបស់នាងបានចេញជារូបរាង គឺមានគ្រីស្តបរិស័ទម្នាក់ ជាអ្នកជិខាង និងស្គាល់គ្នាជាមួយម្តាយនាងបានជួយនិយាយ ហើយនាងក៏បានទៅព្រះវិហារ និងទទួលការអប់រំធម្មតាវិញ។

ចាប់តាំងពីក្លាយជាគ្រីស្តបរិស័ទ កញ្ញា លាង រស្មី សព្វថ្ងៃកំពុងអប់រំជំនឿដល់ក្មេងៗ និងជួយដល់កិច្ចការមួយចំនួនទៀតដល់ព្រះសហគមន៍។

យុវនារីរូបនេះ បានរៀបរាប់បន្ថែមទៀតថា កាលដើមឡើយ គាត់ជាមនុស្សដែលអាត្មានិយម ធ្វើអ្វីតាមចិត្តខ្លួនចង់មិនចាប់អារម្មណ៍អ្នកជិតខាងឡើយ ប៉ុន្តែក្រោយពីទទួលការអប់រំពីព្រះសហគមន៍ រហូតបានទទួលអគ្គសញ្ញាជ្រមុជទឹក ជីវិតបានការផ្លាស់ប្តូរជាច្រើន។

កញ្ញា រស្មី បានបញ្ជាក់ថា ៖ «ខ្ញុំយល់ពីក្តីស្រឡាញ់ ការលើកលែងទោស ចូលចិត្តធ្វើការងាររួម ស្តាប់ និងទទួលរាល់ពាក្យទូន្មានពីមនុស្សជុំវិញខ្លួន ហើយអ្វីដែលកាន់តែពិសេសនោះ ព្រះយេស៊ូបានបង្រៀនខ្ញុំឲ្យប្រើក្តីស្រឡាញ់នេះក្នុងជីវិត រហូតឪពុកម្តាយទទួលយកការសម្រេចចិត្ត និងគាំទ្រជំនឿដែលខ្ញុំបានជ្រើសរើស»។

នៅថ្ងៃអនាគត កញ្ញានឹងព្យាយាមបន្តជំនឿទៅមនុស្សផ្សេងៗទៀត តាមរយៈការបង្រៀនអប់រំជំនឿ ឲ្យគេបានស្គាល់ពីព្រះយេស៊ូឲ្យកាន់តែទូលំទូលាយ និងខិតខំជួយដល់ការងារព្រះសហគមន៍ ដូចជាក្រុមពិធីបុណ្យ ក្រុមសង្គហៈជាដើម....»៕

# SIGNIS ប្រកាសអបអរជ័យលាភីពានរង្វាន់ណូបែលសន្តិភាពដល់អ្នកសារព័ត៌មាន

*អត្ថបទ៖ ព្រះសហគមន៍កាតូលិក*

សមាគមប្រព័ន្ធផ្សព្វផ្សាយកាតូលិកពិភពលោក ដែលហៅកាត់ថា ស៊ីកនីស ( SIGNIS) បានប្រកាសចូលរួមអបអរដល់អ្នកសារព័ត៌មានដែលបានទទួលពានរង្វាន់ណូបែលសន្តិភាពពិភពលោកឆ្នាំ២០២១ ។

ស៊ីកនីស បានប្រកាសចូលរួមអបអរលោកស្រី ម៉ារៀ រ៉េសា (Maria Ressa ) ដែលជាអ្នកសារព័ត៌មានជនជាតិហ្វីលីពីន និងលោក ឌីមីទ្រី ម៉ូរ៉ាតូវ (Dmitry Muratov) ដែលជាអ្នកសារព័ត៌មានជនជាតិរុស្ស៊ី ក្រោយពេលដែលពួកគេទាំងពីរបានព្យាយាម ការពារសិទ្ធិនៃការបញ្ចេញមតិ ដែលជាសមាសធាតុដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ និងសន្តិភាព។

លោក ស្រី ម៉ារៀ រ៉េសា ត្រូវបានគេដឹងថា គឺជាស្ថាបនិកក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយឌីជីថល មួយរបស់ហ្វីលីពីន ដែលមានឈ្មោះថា Rappler។ ក្នុងនាមជាអ្នកសារព័ត៌មាននិងជានាយកប្រតិបត្តិរបស់ Rappler លោកស្រីបានធ្វើការដើម្បីបង្ហាញពីការរំលោភអំណាច ការប្រើប្រាស់អំពើហិង្សានិងការកើនឡើងនូវអំណាចផ្តាច់ការនៅក្នុងប្រទេសកំណើតរបស់លោកស្រី គឺប្រទេសហ្វីលីពីន។ លោកស្រីក្លាហាននៅក្នុងការប្រើប្រព័ន្ធផ្សព្វផ្សាយដើម្បីរិះគន់របបលោកប្រធានាធិបតី រ៉ូឌ្រីហ្គោ ឌូឌឺតេ ចំពោះយុទ្ធនាការប្រឆាំងគ្រឿងញៀនដែលបណ្តាលឲ្យមានសម្លាប់មនុស្សដ៏រង្គាលនៅក្រៅប្រព័ន្ធតុលាការ។

ដោយឡែក លោក ឌីមីទ្រី ម៉ូរ៉ាតូវ គឺជានិពន្ធនាយកនៃកាសែត Novaja Gazeta ដែលជាសារព័ត៌មានមួយហ៊ានរាយការណ៍យ៉ាងធ្ងន់ធ្ងរអំពីអំពើពុករលួយ ការចាប់ខ្លួនខុសច្បាប់ ការលួចបន្លំការបោះឆ្នោត និងអំពើហិង្សា។ ទោះបីជាអ្នកយកព័ត៌មានរបស់ទស្សនាវដ្តីចំនួន ៦ នាក់ត្រូវបានសម្លាប់ចាប់តាំងពីការបង្កើតឡើងក្នុងឆ្នាំ ១៩៩៣ ទោះយ៉ាងណាក៏ដោយក៏នៅតែបន្តការពារសេរីភាពអ្នកសារព័ត៌មានឱ្យចូលរួមក្នុងវិស័យសារព័ត៌មានដោយផ្អែកលើការពិត។

សម្រាប់ការអបអរនេះ ស៊ីកនីសមើលឃើញថាសហសេវិកទាំងពីរនាក់នេះជាគំរូនៃអាជីពអ្នកកាសែតដើម្បីរាយការណ៍ការពិតដែលជាប្រវត្តិសាស្ត្រតែងតែត្រូវបានគំរាមកំហែងដោយផលប្រយោជន៍នយោបាយ សេដ្ឋកិច្ចនិងសូម្បីតែសាសនា ហើយសង្ឃឹមថាអ្វីដែលអ្នកទាំងពីរបានលះបង់ នឹងជម្រុញឱ្យបណ្តាញអ្នកជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយនៅលើ ពិភពលោក បន្តការពារសេរីភាពក្នុងការបញ្ចេញមតិនិងតវ៉ារាល់ការវាយប្រហារលើអ្នកកាសែតដែលស្វែងរកការពិតសម្រាប់សង្គម៕

# លោក ញែម ធា៖ «ជីវិតរបស់យើងម្នាក់ៗតែងតែផ្សារភ្ជាប់ទៅនឹងទំនាក់ទំនង ហេតុនេះយើងត្រូវតែចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក»

*អត្ថបទ៖ ឆាក លាំង*

លោក ញែម ធា ជាកូនប្រុសម្នាក់ក្នុងចំណោមបងប្អូនស្រីចំនួន៧នាក់ នៅក្នុងគ្រួសារពុទ្ធបរិស័ទ ដែលមានស្រុកកំណើតក្នុងភូមិសំរោងខាងកើត ឃុំគោគព្រិច ស្រុកគីរីវង្ស ខេត្តតាកែវ។

យុវជនវ័យ៣១ឆ្នាំរូបនេះ បាននិយាយពីប្រវត្តិជំនឿរបស់ខ្លួនដែលជ្រើសរើសជឿលើសាសនាគ្រីស្ត និកាយកាតូលិកថា ដំបូងឡើយខ្លួនបានជឿលើសាសនាព្រះពុទ្ធតាមជីដូនជីតាបងប្អូនឪពុកម្តាយ ដូចប្រជាជនទូទៅដែរ ប៉ុន្តែនៅក្នុងឆ្នាំ២០០៣ វត្តមានព្រះសហគមន៍បានទៅដល់ភូមិដែលខ្លួនរស់នៅតាមរយៈសកម្មភាពចុះសួរសុខទុក្ខរបស់ក្រុមគ្រីស្តបរិស័ទនិងលោកបូជាចារ្យ។

គ្រីស្តបរិស័ទរូបនេះបានបន្តទៀតថា ក្រោយមកខ្លួនបានចូលរៀនស្វែងយល់ជំនឿលើសាសនាព្រះគ្រីស្តពីគ្រូអប់រំជំនឿ បងប្រុសបងស្រី លោកបូជាចារ្យជាច្រើនឆ្នាំ ក៏សម្រេចចិត្តប្តូរមកជាគ្រីស្តបរិស័ទនិងទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឆ្នាំ២០០៩នៅព្រះសហគមន៍ព្រះត្រៃឯកគីរីវង្ស ក្នុងមណ្ឌលសកម្មភាពតាកែវ ខេត្តតាកែវ។

គ្រីស្តបរិស័ទវ័យជាង៣០ឆ្នាំរូបនេះបានថ្លែងថា៖ « ការប្រកាសដំណឹងរបស់ព្រះយេស៊ូតាមរយៈកិច្ចការមនុស្សធម៌ ជួយចាស់ជរា ក្មេងកំព្រាគ្មានទីពឹង អ្នកជំងឺ កសាងផ្លូវ កាសាងសាលារៀន ជាពិសេសការផ្តល់ឱកាសឲ្យកូនអ្នកក្រីក្រនៅជនបទបានទទួលការសិក្សាអប់រំ បានធ្វើឲ្យជីវិតខ្ញុំជឿលើព្រះអង្គ»។

លោក ញែម ធា បានបន្តទៀតថា លោកក៏ជាកូនអ្នកក្រីក្រ ដែលមានភាពខ្វះខាត់ក្នុងជីវភាព ម្នាក់រស់ក្នុងទីជនបទមួយក្នុងស្រុកគីរីវង្ស ខេត្តតាកែវ ដែលបានព្រះសហគមន៍ផ្តល់ឪកាស ឲ្យបានទទួលការសិក្សារហូតចប់ថ្នាក់ឧត្តមសិក្សា នៅសាលារបស់កាតូលិកមួយកន្លែងក្នុងខេត្តតាកែវ ដែលលោកមិនដែលស្រម៉ៃដល់ផងនោះ។

លោកបានបន្តថា ៖ «ក្រោយទទួលអគ្គសញ្ញាជ្រមុជទឹកប្តូរទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ ជីវិតរបស់ខ្ញុំមានការផ្លាស់ប្តូរ វត្តមានរបស់ព្រះយេស៊ូក្នុងជីវិតរស់នៅប្រចាំថ្ងៃជួយឲ្យខ្ញុំប្រែក្លាយជាមនុស្សម្នាក់រឹងមាំ មានទំនួលខុសត្រូវ ខ្ញុំតែងតែផ្តល់ស្នាមញញឹមដល់មនុស្សនៅជុំវិញ»។

លោក ញែម ធា បានរស់នៅជាជីវិតជាគ្រីស្តបរិស័ទតាំងពីឆ្នាំ២០០៩ រហូតមកទល់សព្វថ្ងៃនេះដោយរស់នៅក្នុងចំណោមបងប្អូន ពុទ្ធបរិស័ទជាច្រើន ដែលជាហេតុនាំឲ្យខ្លួនទទួលបានបទពិសោធន៍ជាច្រើននៅក្នុងសង្គម រួមមានការលំបាក ការមើលងាយជាដើម និងចូលរួមកិច្ចសង្គមមួយចំនួនរួមជាមួយមនុស្សជុំវិញខ្លួន។

គ្រីស្តបរិស័ទរូបនេះបន្ថែមថា ៖ «ខ្ញុំជាអ្នកជឿ ព្រះអង្គរ ទ្រង់មិនដែលបោះបង់ចោលខ្ញុំឡើយ ទោះពេលខ្លះមានទុក្ខលំបាក តែក្តីសណ្តោសប្រណីដ៏ធំធេងរបស់នេះ តែងផ្តល់ក្តីសង្ឃឹមជានិច្ចដល់ជីវិតខ្ញុំ។ ហើយសព្វថ្ងៃនេះខ្ញុំបានប្រតិបត្តិជំនឿដោយការភ្ជាប់ជាមួយការអធិដ្ឋាន អានអត្ថបទព្រះគម្ពីរ និងយកព្រះយេស៊ូធ្វើគំរូ»។

លោក ញែម ធា បានបញ្ជាក់ថា ការរស់នៅក្នុងជីវិតជាគ្រីស្តបរិស័ទ រយៈពេលជាង១០ឆ្នាំបានជួបនិងរឿងរ៉ាវជាច្រើន ទាំងសប្បាយ ទាំងទុក្ខព្រួយ ហើយលោកក៏មិនដែលមានគំនិតបោះបង់ព្រះជំនឿឡើយ ដោយសារលោកពេញចិត្តនិងស្រលាញ់ជីវិតជាគ្រីស្តបរិស័ទដូចសព្វថ្ងៃនេះណាស់។ លោកបានគូសបញ្ជាក់យ៉ាងមុតមាំថា ៖ «សម្រាប់ជីវិតជាគ្រីស្តបរិស័ទនាពេលអនាគត ដោយយកព្រះយេស៊ូគ្រីស្តជាគំរូ ខ្ញុំនឹងរស់នៅដោយសេចក្តីស្រលាញ់ ការអត់អោន និងមេត្តករុណា មិនថាជាក្រុមគ្រួសារខ្លួនឯង ឬអ្នកជិតខាងក្នុងសហគមន៍ក៏ដោយ»៕

# គ្រីស្តសាសនានិងពុទ្ធសាសនា ថ្លែងសាររួមគ្នាក្នុង ទិវាសន្តិភាពអន្តរជាតិ លើកទី១៩

*អត្ថបទ៖ ដាលីស*

អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោកអូលីវីយ៉េ ឆ្មីតអឺស្លែរ រួមជាមួយព្រះចៅអធិការវត្តអង្គមន្ត្រី ព្រះអង្គ ង៉ែត ចម្រើន បានរៀបចំវីដេអូរួមគ្នាមួយនៅវត្តអង្គមន្ត្រី និងនៅព្រះវិហារសន្តីម៉ារីញញឹមចំការទៀង ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ក្នុងឱកាសទិវាសន្តិភាពអន្តរជាតិ លើកទី១៩ នាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ ដែលជានិមិត្តសញ្ញាបង្ហាញអំពីសុខដុមរមនារវាងសាសនា និងសាសនានៅប្រទេសកម្ពុជា។

ព្រះតេជគុណ ង៉ែត ចម្រើន បានមានថេរដីកាតាមរយៈវីដេអូនេះ ពីទិវាសន្តិភាពនេះថា ៖ «ថ្ងៃនេះយើងបានជួបគ្នារវាងព្រះពុទ្ធសាសនា និងគ្រីស្តសាសនានិយាយពីសន្តិភាព និងពីសេចក្តីសុខផ្លូវចិត្ត»។

ព្រះតេជគុណ ង៉ែត ចម្រើន បានធ្វើការពន្យល់ថា នៅក្នុងព្រះពុទ្ធសាសនា ព្រះអង្គបានសម្តែង សុខោពុទ្ធា នមុបាទោ ការកើតឡើងនៃព្រះសម្មាសម្ពុទ្ធ ការត្រាស់ដឹងនៃព្រះសម្មាសម្ពុទ្ធ នាំឱ្យនាំមកនូវសេចក្តីសុខ។ សុខោ សុធម្មសវណំ បានសម្តែងនូវព្រះធម៌ការបានស្តាប់នូវព្រះធម៌នាំមកឱ្យនូវសេចក្តីសុខ។ សង្ឃសាមគ្គីសាមគ្គាណំ តបោសុខោ ការព្រមព្រៀងគ្នា ការសាមគ្គីគ្នាជាពួកជាក្រុម ដូចក្នុងថ្ងៃនេះរវាងព្រះពុទ្ធសាសនា និងគ្រីស្តសាសនា បង្កើតបានសេចក្តីសុខ។









ជាការឆ្លើយតបនឹងទិវានេះ លោកអូលីវីយ៉េ ក៏បានមានប្រសាសន៍ និងលើកយកព្រះបន្ទូលព្រះយេស៊ូថា៖ «ថ្ងៃនេះខ្ញុំសូមស្វាគមន៍បងប្អូនទាំងអស់នៅក្នុងទិវាសន្តិភាពអន្តរជាតិ ដែលជាពេលវេលាមួយដែលពិភពលោកកំពុងអធិដ្ឋាន ដើម្បីឱ្យអំពើហិង្សា ដើម្បីឱ្យសង្គ្រាមទៅឆ្ងាយពីយើង និងសម្រាប់យើងដែលជាគ្រីស្តបរិស័ទ យើងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ»។

លោកអភិបាលរូបនេះ បានបញ្ជាក់ទៀតថា៖ «ខ្ញុំទុកសេចក្តីសុខសាន្តឱ្យអ្នករាល់គ្នា ខ្ញុំផ្តល់សេចក្តីសុខសាន្តរបស់ខ្ញុំឱ្យអ្នករាល់គ្នា។ សេចក្តីសុខសាន្តដែលខ្ញុំផ្តល់ឱ្យនេះមិនដូចសេចក្តីសុខសាន្តដែលមនុស្សលោកឱ្យទេ»។

លោកអូលីវីយ៉េ បានបន្តថា នេះជាពេលវេលាដើម្បីនឹកឃើញព្រះយេស៊ូយាងមក ដើម្បីឱ្យមនុស្សបង្កើតសេចក្តីសុខនៅក្នុងដួងចិត្ត។ នៅពេលមនុស្សមានសេចក្តីសុខសាន្តនៅក្នុងដួងចិត្ត ពួកគេអាចធ្វើដំណើរនៅក្នុងសង្គម អាចចែករំលែកសេចក្តីសុខដល់បងប្អូនឯទៀតៗ នៅក្នុងក្រុមគ្រួសារ នៅកន្លែងដែលអ្នករាល់ធ្វើការ ឬនៅសាលារៀនជាដើម។

លោកបានមានប្រសាសន៍ថា ៖ «នៅថ្ងៃនេះដែរ យើងទាំងពីរអង្គបានជួបជុំគ្នា គឺយើងចង់បង្ហាញថាពិតមែននៅក្នុងជីវិតរបស់យើងជាអ្នកបួស សេចក្តីសុខសាន្តជាអាទិភាព ហើយយើងចង់ណែនាំទាំងគ្រីស្តបរិស័ទនិងពុទ្ធបរិស័ទ ចូលនៅក្នុងជីវិតសុខដុមរមនាពោរពេញដោយសេចក្តីសុខសាន្ត»។

នាទិវានេះផងដែរ បព្វជិតទាំងពីរអង្គ បានផ្ញើសារទៅកាន់បរិស័ទទាំងឡាយ តាមរបៀបសាសនារៀងៗខ្លួន សូមឱ្យប្រជាពលរដ្ឋខ្មែរទូទាំងកម្ពុជរដ្ឋជួបតែសេចក្តីសុខសាន្ត និងសូមឱ្យមនុស្សគ្រប់រូបយកចិត្តទុកដាក់ដើម្បីកសាងសេចក្តីសុខដើម្បីឈ្នះមេរោគកូវីដ១៩ ៕



# *យើងជាគ្រួសារតែមួយ!*

ព្រះសហគមន៍កាតូលិករបស់យើងជាគ្រួសារដ៏ធំធេងមួយ នៅក្នុងទុក្ខលំបាកកូវីដ-១៩នេះ
យើងយកចិត្តទុកដាក់ជួយគ្នាទៅវិញទៅមក និងចែករំលែកសេចក្ដីស្រលាញ់ដល់បងប្អូនរបស់យើង។
ព្រះសហគមន៍ជួយដល់អ្នកត្រូវការអំឡុងពេលដែលយើងរួមគ្នាប្រយុទ្ធនឹងជំងឺកូវីដ-១៩។

## សកម្មភាពនានានៃព្រះសហគមន៍ភូមិភាគភ្នំពេញ









## សកម្មភាពព្រះសហគមន៍ភូមិភាគបាត់ដំបង









## សកម្មភាព នានានៃព្រះសហគមន៍ភូមិភាគកំពង់ចាម







